អង្គការពលកម្មអន្តរជាតិ

រោងចក្រកាន់តែប្រសើរនៅកម្ពុជា

# របាយការណ៍សំយោគលើកទី ១១
# ស្តីពី
# ស្ថានភាពនៃលក្ខខណ្ឌការងារ
# ក្នុងវិស័យកាត់ដេរនៅកម្ពុជា

ខែ មិថុនា ឆ្នាំ ២០០៥

**១. សេចក្តីផ្តើម......៣**

១.១ ប្រវត្តិនៃគំរោង......៣

១.២ ប្រព័ន្ធតាមឃ្លាំមើល......៤

១.៣ របាយការណ៍សំយោគនេះ......៥

**២. លក្ខខណ្ឌការងារក្នុងរោងចក្រចំនួន ៥០......៧**

**២.១ លក្ខខណ្ឌការងារ......៨**

២.១.១ បទបញ្ជាផ្ទៃក្នុង......៨

២.១.២ កិច្ចសន្យាការងារ......៩

២.១.៣ អនុសញ្ញារួម......១២

២.១.៤ ប្រាក់ឈ្នួល......១២

២.១.៥ សោហ៊ុយធ្វើដំណើរត្រឡប់......១៨

២.១.៦ ថិរវេលាធ្វើការ......១៨

២.១.៧ ការឈប់សំរាក......២០

២.១.៨ ការឈប់សំរាកលំហែមាតុភាព......២៣

២.១.៩ ការបំបៅកូន......២៤

២.១.១០ បន្ទប់បំបៅកូន/ទារកដ្ឋាន......២៥

២.១.១១ ការបៀតបៀនខាងផ្លូវភេទ/តិរិយាបថមិនសមរម្យ......២៥

២.១.១២ ការរើសអើង......២៦

២.១.១៣ ពលកម្មដោយបង្ខំ......២៧

២.១.១៤ ពលកម្មកុមារ......២៧

**២.២ សុវត្ថិភាព និង អនាម័យ......២៨**

២.២.១.១ គោលនយោបាយស្តីពីសុវត្ថិភាព និង អនាម័យ......២៨

២.២.១.២ គ្រោះថ្នាក់ការងារ/ជំងឺវិជ្ជាជីវៈ......២៩

២.២.១.៣តារាំកាលិកសំរាប់គ្រោះថ្នាក់ការងារ ឬ ជំងឺវិជ្ជាជីវៈ......៣០

២.២.១.៤ ការចាត់ចែងពេលមានអាសន្ន......៣១

២.២.១.៥ ការសង្គ្រោះបឋម......៣២

២.២.១.៦ គិលានដ្ឋាន......៣៣

២.២.២ ការប្រើប្រាស់ សារធាតុគ្រោះថ្នាក់......៣៤

២.២.២.១ ការស្តុកទុក......៣៤

២.២.២.២វិធានការការពារ......៣៦

២.២.៣ ភ្លើងបំភ្លឺ......៣៦

២.២.៤ សូរសំលេង......៣៧

២.២.៥ សុវត្ថិភាពនៃគ្រឿងម៉ាស៊ីន......៣៧

២.២.៦. ខ្យល់ចេញចូល និង កំដៅ...........................................................................................៣៨
២.២.៧ គេហកិច្ច...............................................................................................................៣៩
២.២.៨ សុខុមាលភាព.........................................................................................................៤០
២.២.៨.១ ភេសជ្ជៈអនាម័យ.................................................................................................៤០
២.២.៨.២ ការរៀបចំបង្គន់អនាម័យ.......................................................................................៤១
២.២.៨.៣ កន្លែងផ្ទុកឥវ៉ាន់ផ្ទាល់ខ្លួន........................................................................................៤៣
២.២.៩ ការរៀបចំអាសនៈ...................................................................................................៤៣
**២.៣ ទំនាក់ទំនងក្នុងវិស័យការងារ**...............................................................................៤៤
២.៣.១ សេរីភាពនៃកម្មករនិយោជិតក្នុងការបង្កើតអង្គការវិជ្ជាជីវៈ..................................................៤៤
២.៣.២ ការរើសអើងប្រឆាំងសហជីព.......................................................................................៤៦
២.៣.៣ ប្រតិភូបុគ្គលិក.........................................................................................................៤៧
២.៣.៤ មន្ត្រីទំនាក់ទំនង.........................................................................................................៤៩
២.៣.៥ វិវាទការងាររួម (ក្នុងកំឡុងពេល ១២ខែមុនការឃ្លាំមើល)..................................................៥០
២.៣.៦ កូដកម្ម / ឡុកអៅ ( រយៈពល ១២ខែកន្លងមក ដោយគិតនៅមុនពេលចុះធ្វើការតាមឃ្លាំមើល).................៥១
២.៣.៧ វិវាទបុគ្គល (រយៈពល ១២ខែកន្លងមក ដោយគិតនៅមុនពេលចុះធ្វើការតាមឃ្លាំមើល)............................៥៣
**សេចក្តីសន្និដ្ឋានបញ្ចប់**......................................................................................................៥៤

## ១. សេចក្តីផ្តើម

### ១.១ ប្រវត្តិនៃគំរោង

វិស័យកាត់ដេរសំលៀកបំពាក់ បានរីកលូតលាស់យ៉ាងលឿនចាប់តាំងពីចុងទសវត្សន៏ឆ្នាំ ១៩៩០មក ភាគច្រើននៃការលូតលាស់នេះ គឺដោយសារល័ក្ខខ័ណ្ឌអំណោយផលខាងពាណិជ្ជកម្ម ដែលផុសចេញមកពីកិច្ចព្រមព្រៀងពហុសរសៃអំបោះ (MFA) ។

ក្រោមការចុះហត្ថលេខាលើកិច្ចព្រមព្រៀងទូទៅលើពន្ធលើតវ៉ាន់នាំចេញ ឬ ចូល និងពាណិជ្ជកម្ម (GATT) កិច្ចព្រមព្រៀងពហុសរសៃអំបោះ បានធ្វើឱ្យប្រទេសដែលមានតំលៃផលិតសំលៀកបំពាក់ខ្ពស់ ដូចជាប្រទេសសហរដ្ឋអាមេរិក និង ប្រទេសសហភាពអឺរ៉ុប ដាក់កំណត់លើការនាំចូលពីប្រទេសដែលមានតំលៃផលិតសំលៀកបំពាក់ទាប ដូចជាប្រទេសចិន និង ឥណ្ឌា ។

ប្រទេសកម្ពុជាក៏ទទួលបានផលប្រយោជន៏បន្ទាប់បន្សំដែរ ។ ដោយផ្អែកលើការកំណត់លើការនាំចូល អ្នកទិញនៃប្រទេសអ្នកមាន ចាប់ផ្តើមទិញសំលៀកបំពាក់ពីប្រទេសដែលពុំមានកំណត់ចំនួនកូតា ។ ប្រទេសកម្ពុជាជាប្រទេសមួយក្នុងចំណោមប្រទេសទាំងនេះ ។ ពាណិជ្ជកម្មសំលៀកបំពាក់នៅក្នុងប្រទេសកម្ពុជា បានចាប់ផ្តើមយ៉ាងឆាប់រហ័សនៅឆ្នាំ ១៩៩៨ ហើយរដ្ឋាភិបាលសហរដ្ឋអាមេរិក ចាប់ផ្តើមធ្វើការចរចាដើម្បីដាក់ប្រទេសកម្ពុជានៅក្រោមប្រព័ន្ធកូតា។ កិច្ចព្រមព្រៀងបានកំណត់ចំនួនកូតានាំចេញផលិតផលកាត់ដេរពីប្រទេសកម្ពុជា ទៅនឹងល័ក្ខខ័ណ្ឌការងារ ហើយសហរដ្ឋអាមេរិក នឹងផ្តល់រង្វាន់នាំចេញដល់កម្ពុជា ដ៏រាបណាប្រទេសកម្ពុជា ធ្វើការកែលំអឱ្យបានប្រសើរនូវល័ក្ខខ័ណ្ឌការងារ ។

គំរោងរោងចក្រកាន់តែប្រសើរនៅកម្ពុជា (ដែលពីមុនត្រូវបានគេស្គាល់ថា គំរោងកែលំអល័ក្ខខ័ណ្ឌការងារក្នុងវិស័យកាត់ដេរនៅកម្ពុជា) បង្កើតឡើងក្នុងឆ្នាំ ២០០១ ដើម្បីជួយដល់គំរោងនេះទទួលបាន និងធ្វើការកែលំអឱ្យបានប្រសើរឡើងនូវល័ក្ខខ័ណ្ឌការងារ ។ គំរោងឃ្លាំមើល នឹងរាយការណ៏ពីល័ក្ខខ័ណ្ឌការងារអំពីរោងចក្រកាត់ដេរនៅក្នុងប្រទេសកម្ពុជាឱ្យទៅតាមបទដ្ឋានជាតិ និងអន្តរជាតិ ។ គំរោងក៏ជួយដល់រោងចក្រធ្វើឱ្យមានការកើនផលិតភាពផងដែរ ហើយធ្វើការជាមួយរដ្ឋាភិបាល និងអ្នកទិញអន្តរជាតិដើម្បីធានាឱ្យប្រាកដថា មានវដ្តនៃការកែលំអល័ក្ខខ័ណ្ឌការងារមួយដ៏ច្បាស់លាស់ និងហ្មត់ចត់ ។

កិច្ចព្រមព្រៀងពហុសរសៃអំបោះបានផុតកំណត់នៅថ្ងៃទី ៣០ ខែធ្នូ ឆ្នាំ ២០០៤ ដែលផ្តល់ឱកាសដល់ប្រទេសទាំងអស់ធ្វើការប្រកួតប្រជែងជាលក្ខណៈសកល ។ កិច្ចព្រមព្រៀងពាណិជ្ជកម្មកម្ពុជា សហរដ្ឋអាមេរិកក៏បានបញ្ចប់ផងដែរនៅដំណាច់ឆ្នាំ ២០០៤ ។ អ្នកផលិតតូចៗ ដូចជាប្រទេសកម្ពុជា ឥឡូវនេះត្រូវតែធ្វើឱ្យមានការលេចធ្លោជាងគេនៅក្នុងទីផ្សារបើសិនជាពួកគេចង់រក្សាការប្រកួតប្រជែង ។ ប្រទេសកម្ពុជាបានធ្វើខ្លួនលេចធ្លោក្នុងកំរិតមួយ ដែលមានការធ្វើឱ្យប្រសើរឡើងនូវល័ក្ខខ័ណ្ឌការងារជាលំដាប់ និងបានសំរួលដល់ការផ្តល់ពត៌មាន ដែលអាចជឿទុកចិត្តបានអំពីការគោរពច្បាប់ការងារ បទដ្ឋានជាតិ និង អន្តរជាតិរបស់រោងចក្រ ។ គំរោងរោងចក្រកាន់តែប្រសើរនៅកម្ពុជា នឹងធ្វើការស្វះស្វែង ដើម្បីធ្វើការកសាងនូវភាពរីកចំរើនដែលមានរួចស្រេចហើយនេះ ។

គំរោងរោងចក្រកាន់តែប្រសើរនៅកម្ពុជា ត្រូវបានណែនាំតម្រង់ទិសដៅ ដោយគណៈកម្មការប្រឹក្សាគំរោង (PAC) ដែលមានសមាសភាពនៃតំណាងបីភាគី ដោយភាគីតំណាងនិមួយៗមកពី រាជរដ្ឋាភិបាលកម្ពុជា សមាគមរោងចក្រកាត់ដេរនៅកម្ពុជា (GMAC) និងមកពីចលនាសហជីពកម្ពុជា ។ គណៈកម្មការប្រឹក្សាគំរោង ផ្តល់ឱវាទដល់គំរោងលើគ្រប់សកម្មភាពរបស់ខ្លួនទាំងអស់ ជារួម មានការចុះឃ្លាំមើល ការកែលំអ និង និរន្តភាពរបស់គំរោង ។

## ១.២ <u>ប្រព័ន្ធតាមឃ្លាំមើល</u>

ប្រព័ន្ធតាមឃ្លាំមើលរួមមានបីផ្នែកសំខាន់ៗ ដូចតទៅនេះ :

- ការចុះបញ្ជិការោងចក្រដែលចូលរួម
- ការធ្វើការចុះតាមឃ្លាំមើល និងធ្វើរបាយការណ៍អំពីការចុះពិនិត្យមើលទាំងនេះ
- ការធ្វើរបាយការណ៍អំពីលទ្ធផលដែលបានរកឃើញទាំងអស់ពីការងារតាមឃ្លាំមើល

### ការចុះបញ្ជិកានៃរោងចក្រដែលចូលរួម

មូលហេតុចម្បងមួយដែលគំរោងនេះទទួលបានជោគជ័យមកដល់សព្វថ្ងៃនេះ គឺថាគ្រប់រោងចក្រកាត់ដេរសំលៀកបំពាក់ទាំងអស់នៅក្នុងប្រទេស ដែលនាំចេញបានចុះបញ្ជិកាជាមួយគំរោង ។ ទោះបីការចុះបញ្ជិកាជាមួយគំរោងជាការស្ម័គ្រចិត្តក៏ដោយ ក៏ក្រសួងពាណិជ្ជកម្មបានតម្រូវឱ្យរោងចក្រត្រូវចុះបញ្ជិកាជាមួយគំរោង ក្នុងការទទួលបាននូវអាជ្ញាប័ណ្ណនាំចេញ ។

ពេលដែលក្រុមហ៊ុនចុះបញ្ជីជាមួយគំរោង ពួកគេយល់ព្រមឱ្យអ្នកតាមឃ្លាំមើលរបស់អង្គការពលកម្មអន្តរជាតិចូលទៅពិនិត្យមើលសព្វទីកន្លែងក្នុងរោងចក្រ អនុញ្ញាតឱ្យអ្នកតាមឃ្លាំមើលរបស់អង្គការពលកម្មអន្តរជាតិ ធ្វើការប្រាស្រ័យទាក់ទងដោយសេរី ជាមួយប្រតិភូបុគ្គលិក តំណាងសហជីពកម្មករនិយោជិត កម្មករនិយោជិតរបស់រោងចក្រទាំងខាងក្នុង និង ខាងក្រៅបរិវេណរោងចក្រ ។

### នីតិវិធីក្នុងការធ្វើការតាមឃ្លាំមើល

*គំរោងរោងចក្រកាន់តែប្រសើរនៅកម្ពុជា* មានអ្នកឃ្លាំមើលចំនួន ១១ នាក់ ដែលមានគ្នាពីរនាក់ ក្នុងការចុះពិនិត្យមើលរោងចក្រ និង ការមកដល់រោងចក្រដោយមិនជូនពតិមានជាមុន ។ បញ្ជីផ្ទៀងផ្ទាត់របស់អ្នកឃ្លាំមើលដែលផ្អែកលើច្បាប់ស្តីពីការងារកម្ពុជា និង បទដ្ឋានគ្រឹះរបស់អង្គការពលកម្មអន្តរជាតិ មានជាង ៥០០ ចំនុច ។ ដើម្បីធានាឱ្យមានសុក្រិត្យភាព អ្នកឃ្លាំមើលធ្វើការសំភាសន៍ជាមួយកម្មករនិយោជិត និង អ្នកគ្រប់គ្រងដោយឡែកពីគ្នា និងដោយរក្សាការសំងាត់ ។ ការសំភាសន៍ជាមួយកម្មករនិយោជិតជាធម្មតាធ្វើឡើងនៅឆ្ងាយពីរោងចក្រ ។ អ្នកឃ្លាំមើលក៏ធ្វើការសំភាសន៍ជាមួយប្រតិភូបុគ្គលិក និង មេដឹកនាំសហជីពផងដែរ ។ អ្នកឃ្លាំមើល ក៏បានស្នើសុំអ្នកគ្រប់គ្រង

រោងចក្រឱ្យផ្តល់នូវឯកសារពាក់ព័ន្ធនានា (ដូចជាបញ្ជីបើកប្រាក់ខែ គំរូប្រភេទកិច្ចសន្យា ឯកសារស្តីពីការឈប់សំរាកនានា ។ល។) ដើម្បីបញ្ជាក់ពីភស្តុតាងនៃល័ក្ខខ័ណ្ឌការងារ និង ខនានានៃកិច្ចសន្យា ។

អ្នកគ្រប់គ្រងរោងចក្រទទួលបាននូវរបាយការណ៏ស្តីពីរបកគំហើញនានា ដែលរួមបញ្ចូលទាំងសំណូមពរសំរាប់កែប្រែល័ក្ខខ័ណ្ឌឱ្យប្រសើរផងដែរ ។ បន្ទាប់ពីមានការពិភាក្សាលើរបាយការណ៏ និង សកម្មភាពចុះតាមដានមក អ្នកឃ្លាំមើលចុះពិនិត្យមើលភាពប្រសើរឡើងនៅក្នុងរោងចក្រម្តងទៀត ។ ដោយផ្អែកលើសំណើពីអ្នកគ្រប់គ្រង គំរោងអាចនឹងជួយដល់រោងចក្រនានាក្នុងការអនុវត្តន៏សំណូមពរដែលលើកឡើងដោយគំរោង ។

ការចុះពិនិត្យតាមដានត្រូវបានធ្វើឡើងដោយមានគ្នាពីរនាក់ ដែលជាគោលការណ៏យ៉ាងហោចណាស់ ត្រូវមានអ្នកឃ្លាំមើលម្នាក់ជាសមាជិកនៃក្រុមឃ្លាំមើលដែលបានចុះពិនិត្យរោងចក្រកាលពីមុន ។ ការចុះពិនិត្យតាមដាននេះអ្នកឃ្លាំមើលបានផ្តោតទៅលើវឌ្ឍនភាពដែលសំរេចបានក្នុងការអនុវត្តន៏នូវសំណូមពរ ។ បន្ថែមពីលើនេះទៀត អ្នកតាមឃ្លាំមើល ក៏ពិនិត្យមើលការផ្លាស់ប្តូរទាក់ទងនឹងបទដ្ឋានការងារសំខាន់ៗ មួយចំនួនមានជាអាទិ៍ សេរីភាពក្នុងការបង្កើតជាអង្គការវិជ្ជាជីវៈ និង ពលកម្មកុមារ ព្រមទាំងការផ្លាស់ប្តូរសំខាន់ៗ ទាក់ទងនឹងល័ក្ខខ័ណ្ឌការងារនានានៅរោងចក្រ ។

**នីតិវិធីក្នុងការធ្វើរបាយការណ៏**

បន្ថែមលើការផ្តល់ឱ្យរបាយការណ៏ផ្ទាល់របស់រោងចក្រនិមួយៗ គំរោងថែមទាំងរៀបចំរបាយការណ៏សំយោគដែលនឹងផ្តល់នូវសេចក្តីពណ៌នាជាទូទៅពីល័ក្ខខ័ណ្ឌការងារនៅក្នុងចង្កោមរោងចក្រ (រោងចក្រទាំងអស់ ត្រូវបានបែងចែកជាក្រុមៗ នៅពេលដែលរោងចក្រទាំងនោះចុះបញ្ជិកា) ។ របាយការណ៏សំយោគដែលមានបង្ហាញពីលទ្ធផលរកឃើញក្នុងពេលចុះពិនិត្យមើលលើកដំបូង គឺពុំបានបង្ហាញឱ្យដឹងពីឈ្មោះរោងចក្រទេ ដើម្បីផ្តល់ដល់រោងចក្រនូវពេលវេលាសមស្របមួយ សំរាប់រោងចក្រធ្វើការកែប្រែធ្វើឱ្យប្រសើរឡើងនូវល័ក្ខខ័ណ្ឌការងារ ។ ទោះជាយ៉ាងណារបាយការណ៏សំយោគ ដែលរាប់អំពីការចុះពិនិត្យតាមដានលើរោងចក្រ គឺត្រូវបង្ហាញឱ្យដឹងពីឈ្មោះរោងចក្រនានាដែលបញ្ចូលក្នុងរបាយការណ៏សំយោគ ។ គណៈកម្មការប្រឹក្សាគំរោង ធ្វើការពិភាក្សារាល់របាយការណ៏សំយោគ ហើយយោបល់នានារបស់ខ្លួន ត្រូវបានកត់ត្រាទុក ។ របាយការណ៏សំយោគមានទាំងភាសាខ្មែរ និងភាសាអង់គ្លេស ហើយត្រូវបានផ្សព្វផ្សាយលើទំព័រវេបសាយ របស់អង្គការពលកម្មអន្តរជាតិ ។

## ១.៣ របាយការណ៏សំយោគនេះ

របាយការណ៏សំយោគលើកទី ១១ នេះ មានសេចក្តីពណ៌នាជារួមទូទៅអំពីរបកគំហើញ ដែលធ្វើឡើងក្នុងកំឡុងពេលធ្វើការពិនិត្យលើកដំបូងទៅកាន់រោងចក្រចំនួន ៥០ ។ ក្នុងពេលធ្វើការពិនិត្យ រោងចក្រទាំងអស់នេះ ជួលកម្មករនិយោជិតឱ្យបំរើការងារចំនួន ៤២.៩៣៧ នាក់ ដែលរួមមាន ស្ត្រីចំនួន ៤០.១២០ នាក់ និង បុរសចំនួន ២.៨១៧ នាក់ ។

រោងចក្រនៅក្នុងចំណោមក្រុមនេះ មានការគោរពច្បាប់ក្នុងកំរិតទាបនៅឡើយ បញ្ហានេះប្រហែលជាដោយសារតែរបាយការណ៍លើកនេះបង្ហាញពីព័ត៌មានដែលទទួលបានមកពីការចុះឃ្លាំមើលជាលើកដំបូង ។ ជាធម្មតារោងចក្រធ្វើការកែប្រែលក្ខខ័ណ្ឌការងារឱ្យល្អប្រសើរ បន្ទាប់ពីទទួលបានរបាយការណ៍ឃ្លាំមើលជាលើកដំបូង ហើយរោងចក្រទាំងនោះបន្តការកែប្រែតទៅទៀតជាមួយនឹងការចុះតាមដានពិនិត្យជាបន្តបន្ទាប់ ។

ក្នុងពេលដំណាលគ្នាដែលរបាយការណ៍នេះបង្ហាញពីកំរិតនៃការអនុវត្តន៍ច្បាប់លើចំនុចមួយចំនួនធំ របកគំហើញសំខាន់នៃរោងចក្រចំនួន ៥០ ដែលបានរៀបរាប់ក្នុងរបាយការណ៍នោះមានដូចខាងក្រោម :

| លទ្ធផលសំខាន់ៗរកឃើញក្នុងរបាយការណ៍ទី ១១ |
|---|
| ♦ គ្មានភស្តុតាងបញ្ជាក់ពីការងារដោយបង្ខំទេ។<br>♦ នៅក្នុងរោងចក្រចំនួន ៦ អ្នកគ្រប់គ្រងបានបណ្តេញកម្មករនិយោជិតដែលមានផ្ទៃពោះចេញពីការងារ ឬ បង្ខំឱ្យពួកគេលាលែងពីការងារ ហើយនៅក្នុងរោងចក្រមួយ អ្នកគ្រប់គ្រងបានបញ្ឈប់ ឬ ផ្លាស់ប្តូរប្រភេទកិច្ចសន្យាការងារក្នុងខណៈពេលការសំរាកមាតុភាពរបស់កម្មករនិយោជិត ។<br>♦ នៅក្នុងរោងចក្រមួយ អ្នកគ្រប់គ្រងមិនបានជ្រើសរើសបុរសណាម្នាក់ឱ្យធ្វើការទេ ដោយសារតែតាមពិសោធន៍កន្លងមកបង្ហាញថាបុរសដឹកនាំធ្វើកូដកម្ម។<br>♦ រោងចក្រជាងពាក់កណ្តាលមានបញ្ហាដោយសារតែអ្នកគ្រប់គ្រងខ្សែបណ្តាញខកខានមិនបានគោរពគប្បី នឹងកម្មករនិយោជិត ។<br>♦ នៅក្នុងរោងចក្រចំនួន ៤ គេបានរកឃើញ កម្មករនិយោជិតក្រោមអាយុចំនួន ១០ នាក់ធ្វើការ ។<br>♦ រោងចក្រភាគច្រើនដែលបានចុះត្រួតពិនិត្យ មិនបានគោរពពេញលេញនូវតំរូវការប្រាក់ឈ្នួលអប្បបរមា បញ្ហានេះជាទូទៅកើតមានឡើង ពាក់ព័ន្ធនឹងកម្មករនិយោជិតម្តងម្កាល ។<br>♦ រោងចក្រភាគច្រើនមានបញ្ហានឹងការធានាឱ្យប្រាកដថា ការធ្វើការបន្ថែមម៉ោង ផ្អែកលើការស្ម័គ្រចិត្ត មិនញឹកញាប់ពេក និង មិនឱ្យលើសពី ២ ម៉ោងក្នុងមួយថ្ងៃ ។<br>♦ រោងចក្រមួយចំនួនតូច មានបញ្ហាជាសំខាន់ក្នុងការធានាឱ្យមានសេរីភាពក្នុងការបង្កើតអង្គការវិជ្ជាជីវៈ និងការមិនរើសអើងចំពោះសហជីព ។<br>♦ ពុំមានកូដកម្មណាមួយនៅក្នុងចំណោមរោងចក្រក្រុមនេះ ដែលកើតមានឡើងក្នុងរយៈពេល ១២ ខែកន្លងមក ដោយគិតនៅមុនពេលចុះធ្វើការពិនិត្យតាមឃ្លាំមើល ត្រូវបានធ្វើឡើងដោយអនុលោមតាមនីតិច្បាប់នោះទេ។<br>♦ រោងចក្រមួយចំនួនខកខានមិនបានគោរពឱ្យបានត្រឹមត្រូវតាមបទដ្ឋាននានាអំពីសុខភាព និង សុវត្ថិភាពការងារនោះទេ ដូចជាការផ្តល់ និង ការប្រើប្រាស់នូវឧបករណ៍ការពារ ការតំឡើងការការពារសុវត្ថិភាពនៃម៉ាស៊ីន ការបង្រៀនអំពីសុវត្ថិភាពឱ្យបានត្រឹមត្រូវ និង ខ្យល់អាកាសចេញចូលឱ្យបានគ្រប់គ្រាន់ ។ |

របាយការណ៍សំយោគនេះ មិនបានបញ្ចេញឈ្មោះឱ្យដឹងថាតើរោងចក្រណាមួយ ត្រូវអនុវត្តសំណូមពរដើម្បីធ្វើការកែលំអលក្ខខ័ណ្ឌការងារឡើយ ដោយសារតែរបាយការណ៍នេះបញ្ជាក់ពីស្ថានភាពនានា ដែលបានចុះតាមឃ្លាំមើល

ជាលើកដំបូងតែប៉ុណ្ណោះ ។ រោងចក្រត្រូវបានបញ្ចេញឈ្មោះឱ្យដឹង និងភាពរីកចំរើនរបស់ខ្លួនលើការកែលំអ ត្រូវកត់សំគាល់ តែនៅក្នុងរបាយការណ៍បន្ទាប់ពីការចុះពិនិត្យតាមដានលើកទី ២ តែប៉ុណ្ណោះ ។

## ២. លក្ខខណ្ឌការងារក្នុងរោងចក្រចំនួន ៥០

ពត៌មាននៅក្នុងជំពូកនេះ ត្រូវបានធ្វើឡើងតាមទំរង់នៃបញ្ជីផ្ទៀងផ្ទាត់ដែលប្រើប្រាស់ដោយអ្នកតាមឃ្លាំមើល ពេលដែលពួកគេចុះឃ្លាំមើលរោងចក្រ ។ អនុជំពូកនិមួយៗ មានសេចក្តីពិពណ៌នាអំពីច្បាប់ជាធរមាន ហើយជាបន្ទាប់ មានសេចក្តីពណ៌នាអំពីការអនុវត្តន៍ក្នុងតារាងដែលបានរកឃើញដោយអ្នកតាមឃ្លាំមើល ។ នៅក្នុងខ្ទង់ទីមួយនៃតារាង មានរៀបរាប់អំពីសំណូមពរសំរាប់ធ្វើការកែលំអ ដែលបានលើកឡើងសំរាប់រោងចក្រ ក្រោយពីចុះតាមឃ្លាំមើល ។ ខ្ទង់កណ្តាលនៃតារាង បង្ហាញពីចំនួន និង ភាគរយនៃរោងចក្រដែលតំរូវតាមសំណូមពរដែលបានលើកឡើង ។ នៅក្នុងខ្ទង់ចុងក្រោយនៃតារាងបង្ហាញពី ថាតើរោងចក្រចំនួន (បើសិនជាមាន)ប៉ុន្មាន បានអនុវត្តទាំងស្រុង ឬ ដោយអន្លើនូវសំណូមពរដែលបានលើកឡើងបន្ទាប់ពីចុះតាមឃ្លាំមើលជាលើកដំបូង និង មុនពេលដែលរបាយការណ៍ឃ្លាំមើល ត្រូវបានធ្វើហើយជាស្ថាពរ ។

**គន្លឹះ**

និមិត្តសញ្ញាខាងក្រោមនេះត្រូវបានប្រើនៅអនុជំពូក ២ នៃរបាយការណ៍ដើម្បីសំគាល់រោងចក្រមួយចំនួន ដែលសំណូមពរខ្លះពាក់ព័ន្ធតែចំពោះកម្មករប្រភេទណាមួយ :

(A) សំគាល់រោងចក្រដែលសំណូមពរ តំរូវតែចំពោះអ្នកហាត់ការ (កូនជាង) ។

(C) សំគាល់រោងចក្រដែលសំណូមពរ តំរូវតែចំពោះកម្មករនិយោជិតម្តងម្កាល ។

(PR) សំគាល់រោងចក្រដែលសំណូមពរតំរូវតែចំពោះកម្មករនិយោជិត ទទួលប្រាក់ឈ្នួលតាមបរិមាណផលិតផល ។

( PW ) សំគាល់រោងចក្រដែលសំណូមពរ តំរូវតែចំពោះកម្មករនិយោជិតសាកល្បង ។

ចំនួននៃរោងចក្រដែលសំណូមពរ ត្រូវបានលើកឡើងសំរាប់តែប្រភេទកម្មករនិយោជិតណាមួយជាក់លាក់នោះ ពុំត្រូវបានដាក់ចូលក្នុងតួលេខដែលតំណាងដោយរោងចក្រដែលគ្មានការបែងចែកត្រូវបានធ្វើឡើងនោះទេ ។

ជាឧទាហរណ៍ :

| អ្នកគ្រប់គ្រង | ចំនួន និងភាគរយនៃរោងចក្រដែលមានសំណូមពរចំពោះបញ្ហានេះ (មិនអនុវត្ត) | ចំនួននៃរោងចក្រដែលធ្វើឱ្យលក្ខខណ្ឌការងារប្រសើរភ្លាមៗ មុននឹងរបាយការណ៍ឃ្លាំមើលសំរេចជាស្ថាពរ |
|---|---|---|
| គប្បីផ្តល់ដល់កម្មករនិយោជិតនូវប្រាក់ឈ្នួលប្រចាំថ្ងៃសំរាប់ថ្ងៃបុណ្យពេលដែលពួកគេមិនធ្វើការ ។ | ២ (៤%)<br>២ PR (៤%)<br>៤ C (៨%) | 0 |

សំណូមពរនេះត្រូវបានលើកឡើងសំរាប់រោងចក្រចំនួន ២ ដែលខកខានមិនបានផ្តល់ប្រាក់ឈ្នួលឱ្យបានត្រឹមត្រូវសំរាប់ថ្ងៃឈប់បុណ្យ ប៉ុន្តែពុំមានការបែងចែកឱ្យបានដាច់ពីគ្នាចំពោះប្រភេទកម្មករនិយោជិតបែបណា ដែលមិនបានទទួលប្រាក់ឈ្នួលត្រឹមត្រូវ ។ រោងចក្រចំនួន ២ ពុំបានផ្តល់ប្រាក់ឈ្នួលដល់កម្មករនិយោជិតដែលទទួលប្រាក់ឈ្នួល តាមបរិមាណផលិតផលឱ្យបានត្រឹមត្រូវសំរាប់ថ្ងៃឈប់បុណ្យ និង រោងចក្រចំនួន ៤ ពុំបានផ្តល់ប្រាក់ឈ្នួលដល់កម្មករនិយោជិតម្តងម្កាលឱ្យបានត្រឹមត្រូវសំរាប់ថ្ងៃឈប់បុណ្យ ។ ជាសរុបរោងចក្រចំនួន ៨ ដែលនៅមានបញ្ហា នឹងការទូទាត់ប្រាក់ឈ្នួលសំរាប់ថ្ងៃឈប់បុណ្យ ។ ពុំមានរោងចក្រណាមួយធ្វើឱ្យប្រសើរឡើង នូវការផ្តល់ប្រាក់ឈ្នួលសំរាប់ថ្ងៃឈប់បុណ្យ មុនពេលរបាយការណ៍ឃ្លាំមើលត្រូវបានធ្វើហើយជាស្ថាពរនោះទេ ។

## ២.១ **លក្ខខ័ណ្ឌការងារ**

### ២.១.១ បទបញ្ជាផ្ទៃក្នុង

ច្បាប់ ( មាត្រា ២២-២៥ ២៩ ៣០ និង ២៨៤ សេចក្តីជូនដំណឹង ១៤/០២) :

សហគ្រាសទាំងឡាយត្រូវមានបទបញ្ជាផ្ទៃក្នុងបញ្ជាក់ច្បាស់ពីល័ក្ខខ័ណ្ឌនៃការងារ ។ បទបញ្ជាផ្ទៃក្នុងត្រូវតែរៀបចំឡើងដោយមានការពិគ្រោះយោបល់ជាមួយនឹងតំណាងកម្មករនិយោជិត ។ ប្រការទាំងឡាយនៅក្នុងបទបញ្ជាផ្ទៃក្នុងដែលមិនអនុលោមតាមច្បាប់ត្រូវទុកជាមោឃៈ ។ បទបញ្ជាផ្ទៃក្នុងត្រូវសរសេរជាភាសាខ្មែរ ដាក់នៅកន្លែងត្រឹមត្រូវ និងងាយស្រួលចូល ហើយអាចមើលបានច្បាស់ទៀតផង ។ សហគ្រាសត្រូវឱ្យមានការទទួលស្គាល់លើបទបញ្ជាផ្ទៃក្នុងពីអធិការការងារ ។

**សំណូមពរដែលលើកឡើងសំរាប់រោងចក្រ :**

| អ្នកគ្រប់គ្រង | ចំនួននិងភាគរយនៃរោងចក្រដែលមានសំណូមពរចំពោះបញ្ហានេះ (មិនអនុវត្ត) | ចំនួននៃរោងចក្រដែលធ្វើឱ្យល័ក្ខខ័ណ្ឌការងារប្រសើរភ្លាមៗ មុននឹងរបាយការណ៍ឃ្លាំមើលសំរេចជាស្ថាពរ |
|---|---|---|
| គប្បីបង្កើតឱ្យមាននូវបទបញ្ជាផ្ទៃក្នុង ។ | ១៤ (២៨%) | ២ |
| | | |
| គប្បីបង្កើតឱ្យមាននូវបទបញ្ជាផ្ទៃក្នុងសំរាប់ហ៊ីកហ៊ឺនកូនជាង ។ | ៤ (៨%) | ០ |
| | | |
| គប្បីពិគ្រោះយោបល់ជាមួយនឹងប្រតិភូបុគ្គលិកពេលបង្កើតបទបញ្ជាផ្ទៃក្នុង ។ | ២ (៤%) | ០ |

| អ្នកគ្រប់គ្រង | ចំនួននិងភាគរយនៃរោងចក្រដែលមានសំណូមពរចំពោះបញ្ហានេះ (មិនអនុវត្ត) | ចំនួននៃរោងចក្រដែលធ្វើឱ្យល័ក្ខខ័ណ្ឌការងារប្រសើរភ្លាមៗមុននឹងរបាយការណ៍ឃ្លាំមើលសំរេចជាស្ថាពរ |
|---|---|---|
| គប្បីធានាឱ្យប្រាកដថាបទបញ្ជាផ្ទៃក្នុងត្រូវស្របតាមច្បាប់ ។ | ៨ (១៦%) | 0 |
| | | |
| គប្បីធ្វើយ៉ាងណាឱ្យបទបញ្ជាផ្ទៃក្នុងទទួលស្គាល់ដោយអធិការការងារ ។ | ៣ (៦%) | ១ |
| | | |
| គប្បីបិទបទបញ្ជាផ្ទៃក្នុង នៅកន្លែងធ្វើការ ។ | ៨ (១៦%) | ១ |

**២.១.២ <u>កិច្ចសន្យាការងារ</u>**

ច្បាប់ (មាត្រា ៩ ១០ ៥១-៥៣ ៦៥-៦៨ ៧១-៧៩ ៨៩-៩១ ១១៦ ១២៦ ១៦៦ ១៦៧ និង ២៦០

ប្រកាស 00៤/00 សេចក្តីជូនដំណឹង 0៦/៩៧) :

កិច្ចសន្យាការងារ គឺជាកិច្ចសន្យាដែលបង្កើតឱ្យមានការទាក់ទងផ្នែកការងាររវាងកម្មករនិយោជិត និង និយោជក ។ កិច្ចសន្យានេះ ត្រូវនៅក្រោមវិធានអាជ្ញាគតិ និង អាចត្រូវធ្វើជាលាយល័ក្ខណ៍អក្សរ ឬដោយផ្ទាល់មាត់ ។ កម្មករនិយោជិត អាចទទួលប្រាក់ឈ្នួលបានតាមពេលវេលាធ្វើការ ឬ ក៏តាមចំនួនការងារដែលបានបំពេញ (មានន័យថា កម្មករនិយោជិត ដែលទទួលប្រាក់ឈ្នួលតាមបរិមាណផលិតផល) ។ កិច្ចសន្យាការងារ អាចធ្វើបានតាមថិរវេលាកំណត់ ឬ ថិរវេលាមិនកំណត់ ។ កម្មករនិយោជិត មិនតំរូវឱ្យបង់ប្រាក់ឱ្យនរណាម្នាក់ ដើម្បីទទួលបានការងារធ្វើឡើយ ។

កម្មករនិយោជិតដែលបំពេញការងារជាប់លាប់ គឺជាកម្មករនិយោជិតជាប់លាប់ ។ កម្មករនិយោជិតម្តងម្កាល គឺជាកម្មករនិយោជិតដែលជាប់កិច្ចសន្យាបំពេញការងារ សំរាប់តែការងារជាក់លាក់ណាមួយដែលមានរយៈពេលខ្លីតែប៉ុណ្ណោះ ។ កម្មករនិយោជិតម្តងម្កាល មានសិទ្ធិដូចគ្នានឹងកម្មករនិយោជិតជាប់លាប់ដែរ ។

កម្មករនិយោជិត អាចតំរូវឱ្យបំពេញការងារសំរាប់រយៈពេលសាកល្បង ពេលពួកគេចាប់ផ្តើមចូលធ្វើការមិនត្រូវលើសពី ៣ ខែឡើយ សំរាប់កម្មករជាប់លាប់ ។ កិច្ចសន្យាសំរាប់កូនជាង ជាអតិបរិមាមានរយៈពេល ២ ខែ ។

ពេលបញ្ចប់កិច្ចសន្យាការងារ និយោជកត្រូវគោរពតាមប្រការផ្សេងៗ ដូចជាពាក់ព័ន្ធនឹងការជូនដំណឹងជាមុន ប្រាក់បំណាច់បណ្តេញចេញ និង សំណងជំងឺចិត្ត ។ ការអនុវត្តន៍លើប្រការទាំងនេះ ខុសគ្នាពីមួយទៅមួយអាស្រ័យលើប្រភេទកិច្ចសន្យាការងារ និង កាលៈទេសៈនៅពេលមានការបញ្ចប់កិច្ចសន្យា ។

សំណូមពរដែលលើកឡើងសំរាប់រោងចក្រ ៖

| អ្នកគ្រប់គ្រង | ចំនួននិងភាគរយនៃរោងចក្រដែលមានសំណូមពរចំពោះបញ្ហានេះ (មិនអនុវត្ត) | ចំនួននៃរោងចក្រដែលធ្វើឱ្យល័ក្ខខ័ណ្ឌការងារប្រសើរភ្លាមៗ មុននឹងរបាយការណ៍ឃ្លាំមើលសំរេចជាស្ថាពរ |
|---|---|---|
| គប្បីធានាឱ្យប្រាកដថាមិនមានកម្មករនិយោជិតណាម្នាក់ ត្រូវបង់ប្រាក់ដល់នរណាម្នាក់ ដើម្បីបានចូលធ្វើការនោះទេ។ | ១១ (២២%) | ២ |
| | | |
| គប្បីធានាឱ្យប្រាកដថាកិច្ចសន្យាការងារមានរៀបរាប់អំពីខ្លឹមសារ និង ល័ក្ខខ័ណ្ឌការងារ ។ | ៦ (១២%) | 0 |
| | | |
| គប្បីកែប្រែនូវខទាំងឡាយក្នុងកិច្ចសន្យាការងារដែលពុំសមស្រប តាមច្បាប់។ | ២០ (៤០%)<br>១ PW (២%) | ១ |
| | | |
| គប្បីកែប្រែនូវខទាំងឡាយក្នុងកិច្ចសន្យាការងារដែលពុំសមស្រប តាមបទបញ្ជាផ្ទៃក្នុង។ | ១ (២%) | 0 |
| | | |
| គប្បីធានាឱ្យប្រាកដថា កម្មករនិយោជិតបានយល់ដឹងអំពីខ្លឹមសារ និងល័ក្ខខ័ណ្ឌការងារនៃកិច្ចសន្យាការងាររបស់ខ្លួន។ | ៣៥ (៧0%)<br>១ C (២%) | 0 |
| | | |
| គប្បីធានាឱ្យប្រាកដថា កិច្ចសន្យាសំរាប់រយៈពេលសាកល្បងការងារមិនត្រូវលើសពី ៣ ខែឡើយ។ | ១២ (២៤%) | 0 |
| | | |
| គប្បីធានាឱ្យប្រាកដថាកិច្ចសន្យាកូនជាង អនុលោមតាមច្បាប់។ | ៨ (១៦%) | 0 |
| | | |
| គប្បីធានាឱ្យប្រាកដថាកិច្ចសន្យាហាត់ការមានរយៈពេលមិនលើស ២ ខែឡើយ។ | ៣ (៦%) | 0 |
| | | |
| ពុំគប្បីដូរកិច្ចសន្យាការងារតាមទំនើងចិត្ត (ឧទាហរណ៍ ពីពេញសិទ្ធិទៅជាសាកល្បង)។ | ៤ (៨%) | 0 |
| | | |
| គប្បីធានាឱ្យប្រាកដថា កម្មករនិយោជិតម្តងម្កាលត្រូវបាន | ១៨ (៣៦%) | ១ |

| អ្នកគ្រប់គ្រង | ចំនួននិងភាគរយនៃរោងចក្រដែលមានសំណួមពរចំពោះបញ្ហានេះ (មិនអនុវត្ត) | ចំនួននៃរោងចក្រដែលធ្វើឱ្យល័ក្ខខ័ណ្ឌការងារប្រសើរភ្លាមៗមុននឹងរបាយការណ៍ឃ្លាំមើលសំរេចជាស្ថាពរ |
|---|---|---|
| ជ្រើសរើសសំរាប់តែការងារជាក់លាក់ណាមួយដែលមានរយៈពេលខ្លីតែប៉ុណ្ណោះ ។ | | |
| | | |
| គប្បីធានាឱ្យមានការជូនដំណឹងមានរយៈពេលត្រឹមត្រូវមុននឹងបញ្ឈប់កម្មករនិយោជិតពីការងារ ។ | ១ (២%) | 0 |
| | | |
| គប្បីអនុវត្តតាមនីតិវិធីនៃច្បាប់ក្នុងករណីមានការបញ្ចប់កិច្ចសន្យារបស់កម្មករនិយោជិត ។ | ៤ (៨%) | 0 |
| | | |
| គប្បីធានាឱ្យមានការបង់ប្រាក់សងជំងឺចិត្ត និង ប្រាក់បំណាច់ត្រឹមត្រូវចំពោះករណីនៃការបញ្ឈប់ពីការងារ ។ | ៥ (១០%) | 0 |
| | | |
| ពុំគប្បីកាត់ប្រាក់ឈ្នួលពីកូនជាង និង/ឬក៏កម្មករសាកល្បងដែលពុំបានជូនដំណឹងមុនពេល ដែលពួកគេលាឈប់ពីការងារ ។ | ៣ (៦%) | 0 |
| | | |
| គប្បីធានាឱ្យមានការបង់ប្រាក់សងជំងឺចិត្ត ចំពោះករណីគ្មានមូលហេតុសុពលត្រឹមត្រូវក្នុងការបញ្ឈប់កម្មករនិយោជិត ពីការងារដោយនិយោជក ។ | ៣ (៦%) | 0 |
| | | |
| គប្បីផ្តល់ដល់កម្មករនិយោជិត នូវការឈប់សំរាកប្រចាំឆ្នាំក្នុងខណៈពេលដែលពួកគេសុំលាលែងពីការងារ ឬ ពួកគេត្រូវបានបញ្ឈប់ពីការងារ ។ | ១១ (២២%) | 0 |
| | | |
| គប្បីជូនដំណឹងដល់ កកបវ មុននឹងព្យួរកិច្ចសន្យាការងាររបស់កម្មករនិយោជិតដោយហេតុផលសេដ្ឋកិច្ចនោះ ។ | ២ (៤%) | 0 |

### ២.១.៣ អនុសញ្ញារួម

ច្បាប់ ( មាត្រា ៩៦-៩៨ ប្រកាស ២៨៧/០១ និង ៣០៥/០១):

អនុសញ្ញារួម គឺជាកិច្ចព្រមព្រៀងជាលាយល័ក្ខណ៍អក្សរ មានគោលបំណងកំណត់ល័ក្ខខ័ណ្ឌការងារ និង មុខរបររបស់កម្មករនិយោជិត និងគ្រប់គ្រងទំនាក់ទំនងរវាងកម្មករនិយោជក និង កម្មករនិយោជិត ។ និយោជកអាចធ្វើអនុសញ្ញារួមជាមួយនឹងអង្គការសហជីពមួយ ឬ ច្រើនដែលមានភាពជាតំណាង។ បើគ្មានសហជីពទេ អនុសញ្ញារួមអាចធ្វើឡើងរវាងនិយោជក និងប្រតិភូបុគ្គលិកដែលបានបោះឆ្នោតជ្រើសរើសត្រឹមត្រូវ ។ ប្រការទាំងឡាយនៃអនុសញ្ញារួមអាចផ្តល់ដល់កម្មករនិយោជិត នូវផលប្រយោជន៍បានប្រសើរជាងច្បាប់ ប៉ុន្តែប្រការទាំងឡាយដែលផ្តល់ដល់កម្មករនិយោជិត នូវផលប្រយោជន៍តិចជាងច្បាប់ មិនត្រូវយកមកអនុវត្តឡើយ ។ អនុសញ្ញារួមត្រូវធ្វើជាភាសាខ្មែររួចត្រូវបានចុះបញ្ជីត្រឹមត្រូវ ជាមួយក្រសួងការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ ហើយត្រូវបិទនៅទូទាំងគ្រឹះស្ថាន ។

**សំណូមពរដែលលើកឡើងសំរាប់រោងចក្រ :**

| អ្នកគ្រប់គ្រង | ចំនួននិងភាគរយនៃរោងចក្រដែលមានសំណូមពរចំពោះបញ្ហានេះ (មិនអនុវត្ត) | ចំនួននៃរោងចក្រដែលធ្វើឱ្យល័ក្ខខ័ណ្ឌការងារប្រសើរភ្លាមៗមុននឹងរបាយការណ៍ឃ្លាំមើលសំរេចជាស្ថាពរ |
|---|---|---|
| គប្បីធានាឱ្យប្រាកដថា អនុសញ្ញារួមត្រូវស្របទៅតាមច្បាប់។ | ១ (២%) | 0 |
| | | |
| គប្បីអនុវត្តអនុសញ្ញារួម។ | ១ (២%) | 0 |

### ២.១.៤ ប្រាក់ឈ្នួល

ច្បាប់ ( មាត្រា ២៨ ៣៩ ៤១ ១០២ ១១៩ ១២៧ ១៣៩ និង ១៦៣ ប្រកាស ១០/៩៩ ៨០/៩៩ ២៦៩/០១ និង ១០០/០២ សារាចរ ០២៤/៩៩ និង សេចក្តីជូនដំណឹង ០៦/៩៧ និង ០១៧/០០):

ពាក្យថា "ប្រាក់ឈ្នួល" មានន័យថា ការទូទាត់ប្រាក់ដល់កម្មករនិយោជិតម្នាក់ ដោយនិយោជក សំរាប់ឈ្នួលការងារដែលបានបំពេញ ។ ប្រាក់ឈ្នួលមានជាអាទិ៍: ប្រាក់ឈ្នួលសុទ្ធសាធ ប្រាក់ម៉ោងបន្ថែម ប្រាក់រង្វាន់នានា វិភាជន៍សំរាប់ថ្ងៃឈប់សំរាក និង វិភាជន៍សំរាប់ពេលលំហែមាតុភាព ។ កម្មករនិយោជិត ត្រូវទទួលប្រាក់ឈ្នួលអប្បបរមាដែលត្រូវបានធានា ។ កិច្ចព្រមព្រៀងណាមួយដែលតំរូវឱ្យប្រាក់ឈ្នួលទៅកម្មករនិយោជិត ដោយអត្រាទាបជាងប្រាក់ឈ្នួលអប្បបរមាដែលត្រូវបានធានា ត្រូវទុកជាមោឃៈ។ ចំពោះការងារតាមបរិមាណផលិតផល (ដេរស៊ីប៉ុង) បរិមាណផលិតផល ត្រូវតែយ៉ាងណាឱ្យកម្មករនិយោជិត មានការប៉ិនប្រសប់ជាមធ្យមធ្វើការក្នុងថិរវេលាធម្មតាអាចទទួលបាននូវប្រាក់ឈ្នួលអប្បបរមា ។ ពត៌មានអំពីប្រាក់ឈ្នួលអប្បបរមាដែលកំរិតឡើងដោយច្បាប់នេះ ត្រូវបិទផ្សាយជាអចិន្ត្រៃយ៍នៅក្នុងបន្ទប់ធ្វើការក្នុងការិយាល័យបើកប្រាក់ និង នៅទីទទួលឱ្យធ្វើការ។

ប្រាក់ឈ្នួលអប្បបរមាកំណត់សំរាប់កម្មករនិយោជិតក្នុងវិស័យកាត់ដេរគឺ ៤៥[1] ដុល្លាអាមេរិកចំពោះកម្មករនិយោជិតជាប់លាប់ ៤០ ដុល្លាអាមេរិកចំពោះកម្មករនិយោជិតសាកល្បង និង ៣០ ដុល្លាអាមេរិកចំពោះកូនជាង ។ ចំពោះកម្មករនិយោជិតដែលឱ្យប្រាក់ឈ្នួលតាមបរិមាណផលិតផល (ដេរស៊ីបុង) ទទួលបានទាបជាង ៤៥ ដុល្លាអាមេរិកក្នុងមួយខែ និយោជកត្រូវបន្ថែមឱ្យគ្រប់តាមកំរិតប្រាក់ឈ្នួលអប្បបរមា ។ កម្មករនិយោជិតដែលធ្វើការទៀងទាត់នៃចំនួនថ្ងៃដែលត្រូវធ្វើការក្នុងមួយខែៗនោះ ត្រូវបានប្រាក់រង្វាន់ ៥ ដុល្លាអាមេរិកក្នុងមួយខែ ។ កម្មករនិយោជិតដែលបានបំរើការងារនៅរោងចក្រដដែលបានរយៈពេលមួយឆ្នាំឡើងទៅ គប្បីត្រូវទទួលបានប្រាក់រង្វាន់អតីតភាពការងារចំនួន ២ ដុល្លាអាមេរិកក្នុងមួយខែ ។ អត្រាប្រាក់បន្ថែមម៉ោងក្នុងថ្ងៃធ្វើការធម្មតា ស្មើនឹង ១,៥ ដងនៃប្រាក់ឈ្នួលថ្ងៃធម្មតា ។ ប្រាក់ធ្វើការថ្ងៃអាទិត្យ និងថ្ងៃបុណ្យ ត្រូវផ្តល់ស្មើនឹង ២ ដងនៃប្រាក់ឈ្នួលធម្មតា ។ ការងារពេលយប់ ( ចាប់ពីម៉ោង ២២:០០ ទៅម៉ោង ៥:០០ភ្លឺ ) គឺត្រូវផ្តល់ប្រាក់ឈ្នួលចំនួន ២ ដង នៃប្រាក់ឈ្នួលពេលធ្វើការធម្មតា ។ កម្មករនិយោជិតដែលធ្វើការបន្ថែមម៉ោង ត្រូវទទួលបានប្រាក់ថ្លៃបាយចំនួន ១០០០រៀល ឬ ទទួលបានការផ្តល់ជូនបាយមួយពេល ។

និយោជកមិនត្រូវបានអនុញ្ញាតឱ្យដាក់ទណ្ឌកម្មលើកម្មករនិយោជិត ដោយអនុវត្តការផាកពិន័យ ឬ កាត់ប្រាក់ឈ្នួលរបស់កម្មករនិយោជិតនោះទេ ។ និយោជក គប្បីរក្សាសៀវភៅបើកប្រាក់ដែលមានការពិពណ៌នាពិស្តារ និងបើកប្រាក់ឱ្យកម្មករទៀងពេល និង ក្នុងម៉ោងធ្វើការធម្មតា ។

**សំណូមពរដែលលើកឡើងសំរាប់រោងចក្រ :**

| អ្នកគ្រប់គ្រង | ចំនួននិងភាគរយនៃរោងចក្រដែលមានសំណូមពរចំពោះបញ្ហានេះ (មិនអនុវត្ត) | ចំនួននៃរោងចក្រដែលធ្វើឱ្យល័ក្ខខ័ណ្ឌការងារប្រសើរភ្លាមៗមុននឹងរបាយការណ៍ឃ្លាំមើលសំរេចជាស្ថាពរ |
|---|---|---|
| គប្បីធានាឱ្យប្រាកដថាបានបិទសេចក្តីជូនដំណឹងអំពីប្រាក់ឈ្នួលអប្បបរមានៅកន្លែងធ្វើការ ។ | ២៤ (៤៨%) | ៤ |
| | | |
| គប្បីធានាឱ្យប្រាកដថា កម្មករនិយោជិតបានយល់ដឹងអំពីការគិតប្រាក់ឈ្នួលរបស់គេ ។ | ៣៧ (៧៤%) | ១ |
| | | |
| គប្បីផ្តល់ប័ណ្ណបើកប្រាក់ដែលមានសរសេរច្បាស់ត្រឹមត្រូវជូនដល់កម្មករនិយោជិត ។ | ១៤ (២៨%) | ២ |

[1] គ្រប់តួលេខដុល្លាទាំងអស់ គឺជាដុល្លាអាមេរិក

| អ្នកគ្រប់គ្រង | ចំនួននិងភាគរយនៃរោងចក្រដែលមានសំណូមពរចំពោះបញ្ហានេះ (មិនអនុវត្ត) | ចំនួននៃរោងចក្រដែលធ្វើឱ្យល័ក្ខខ័ណ្ឌការងារប្រសើរភ្លាមៗ មុននឹងរបាយការណ៍ឃ្លាំមើលសំរេចជាស្ថាពរ |
|---|---|---|
| គប្បីពន្យល់ដល់កម្មករនិយោជិតនូវផ្នែកដែលបូកបញ្ចូលប្រាក់ឈ្នួលរបស់ខ្លួន និង ខ្លឹមសារនៃប្រាក់ឈ្នួល មុនពេលកម្មករនិយោជិតចាប់ផ្តើមការងារ និង នៅគ្រប់ពេលដែលខ្លឹមសារផ្នែកផ្សេងៗ ឬក៏ ម៉ូដែលមានការផ្លាស់ប្តូរ ។ | ៥ PR (១០%) | 0 |
| | | |
| គប្បីពន្យល់ដល់កម្មករនិយោជិតនូវអត្រាតំលៃសំរាប់ការងារបន្ថែមម៉ោងធម្មតា ការងារពេលយប់ ការងារនៅថ្ងៃអាទិត្យ និង ថ្ងៃឈប់សំរាក ។ | ៣ (៦%) | 0 |
| | | |
| គប្បីកំណត់បរិមាណផលិត(ដេរស៊ីប៉ុង)ក្នុងកំរិតមួយ ដែលលៃយ៉ាងណាឱ្យកម្មករនិយោជិតមានការប៉ិនប្រសប់ ជាមធ្យមធ្វើការក្នុងចិរវេលាធម្មតាអាចទទួលបាន នូវប្រាក់ឈ្នួលអប្បបរមា។ | ៨ (១៦%) | 0 |
| | | |
| គប្បីផ្តល់ដល់កម្មករនិយោជិតដែលដេរស៊ីប៉ុង នូវប្រាក់ឈ្នួលអប្បបរមា នៅពេលដែលប្រាក់ឈ្នួលទទួលបានពីបរិមាណផលិតមានចំនួនតិចជាងប្រាក់ឈ្នួលអប្បបរមា ដោយមិនគិតប្រាក់បន្ថែមម៉ោង។ | ៤ (៨%) | 0 |
| | | |
| គប្បីផ្តល់ដល់កម្មករនិយោជិតដែលដេរស៊ីប៉ុង នូវប្រាក់ឈ្នួលបន្ថែមម៉ោងនៅពេលដែលប្រាក់ឈ្នួល ទទួលបានពីបរិមាណផលិតមានចំនួនច្រើនជាងប្រាក់ឈ្នួលអប្បបរមា ។ | ៣ (៦%) | 0 |
| | | |
| គប្បីផ្តល់ប្រាក់ឈ្នួលដល់កម្មករនិយោជិត ចាប់តាំងពីពេលចាប់ផ្តើមការងារ រួមទាំងពេលធ្វើតេស្តិ៍សាកល្បង ។ | ៩ (១៨%) | ១ |
| | | |
| គប្បីផ្តល់ប្រាក់ឈ្នួលដល់កូនជាងយ៉ាងហោចណាស់ $៣0 ក្នុងមួយខែសំរាប់ការងារម៉ោងធ្វើការធម្មតា ។ | ៥ (១0%) | 0 |

| អ្នកគ្រប់គ្រង | ចំនួននិងភាគរយនៃរោងចក្រដែលមានសំណូមពរចំពោះបញ្ហានេះ (មិនអនុវត្ត) | ចំនួននៃរោងចក្រដែលធ្វើឱ្យល័ក្ខខ័ណ្ឌការងារប្រសើរភ្លាមៗមុននឹងរបាយការណ៍ឃ្លាំមើលសំរេចជាស្ថាពរ |
|---|---|---|
| គប្បីផ្ដល់ប្រាក់ឈ្នួលដល់កម្មករនិយោជិតក្នុងពេលសាកល្បងចំនួន ៤០ ដុល្លាក្នុងមួយខែ សំរាប់ម៉ោងធ្វើការធម្មតា (៨ ម៉ោងក្នុងមួយថ្ងៃ សំរាប់ ២៦ ថ្ងៃក្នុងមួយខែ ដោយមិនរួមបញ្ចូលនូវម៉ោងបន្ថែមការងារនៅថ្ងៃអាទិត្យ ការងារនៅថ្ងៃឈប់សំរាក ឬក៏នៅពេលយប់) ។ | ៥ (១០%) | 0 |
| គប្បីផ្ដល់ប្រាក់ឈ្នួលដល់កម្មករនិយោជិតចំនួន ៤៥ ដុល្លា ក្នុងមួយខែសំរាប់ម៉ោងធ្វើការធម្មតា ។ | ៥ (១០%) | 0 |
| គប្បីផ្ដល់ប្រាក់ឈ្នួលដល់កម្មករនិយោជិតម្ដងម្កាលចំនួន ៤៥ដុល្លាក្នុងមួយខែសំរាប់ម៉ោងធ្វើការធម្មតា ។ | ២១ C (៤២%) | 0 |
| គប្បីផ្ដល់ប្រាក់ឈ្នួល ១៥០ ភាគរយនៃប្រាក់ឈ្នួលធម្មតា ដល់កម្មករនិយោជិតសំរាប់ការងារបន្ថែមម៉ោង ដែលបានធ្វើនៅថ្ងៃធ្វើការធម្មតាមុនម៉ោង ២២:00 ។ | ៧ (១៤%)<br>៦ C (១២%)<br>១ PR (២%) | 0 |
| គប្បីផ្ដល់ប្រាក់ឈ្នួលទ្វេជាពីរនៃប្រាក់ឈ្នួលធម្មតា ដល់កម្មករនិយោជិតសំរាប់ការងារនៅចំពេលការឈប់សំរាកប្រចាំសប្ដាហ៍ (ថ្ងៃអាទិត្យ) ។ | ៦ (១២%)<br>១ C (២%)<br>១ PR (២%) | 0 |
| គប្បីផ្ដល់ប្រាក់ឈ្នួលដល់កម្មករនិយោជិត ដែលធ្វើការងារចំថ្ងៃឈប់សំរាក នូវប្រាក់ឈ្នួលមួយថ្ងៃ (បន្ថែមលើប្រាក់ឈ្នួលប្រចាំថ្ងៃធម្មតា) ។ | ៥ (១០%)<br>១ C (២%)<br>១ PR (២%) | 0 |
| គប្បីផ្ដល់ប្រាក់ឈ្នួលដល់កម្មករនិយោជិត នូវប្រាក់ឈ្នួលប្រចាំថ្ងៃសំរាប់ថ្ងៃឈប់សំរាកបុណ្យ ។ | ២ (៤%)<br>៤ C (៨%)<br>២ PR (៤%) | 0 |

| អ្នកគ្រប់គ្រង | ចំនួននិងភាគរយនៃរោងចក្រដែលមានសំណួមពរចំពោះបញ្ហានេះ (មិនអនុវត្ត) | ចំនួននៃរោងចក្រដែលធ្វើឱ្យល័ក្ខខ័ណ្ឌការងារប្រសើរភ្លាមៗមុននឹងរបាយការណ៍ឃ្លាំមើលសំរេចជាស្ថាពរ |
|---|---|---|
| គប្បីផ្តល់ប្រាក់ឈ្នួលទ្វេជាពីរនៃប្រាក់ឈ្នួលធម្មតាដល់កម្មករនិយោជិត សំរាប់ការងារពេលយប់ ។ | ៨(១៦%) | 0 |
| | | |
| គប្បីផ្តល់ប្រាក់ ១000 រៀលម្នាក់ ដល់កម្មករគ្រប់រូបសំរាប់ថ្លៃបាយ ឬ ផ្តល់អាហារសំរាប់ការងារបន្ថែមម៉ោង ។ | ៧ (១៤%)<br>៦ C (១២%) | 0 |
| | | |
| គប្បីផ្តល់ដល់កម្មករនិយោជិតទាំងឡាយណា ដែលធ្វើការជាទៀងទាត់នូវប្រាក់រង្វាន់ធ្វើការទៀងទាត់ចំនួន ៥ ដុល្លាអាមេរិកក្នុងមួយខែ ។ | ៨ (១៦%)<br>១៣ C (២៦%)<br>១ PW (២%)<br>១ A (២%) | 0 |
| | | |
| គប្បីផ្តល់ដល់កម្មករនិយោជិតទាំងអស់ នូវប្រាក់រង្វាន់អតីតភាពការងារបន្ទាប់ពីបំរើការងារបានមួយឆ្នាំ ។ | ៦ (១២%) | 0 |
| | | |
| ពុំគប្បីអនុវត្តការផាកពិន័យ ឬ កាត់ប្រាក់ឈ្នួលរបស់កម្មករនិយោជិតនោះទេ ។ | ១៣ (២៦%) | 0 |
| | | |
| ពុំគប្បីដាក់ពិន័យប្រាក់ឈ្នួល ឬ កាត់ប្រាក់ឈ្នួលពីកម្មករនិយោជិត ដែលមិនធ្វើការបន្ថែមម៉ោង ធ្វើការនៅថ្ងៃអាទិត្យ ឬក៏ថ្ងៃបុណ្យ ។ | ១ (២%) | 0 |
| | | |
| ពុំគប្បីកាត់ប្រាក់ឈ្នួល សំរាប់អវត្តមានដោយគ្មានការអនុញ្ញាតត្រឹមត្រូវ លើសពីប្រាក់ឈ្នួលគោលប្រចាំថ្ងៃ ។ | ២ (៤%) | ១ |
| | | |
| ពុំគប្បីកាត់បន្ថយប្រាក់ឈ្នួលពីកម្មករនិយោជិត ឱ្យលើសពីតំលៃប័ណ្ណសំគាល់ខ្លួន ឬ ឧបករណ៍ផ្សេងទៀត នៅពេលដូរឱ្យកម្មករនិយោជិតនូវប័ណ្ណសំគាល់ និង ឧបករណ៍ទាំងនោះរបស់គេដែលបានបាត់ ។ | ២0 (៤0%) | ១ |

| អ្នកគ្រប់គ្រង | ចំនួននិងភាគរយនៃរោងចក្រដែលមានសំណូមពរចំពោះបញ្ហានេះ (មិនអនុវត្ត) | ចំនួននៃរោងចក្រដែលធ្វើឱ្យល័ក្ខខ័ណ្ឌការងារប្រសើរភ្លាមៗមុននឹងរបាយការណ៍ឃ្លាំមើលសំរេចជាស្ថាពរ |
|---|---|---|
| គប្បីរក្សាសៀវភៅបើកប្រាក់ ដែលមានការពិពណ៌នា ពិស្តារជាភាសាខ្មែរ ដើម្បីឱ្យងាយយល់ ។ | ៩ (១៨%) | ១ |
| | | |
| គប្បីបញ្ចូលថ្ងៃចាប់ផ្តើមធ្វើការរបស់កម្មករនិយោជិត នៅក្នុងសៀវភៅបើកប្រាក់ ។ | ៦ (១២%) | 0 |
| | | |
| គប្បីធានាឱ្យប្រាកដថា សៀវភៅបើកប្រាក់មានបញ្ជាក់ច្បាស់លាស់ នូវប្រាក់ឈ្នួលទាំងអស់/ចំនួនម៉ោងធ្វើការដែលបានបើកឱ្យកម្មករនិយោជិត។ | ៤ (៨%) | 0 |
| | | |
| គប្បីកែតម្រូវការទូទាត់ប្រាក់ឈ្នួលឱ្យកម្មករនិយោជិតឱ្យបានត្រឹមត្រូវ ។ | ១ (២%) | 0 |
| | | |
| គប្បីផ្តល់ប្រាក់ឈ្នួលដល់កម្មករនិយោជិតឱ្យបានទាន់ពេលវេលា ។ | ៤ (៨%) | 0 |
| | | |
| គប្បីបើកប្រាក់ឈ្នួលដល់កម្មករនិយោជិត ក្នុងអំឡុងពេលម៉ោងធ្វើការធម្មតា។ | ១៧ (៣៤%) | 0 |
| | | |
| គប្បីបើកប្រាក់ឈ្នួលដល់កម្មករនិយោជិតមួយថ្ងៃមុនពេលដែលថ្ងៃបើកប្រាក់ចំថ្ងៃឈប់សំរាក(ដូចជាថ្ងៃអាទិត្យ ឬថ្ងៃបុណ្យ) ។ | ៣ (៦%) | 0 |
| | | |
| គប្បីបើកប្រាក់ឈ្នួលដល់កម្មករនិយោជិតដែលត្រូវបញ្ឈប់ពីការងារនូវប្រាក់ឈ្នួល និងប្រាក់សងជំងឺចិត្តផ្សេងៗទៀត ក្នុងកំឡុងពេល ៤៨ ម៉ោងបន្ទាប់ពីកម្មករ និយោជិតនោះត្រូវបញ្ឈប់ពីការងារ ។ | ៤ (៨%) | 0 |

| អ្នកគ្រប់គ្រង | ចំនួននិងភាគរយនៃរោងចក្រដែលមានសំណូមពរចំពោះបញ្ហានេះ (មិនអនុវត្ត) | ចំនួននៃរោងចក្រដែលធ្វើឱ្យល័ក្ខខ័ណ្ឌការងារប្រសើរភ្លាមៗ មុននឹងរបាយការណ៍ឃ្លាំមើលសំរេចជាស្ថាពរ |
|---|---|---|
| គប្បីផ្តល់ដល់កម្មករនិយោជិតនូវអត្រាប្តូរប្រាក់ត្រឹមត្រូវ ពេលដែលប្តូរប្រាក់ឈ្នួលរបស់កម្មករនិយោជិតពី ប្រាក់ដុល្លាទៅជាប្រាក់រៀល ។ | ១ (២%) | 0 |

## ២.១.៥ សោហ៊ុយធ្វើដំណើរត្រឡប់

ច្បាប់ (មាត្រា ១៨៨) :

កម្មករនិយោជិតទាំងអស់ ដែលត្រូវជ្រើសរើសឆ្ងាយពីកន្លែងធ្វើការ និយោជកត្រូវចេញប្រាក់សំរាប់ការធ្វើដំណើររបស់គាត់មកកាន់ទីកន្លែងធ្វើការ ហើយពេលចប់កិច្ចសន្យា ត្រូវមានសិទ្ធិទទួលបានសោហ៊ុយធ្វើដំណើរត្រឡប់ទៅទីកន្លែងដែលគេជ្រើសរើសនោះវិញ ។ សោហ៊ុយនេះត្រូវជាបន្ទុករបស់និយោជក ។

**សំណូមពរដែលលើកឡើងសំរាប់រោងចក្រ :** ពុំមាន

## ២.១.៦ ថិរវេលាធ្វើការ

ច្បាប់ (មាត្រា ១៣៧ ១៣៩ ១៤០ ១៤១ ១៤៤ ១៤៧ និង ១៦០ ប្រកាស ១០/៩៩ ៨០/៩៩ និង ១០០/០២ សេចក្តីជូនដំណឹង 00៤/00) :

ថិរវេលាធ្វើការពេញលេញនៃកម្មករនិយោជិតទាំងពីរភេទ មិនត្រូវឱ្យលើសពីប្រាំបីម៉ោងក្នុងមួយថ្ងៃ ឬ ៤៨ ម៉ោងក្នុងមួយសប្តាហ៍ឡើយ ។ និយោជកអាចរៀបចំឱ្យធ្វើការបន្ថែមម៉ោង ចំពោះតែការងារពិសេស និងបន្ទាន់ប៉ុណ្ណោះ ហើយនិយោជកត្រូវទទួលការអនុញ្ញាតពីអធិការការងារ មុននឹងកម្មករនិយោជិតចាប់ផ្តើមធ្វើការបន្ថែមម៉ោង ។ ការបន្ថែមម៉ោង គឺត្រូវអនុវត្តតាមការស្ម័គ្រចិត្ត ហើយកម្មករនិយោជិតមិនត្រូវទទួលទោសពៃរ៍អ្វីឡើយ ចំពោះការបដិសេធមិនព្រមធ្វើការបន្ថែមម៉ោង ។ ការធ្វើការបន្ថែមម៉ោងដែលអនុវត្តបច្ចុប្បន្ន គឺដើម្បីឱ្យ កកបវ ក៏រិតការបន្ថែមម៉ោង មិនត្រូវឱ្យលើសពីពីរម៉ោងក្នុងមួយថ្ងៃ ពេលផ្តល់ការអនុញ្ញាតឱ្យធ្វើការបន្ថែមម៉ោង ។ និយោជក ត្រូវផ្តល់នូវមធ្យោបាយដឹកជញ្ជូន ដល់កម្មករនិយោជិតដែលបញ្ចប់ការងារពេលយប់ (គិតចាប់ពីចន្លោះម៉ោង ២២:00 និង ម៉ោង ៥:00 ភ្លឺ) បើអ្នកគ្រប់គ្រងមិនបានផ្តល់កន្លែងសំរាប់គេងឱ្យពួកគេទេនោះ ។ កម្មករនិយោជិត ត្រូវទទួលបានការឈប់សំរាកដែលមានថិរវេលាអប្បបរមា ២៤ ម៉ោង បន្តបន្ទាប់គ្នារៀងរាល់សប្តាហ៍ ជាទូទៅនៅថ្ងៃអាទិត្យ ។

សំណូមពរដែលលើកឡើងសំរាប់រោងចក្រ ៖

| អ្នកគ្រប់គ្រង | ចំនួននិងភាគរយនៃរោងចក្រដែលមានសំណូមពរចំពោះបញ្ហានេះ (មិនអនុវត្ត) | ចំនួននៃរោងចក្រដែលធ្វើឱ្យល័ក្ខខ័ណ្ឌការងារប្រសើរភ្លាមៗមុននឹងរបាយការណ៍ឃ្លាំមើលសំរេចជាស្ថាពរ |
|---|---|---|
| គប្បីធានាឱ្យប្រាកដថា កូនជាងត្រូវបានធ្វើការចំនួនតែ ៦ ម៉ោងក្នុងមួយថ្ងៃ និង ៥ ថ្ងៃក្នុងមួយសប្តាហ៍ ។ | ៥ (១០%) | 0 |
| | | |
| គប្បីផ្តល់ដល់កម្មករនិយោជិតនូវការឈប់សំរាកប្រចាំសប្តាហ៍ ។ | ៤ (៨%) | 0 |
| | | |
| គប្បីធានាឱ្យប្រាកដថា ការធ្វើការនៅថ្ងៃអាទិត្យ អនុវត្តតាមការស្ម័គ្រចិត្ត ។ | ១១ (២២%) | 0 |
| | | |
| គប្បីធានាឱ្យប្រាកដថា ការធ្វើការនៅថ្ងៃអាទិត្យពុំត្រូវបានធ្វើឡើងជាញឹកញាប់ ។ | ៥ (១០%) | 0 |
| | | |
| គប្បីធានាឱ្យប្រាកដថា ការធ្វើការនៅថ្ងៃបុណ្យអនុវត្តតាមការស្ម័គ្រចិត្ត ។ | ៩ (១៨%) | ១ |
| | | |
| គប្បីធានាឱ្យប្រាកដថា ការធ្វើការនៅថ្ងៃបុណ្យពុំត្រូវបានធ្វើឡើងជាញឹកញាប់ ។ | ៦ (១២%) | 0 |
| | | |
| គប្បីធានាឱ្យប្រាកដថា ការធ្វើការបន្ថែមម៉ោងអនុវត្តតាមការស្ម័គ្រចិត្ត ។ | ៣២ (៦៤%) | ១ |
| | | |
| គប្បីធានាឱ្យប្រាកដថា ការធ្វើការបន្ថែមម៉ោង ពុំត្រូវបានធ្វើឡើងជាញឹកញាប់ ។ | ៣៦ (៧២%) | 0 |
| | | |
| គប្បីធានាឱ្យប្រាកដថា ការធ្វើការបន្ថែមម៉ោង ពុំត្រូវឱ្យលើសពី ២ ម៉ោងក្នុងមួយថ្ងៃ ។ | ៣៤ (៦៨%) | 0 |
| | | |
| ពុំគប្បីធ្វើការដាក់ពិន័យ ដាក់ទណ្ឌកម្ម ដល់កម្មករនិយោជិត | ៥ (១០%) | 0 |

| អ្នកគ្រប់គ្រង | ចំនួននិងភាគរយនៃរោងចក្រដែលមានសំណូមពរចំពោះបញ្ហានេះ (មិនអនុវត្ត) | ចំនួននៃរោងចក្រដែលធ្វើឱ្យល័ក្ខខ័ណ្ឌការងារប្រសើរភ្លាមៗ មុននឹងរបាយការណ៍ឃ្លាំមើលសំរេចជាស្ថាពរ |
|---|---|---|
| ទាំងឡាយណា ដែលពុំព្រមធ្វើការបន្ថែមម៉ោង ឬ ធ្វើការថ្ងៃអាទិត្យ ឬ ថ្ងៃឈប់សំរាកឡើយ ។ | | |
| | | |
| គប្បីផ្តល់នូវមធ្យោបាយដឹកជញ្ជូន ដល់កម្មករនិយោជិតដែលបញ្ចប់ការងារពេលយប់ ឬ ផ្តល់កន្លែងសំរាប់គេងឱ្យពួកគេ ។ | ១៣ (២៦%) | 0 |
| | | |
| គប្បីពិចារណារក្សាការផ្លាស់ប្តូរវេនការងារយ៉ាងហោចណាស់ ២ សប្តាហ៍ម្តង ។ | ១ (២%) | 0 |
| | | |
| គប្បីសុំការអនុញ្ញាត ពី កកបវ មុនពេលឱ្យកម្មករនិយោជិតធ្វើការបន្ថែមម៉ោង ។ | ១៥ (៣0%) | ១ |
| | | |
| គប្បីសុំការអនុញ្ញាតពី កកបវ មុនពេលធ្វើការព្យួរម៉ោងសំរាកប្រចាំសប្តាហ៍ ។ | ២២ (៤៤%) | 0 |
| | | |
| គប្បីបិទផ្សាយការអនុញ្ញាតឱ្យធ្វើការបន្ថែមម៉ោង នៅក្នុងរោងចក្រ ។ | ៤ (៨%) | 0 |

**២.១.៧ ការឈប់សំរាក**

ច្បាប់ (មាត្រា ១៦១ ១៦៦ និង ១៧១ ប្រកាស ២៦៧/០១) :

រៀងរាល់ឆ្នាំ ក្រសួងការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ (កកបវ) ចេញប្រកាសកំណត់ថ្ងៃបុណ្យ ដែលត្រូវឈប់មានប្រាក់ឈ្នួលសំរាប់កម្មករនិយោជិតនៃសហគ្រាសទាំងអស់ ហើយនិយោជកត្រូវបិទផ្សព្វផ្សាយនៅគ្រឹះស្ថានធ្វើការ ។ កម្មករនិយោជិតទាំងអស់ ត្រូវមានសិទ្ធិឈប់សំរាកប្រចាំឆ្នាំ ដោយគិតជាថ្ងៃធ្វើការធម្មតា ចំនួនមួយថ្ងៃកន្លះក្នុងរយៈពេលធ្វើការមួយខែជាប់ ពោលគឺ ១៨ ថ្ងៃ ក្នុងមួយឆ្នាំ ។ កម្មករនិយោជិតត្រូវប្រើប្រាស់ការឈប់សំរាកដែលមានប្រាក់ឈ្នួលរបស់ខ្លួន បន្ទាប់ពីបំរើការបានមួយឆ្នាំ ។ កម្មករនិយោជិតដែលបំរើការងារបាន ៣ ឆ្នាំ ត្រូវទទួលបានការឈប់សំរាកប្រចាំឆ្នាំបន្ថែមមួយថ្ងៃទៀត ។ និយោជកមានសិទ្ធិអនុញ្ញាតច្បាប់ឱ្យកម្មករនិយោជិតឈប់សំរាក

រហូតដល់ ៧ ថ្ងៃ សំរាប់ការឈប់សំរាកពិសេស ក្នុងឱកាសមានព្រឹត្តិកាណ៍ប៉ះពាល់ដល់កម្មករនិយោជិត ឬ ដល់គ្រួសារផ្ទាល់របស់កម្មករនិយោជិត មានជាអាទិ៍ ការរៀបអាពាហ៍ពិពាហ៍ផ្ទាល់ខ្លួន ប្រពន្ធសំរាលកូន រៀបអាពាហ៍ពិពាហ៍កូន ពេលប្តី ប្រពន្ធ កូន ឪពុក ម្តាយ មានជំងឺ ឬ ទទួលមរណៈភាព ។ បើកម្មករនិយោជិត ពុំទាន់បានអនុវត្តការឈប់សំរាកប្រចាំឆ្នាំអស់ទេ នោះនិយោជកអាចធ្វើការកាត់កងការឈប់សំរាកពិសេសនេះ ពីថ្ងៃឈប់សំរាកប្រចាំឆ្នាំរបស់កម្មករនិយោជិតបាន ។ កម្មករនិយោជិតមានសិទ្ធិឈប់សំរាកពេលមានជំងឺ ។ ការអនុវត្តន៏របស់ កកបវ គឺតម្រូវឱ្យនិយោជកផ្តល់ប្រាក់ឈ្នួលដល់កម្មករនិយោជិត នៅពេលឈប់ដោយមានជំងឺ តាមរយៈបទបញ្ជាផ្ទៃក្នុងរបស់រោងចក្រ ។

**សំណូមពរដែលលើកឡើងសំរាប់រោងចក្រ :**

| អ្នកគ្រប់គ្រង | ចំនួននិងភាគរយនៃរោងចក្រដែលមានសំណូមពរចំពោះបញ្ហានេះ (មិនអនុវត្ត) | ចំនួននៃរោងចក្រដែលធ្វើឱ្យល័ក្ខខ័ណ្ឌការងារប្រសើរភ្លាមៗ មុននឹងរបាយការណ៍ឃ្លាំមើលសំរេចជាស្ថាពរ |
|---|---|---|
| គប្បីបិទផ្សាយកាលវិភាគថ្ងៃឈប់សំរាកផ្លូវការនៅរោងចក្រ។ | ៨ (១៦%) | ២ |
| | | |
| គប្បីផ្តល់ដល់កម្មករនិយោជិត នូវការឈប់សំរាកប្រចាំឆ្នាំ ចំនួន ១៨ ថ្ងៃរៀងរាល់ឆ្នាំ ។ | ៩ (១៨%) | 0 |
| | | |
| គប្បីធានាឱ្យប្រាកដថា កម្មករនិយោជិតទាំងអស់ទទួលការឈប់សំរាកប្រចាំឆ្នាំ ដោយគ្មានការដាក់កម្រិតជ្រុលហួសហេតុ។ | ៦ (១២%) | 0 |
| | | |
| គប្បីផ្តល់ប្រាក់ឈ្នួលដល់កម្មករនិយោជិត នូវប្រាក់ឈ្នួលប្រចាំថ្ងៃធម្មតា រួមទាំងប្រាក់រង្វាន់ផ្សេងទៀតសំរាប់ការឈប់សំរាកប្រចាំឆ្នាំ មុនពេលកម្មករនិយោជិត ធ្វើការឈប់សំរាកប្រចាំឆ្នាំ ។ | ៥ (១០%) | 0 |
| | | |
| ពុំគប្បីកាត់ប្រាក់រង្វាន់ទៀងទាត់ចំនួន $៥ ពេលកម្មករនិយោជិតធ្វើការឈប់សំរាកប្រចាំឆ្នាំនោះទេ ។ | ១ (២%) | 0 |
| | | |
| គប្បីទទួលការយល់ព្រមពីកម្មករនិយោជិតក្នុងការទូទាត់ការឈប់សំរាកប្រចាំឆ្នាំជាប្រាក់បំណាច់។ | ៣ (៦%) | 0 |
| | | |
| គប្បីផ្តល់នូវការឈប់សំរាកប្រចាំឆ្នាំបន្ថែមមួយថ្ងៃទៀតដល់កម្មករនិយោជិតដែលបំរើការងារបាន ៣ ឆ្នាំ។ | ៦ (១២%) | 0 |

| អ្នកគ្រប់គ្រង | ចំនួននិងភាគរយនៃរោងចក្រដែលមានសំណូមពរចំពោះបញ្ហានេះ (មិនអនុវត្ត) | ចំនួននៃរោងចក្រដែលធ្វើឱ្យល័ក្ខខ័ណ្ឌការងារប្រសើរភ្លាមៗ មុននឹងរបាយការណ៍ឃ្លាំមើលសំរេចជាស្ថាពរ |
|---|---|---|
| គប្បីពិចារណារៀបចំ ឬ កែប្រែបទបញ្ជាផ្ទៃក្នុង ដើម្បីផ្តល់ដល់កម្មករនិយោជិតនូវការឈប់សំរាកឈឺដោយមានប្រាក់ឈ្នួលចំពោះជំងឺណា មានការបញ្ជាក់ត្រឹមត្រូវពីគ្រូពេទ្យផ្លូវការ ដូចខាងក្រោម :<br>♦ ប្រាក់ឈ្នួល ១០០ ភាគរយសំរាប់ខែទី ១ ។<br>♦ ប្រាក់ឈ្នួល ៦០ ភាគរយ សំរាប់ខែទី ២ ។<br>♦ ប្រាក់ឈ្នួល ៤០ ភាគរយ សំរាប់ខែទី ៣ ។<br>♦ គ្មានប្រាក់ឈ្នួលចាប់ពីខែទី ៤ដល់ខែទី ៦ ។ | ៣២ (៦៤%) | ១ |
| | | |
| គប្បីផ្តល់ដល់កម្មករនិយោជិត នូវការឈប់សំរាកឈឺដោយមានប្រាក់ឈ្នួល ដែលតំរូវដោយបទបញ្ជាផ្ទៃក្នុងរបស់រោងចក្រ ។ | ៩ (១៨%)<br>១ PR (២%) | 0 |
| | | |
| ពុំគប្បីដាក់កម្រិតជ្រុលហួសហេតុលើកម្មករនិយោជិត ក្នុងការសុំការឈប់សំរាកដោយជំងឺ ។ | ១០ (២០%) | 0 |
| | | |
| គប្បីពិចារណាផ្តល់ការឈប់សំរាកពិសេសរហូតដល់ ៧ ថ្ងៃក្នុងមួយឆ្នាំដល់កម្មករនិយោជិតសំរាប់ព្រឹត្តិការណ៍ ទាក់ទងនឹងកម្មករនិយោជិត ឬ ក្រុមគ្រួសារ ។ | ៣៥ (៧០%)<br>១ PR (២%) | ១ |
| | | |
| គប្បីអនុញ្ញាតឱ្យកម្មករនិយោជិតទទួលបានការសំរាកពិសេសសំរាប់ព្រឹត្តិការណ៍ទាក់ទងនឹងកម្មករនិយោជិត ឬ ក្រុមគ្រួសាររួមមាន អាពាហ៍ពិពាហ៍របស់កម្មករនិយោជិត គ្រួសារប្រសូត្របុត្រ ជំងឺ ឬ មរណភាពរបស់ក្រុមគ្រួសារកម្មករនិយោជិត ព្រមទាំង អាពាហ៍ពិពាហ៍កូន របស់កម្មករនិយោជិត ។ | ៨ (១៦%) | 0 |
| | | |
| ពុំគប្បីកាត់បន្ថយប្រាក់រង្វាន់ ៥ ដុល្លា សំរាប់ការមកធ្វើការទៀងទាត់ទេ ពេលដែលកម្មករនិយោជិត ឈប់សំរាកពិសេស ។ | ៧ (១៤%) | 0 |

| អ្នកគ្រប់គ្រង | ចំនួននិងភាគរយនៃរោងចក្រដែលមានសំណូមពរចំពោះបញ្ហានេះ (មិនអនុវត្ត) | ចំនួននៃរោងចក្រដែលធ្វើឱ្យល័ក្ខខ័ណ្ឌការងារប្រសើរភ្លាមៗមុននឹងរបាយការណ៍ឃ្លាំមើលសំរេចជាស្ថាពរ |
|---|---|---|
| ពុំគប្បីដាក់កម្រិតជ្រុលហួសហេតុចំពោះកម្មករនិយោជិតទាំងឡាយណាក្នុងការសុំឈប់សំរាកពិសេស ។ | ៥ (១០%) | 0 |

## ២.១.៨ ការឈប់សំរាកលំហែមាតុភាព

ច្បាប់ (មាត្រា ១៨២ និង ១៨៣) :

ស្ត្រីទាំងឡាយត្រូវមានសិទ្ធិឈប់សំរាកសំរាលកូនចំនួន ៩0 ថ្ងៃ ។ ចំពោះស្ត្រីទូទៅដែលបានបំរើការងារជាប់លាប់យ៉ាងតិចរយៈពេលមួយឆ្នាំ ត្រូវបានប្រាក់ឈ្នួលពាក់កណ្តាល សំរាប់ការឈប់សំរាកលំហែមាតុភាពព្រមទាំងប្រាក់បំណាច់ផ្សេងទៀតមុននឹង ឬ ក្នុងអំឡុងពេលសំរាកសំរាលកូន ។ និយោជកគប្បីប្រាប់ឱ្យកម្មករនិយោជិតបានដឹងនូវសិទ្ធិរបស់ពួកគេក្នុងការទទួលបានការសំរាកលំហែមាតុភាព ។ ឧទាហរណ៍ ស្ត្រីមានកូនខ្ចី ត្រូវបានអនុញ្ញាតឱ្យធ្វើការងារស្រាល ក្នុងអំឡុងពេល ២ ខែដំបូង បន្ទាប់ពីការសំរាកលំហែមាតុភាព។

**សំណូមពរដែលលើកឡើងសំរាប់រោងចក្រ :**

| អ្នកគ្រប់គ្រង | ចំនួននិងភាគរយនៃរោងចក្រដែលមានសំណូមពរចំពោះបញ្ហានេះ (មិនអនុវត្ត) | ចំនួននៃរោងចក្រដែលធ្វើឱ្យល័ក្ខខ័ណ្ឌការងារប្រសើរភ្លាមៗមុននឹងរបាយការណ៍ឃ្លាំមើលសំរេចជាស្ថាពរ |
|---|---|---|
| គប្បីផ្តល់ការឈប់សំរាកលំហែមាតុភាពរយៈពេល ៩0 ថ្ងៃ ជូនដល់កម្មករនិយោជិត ។ | ១ (២%) | 0 |
| | | |
| គប្បីប្រាប់ឱ្យកម្មករនិយោជិតបានដឹង នូវសិទ្ធិរបស់ពួកគេក្នុងការទទួលបានការសំរាកលំហែមាតុភាព ។ | ៦ (១២%) | 0 |
| | | |
| គប្បីផ្តល់នូវប្រាក់ឈ្នួលពាក់កណ្តាល សំរាប់ការឈប់សំរាកលំហែមាតុភាព ដល់កម្មករនិយោជិតណា ដែលធ្វើការបានមួយឆ្នាំព្រមទាំងផ្តល់នូវប្រាក់បំណាច់ផ្សេងទៀត។ | ១៥ (៣0%) | 0 |

| អ្នកគ្រប់គ្រង | ចំនួននិងភាគរយនៃរោងចក្រដែលមានសំណូមពរចំពោះបញ្ហានេះ (មិនអនុវត្ត) | ចំនួននៃរោងចក្រដែលធ្វើឱ្យល័ក្ខខ័ណ្ឌការងារប្រសើរភ្លាមៗមុននឹងរបាយការណ៍ឃ្លាំមើលសំរេចជាស្ថាពរ |
|---|---|---|
| គប្បីធានាឱ្យប្រាកដថា កម្មករនិយោជិតទទួលបានប្រាក់ឈ្នួលសំរាប់ការសំរាកលំហែមាតុភាព មុនពេល ឬ អំឡុងពេលសំរាក។ | ៨ (១៦%) | 0 |
| | | |
| គប្បីធានាឱ្យប្រាកដថា ស្ត្រីមានកូនខ្ចីត្រូវបានអនុញ្ញាតឱ្យធ្វើការងារស្រាលក្នុងអំឡុងពេល ២ ខែដំបូង បន្ទាប់ពីការសំរាកលំហែមាតុភាព។ | ១ (២%) | 0 |

**២.១.៩ <u>ការបំបៅកូន</u>**

ច្បាប់ (មាត្រា ១៨៤):

ក្នុងរយៈពេលមួយឆ្នាំ ចាប់ពីថ្ងៃដែលសំរាលកូនរួច ស្ត្រីដែលឱ្យកូនបៅដោះ អាចបានពេលមួយម៉ោងក្នុងមួយថ្ងៃ ដើម្បីបំបៅកូនខ្លួនក្នុងពេលម៉ោងធ្វើការ ។ រយៈពេលមួយម៉ោងនេះអាចចែកជាពីរវគ្គ ដែលមាន ៣0 នាទីក្នុងមួយវគ្គ គឺនៅពេលធ្វើការព្រឹកម្តង និង នៅពេលធ្វើការរសៀលម្តង ។ និយោជកគប្បីធានាអោយប្រាកដថា ពេលសំរាកមួយម៉ោងក្នុងមួយថ្ងៃ ត្រូវបានប្រាប់ឱ្យម្តាយដែលមានកូនក្នុងអំឡុងពេលមួយឆ្នាំដំបូងបានដឹង ដើម្បីបំបៅកូន ។

**សំណូមពរដែលលើកឡើងសំរាប់រោងចក្រ :**

| អ្នកគ្រប់គ្រង | ចំនួននិងភាគរយនៃរោងចក្រដែលមានសំណូមពរចំពោះបញ្ហានេះ (មិនអនុវត្ត) | ចំនួននៃរោងចក្រដែលធ្វើឱ្យល័ក្ខខ័ណ្ឌការងារប្រសើរភ្លាមៗមុននឹងរបាយការណ៍ឃ្លាំមើលសំរេចជាស្ថាពរ |
|---|---|---|
| គប្បីធានាឱ្យប្រាកដថា ពេលសំរាកបំបៅដោះកូនមួយម៉ោងក្នុងមួយថ្ងៃដោយមានប្រាក់ឈ្នួល ត្រូវបានផ្តល់ឱ្យកម្មករនិយោជិត និងឱ្យពួកគេបានដឹងថាខ្លួនត្រូវទទួលបានសិទ្ធិនេះ សំរាប់ម្តាយដែលមានកូនក្នុងអំឡុងពេលមួយឆ្នាំដំបូង។ | ២៥ (៥0%) | 0 |
| | | |
| គប្បីធានាឱ្យប្រាកដថា ម្តាយដែលមានកូនក្នុងអំឡុងពេលមួយឆ្នាំដំបូង ត្រូវបានទទួលពេលសំរាកមួយម៉ោងក្នុងមួយថ្ងៃដើម្បីបំបៅដោះកូន។ | ១0 (២0%)<br>១ PR (២%) | 0 |

## ២.១.១០ បន្ទប់បំបៅកូន /ទារកដ្ឋាន

ច្បាប់ ( មាត្រា ១៨៦) :

សហគ្រាសទាំងឡាយដែលជួលស្ត្រីយ៉ាងតិចចំនួន ១០០ នាក់ ត្រូវរៀបចំបន្ទប់សំរាប់បំបៅកូនមួយដែលដំណើរការពេញលេញនៅក្នុង ឬ នៅក្បែរគ្រឹះស្ថាន ។ និយោជកក៏ត្រូវបង្កើតឱ្យមានទារកដ្ឋាននៅក្នុង ឬ ផ្តល់នូវថ្លៃឈ្នួលការថែទាំកូននៅទារកដ្ឋានឯកជនដល់កម្មការិនី ។

**សំណូមពរដែលលើកឡើងសំរាប់រោងចក្រ :**

| អ្នកគ្រប់គ្រង | ចំនួននិងភាគរយនៃរោងចក្រដែលមានសំណូមពរចំពោះបញ្ហានេះ (មិនអនុវត្ត) | ចំនួននៃរោងចក្រដែលធ្វើឱ្យល័ក្ខខ័ណ្ឌការងារប្រសើរភ្លាមៗមុននឹងរបាយការណ៍ឃ្លាំមើលសំរេចជាស្ថាពរ |
|---|---|---|
| គប្បីធានាឱ្យប្រាកដថា បន្ទប់បំបៅកូនបើកដំណើរការពេញលេញ។ | ៤៦ (៩២%) | 0 |
| | | |
| គប្បីបង្កើតឱ្យមានទារកដ្ឋាននៅក្នុង ឬ នៅជិតកន្លែងធ្វើការ ឬ ផ្តល់ប្រាក់បំណាច់ដល់កម្មករនិយោជិតនារី នូវថ្លៃឈ្នួលការថែទាំកូននៅទារកដ្ឋានឯកជន។ | ៤៦ (៩២%) | 0 |

## ២.១.១១ ការបៀតបៀនខាងផ្លូវភេទ/តិរិយាបថមិនសមរម្យ

ច្បាប់ ( មាត្រា ១៧២) :

ត្រូវហាមឃាត់យ៉ាងតឹងរ៉ឹង ចំពោះការបៀតបៀនខាងផ្លូវភេទ និង តិរិយាបថមិនសមរម្យ ។

**សំណូមពរដែលលើកឡើងសំរាប់រោងចក្រ :**

ពុំមានឧប្បត្តិហេតុពាក់ព័ន្ធនឹងការបៀតបៀនផ្លូវភេទត្រូវបានរាយការណ៍ថាកើតមានឡើងនោះទេ ។

| អ្នកគ្រប់គ្រង | ចំនួននិងភាគរយនៃរោងចក្រដែលមានសំណូមពរចំពោះបញ្ហានេះ (មិនអនុវត្ត) | ចំនួននៃរោងចក្រដែលធ្វើឱ្យល័ក្ខខ័ណ្ឌការងារប្រសើរភ្លាមៗមុននឹងរបាយការណ៍ឃ្លាំមើលសំរេចជាស្ថាពរ |
|---|---|---|
| ព្រមទាំងមេការ គប្បីប្រព្រឹត្តចំពោះកម្មករនិយោជិត ដោយមានការគោរព។ | ២៩ (៥៨%) | ១ |

### ២.១.១២ ការរើសអើង

ច្បាប់ ( មាត្រា ១២ និង ១៨២ អនុសញ្ញាអង្គការពលកម្មអន្តរជាតិលេខ ១១១) :

គ្មាននិយោជកណាម្នាក់អាចយកបញ្ហាពូជសាសន៍ ភេទ ជំនឿ សាសនា គំនិតនយោបាយ ជាតិកំណើត និង ដើមកំណើតសង្គម ដើម្បីជាលេសធ្វើសេចក្តីសំរេចអំពីការជួល ការកំណត់ និង ការបែងចែកការងារ ការងារបណ្តុះបណ្តាលវិជ្ជាជីវៈ ការតម្លើងឋានៈស័ក្ត ការផ្តល់អត្ថប្រយោជន៍ ការដាក់វិន័យ ឬ ការផ្តាច់កិច្ចសន្យាការងារឡើយ[២] ។ ហេតុដូច្នេះហើយ និយោជកមិនត្រូវបញ្ឈប់ស្ត្រីមានផ្ទៃពោះ ឬ បង្ខំឱ្យពួកគេលាលែងពីការងារឡើយ ។ និយោជកក៏មិនត្រូវបញ្ឈប់កម្មករនិយោជិត ឬផ្លាស់ប្តូរប្រភេទកិច្ចសន្យា/អតីតភាព ក្នុងកំឡុងពេលសំរាកលំហែមាតុភាពនោះទេ។

**សំណូមពរដែលលើកឡើងសំរាប់រោងចក្រ :**

| អ្នកគ្រប់គ្រង | ចំនួននិងភាគរយនៃរោងចក្រដែលមានសំណូមពរចំពោះបញ្ហានេះ (មិនអនុវត្ត) | ចំនួននៃរោងចក្រដែលធ្វើឱ្យល័ក្ខខ័ណ្ឌការងារប្រសើរភ្លាមៗ មុននឹងរបាយការណ៍ឃ្លាំមើលសំរេចជាស្ថាពរ |
|---|---|---|
| ពុំគប្បីបណ្តេញកម្មករនិយោជិតដែលមានផ្ទៃពោះ ឱ្យឈប់ពីការងារ ឬ បង្ខំឱ្យពួកគេលាលែងពីការងារ ។ | ៦ (១២%) | 0 |
| | | |
| ពុំគប្បីបញ្ឈប់កម្មករនិយោជិត ឬ ផ្លាស់ប្តូរប្រភេទកិច្ចសន្យា/អតីតភាពក្នុងកំឡុងពេលសំរាកលំហែមាតុភាពនោះទេ ។ | ១ (២%) | 0 |
| | | |
| ពុំគប្បីរើសអើងភេទពេលដែលធ្វើការជ្រើសរើសនោះទេ ។ | ១ (២%) | 0 |

ក្នុងរោងចក្រចំនួន ៦ អ្នកគ្រប់គ្រងបានបញ្ឈប់កម្មករនិយោជិតមានផ្ទៃពោះ ឬ បង្ខំឱ្យពួកគេលាឈប់ពីការងារ ។ អ្នកគ្រប់គ្រងបានផ្លាស់ប្តូរប្រភេទកិច្ចសន្យា ក្នុងអំឡុងពេលសំរាកលំហែមាតុភាពនៅក្នុងរោងចក្រ ១ ។ នៅក្នុងរោងចក្រ ១ អ្នកគ្រប់គ្រងមិនធ្វើការជ្រើសរើសបុរសឱ្យធ្វើការទេ ដោយយោងតាមបទពិសោធន៍កន្លងមកបង្ហាញថាបុរសដឹកនាំធ្វើឱ្យមានកូដកម្ម ។

[២] ការរើសអើងដោយមូលហេតុនៃសមាជិកភាពសហជីព ឬ ដោយសកម្មភាពសហជីព មានបញ្ចូលដោយឡែកពីគ្នាដូចខាងក្រោម ។

## ២.១.១៣ ពលកម្មដោយបង្ខំ

ច្បាប់ ( មាត្រា ១៥ អនុសញ្ញាអង្គការពលកម្មអន្តរជាតិលេខ ២៩ និង ១០៥) :

ការងារដោយបង្ខំ ត្រូវហាមឃាត់ជាដាច់ខាត ដោយអនុលោមតាមអនុសញ្ញារបស់អង្គការពលកម្មអន្តរជាតិលេខ ២៩ និង អនុសញ្ញាលេខ ១០៥ ស្តីពីពលកម្មដោយបង្ខំ ហើយព្រះរាជាណាចក្រកម្ពុជាបានឱ្យសច្ចាប័ននៅក្នុងឆ្នាំ ១៩៦៩ និង ១៩៩៩ ។ អនុសញ្ញាលេខ ២៩ កំណត់ពីការងារដោយបង្ខំ ថាជាការងារមិនផ្អែកលើការស្ម័គ្រចិត្ត និងឋិតនៅក្រោមការគំរាមកំហែងពីការដាក់ទណ្ឌកម្មណាមួយ ។

ពុំមានការបញ្ជាក់ណាមួយត្រូវបានគេរកឃើញអំពីការងារដោយបង្ខំនៅក្នុងរោងចក្រណាមួយនោះទេ ។

## ២.១.១៤ ពលកម្មកុមារ

ច្បាប់ (មាត្រា ១៧៧ និង ១៧៩ សេចក្តីជូនដំណឹង ១១/០៣) :

អាយុអប្បបរមាអាចចូលធ្វើការជាកម្មករនិយោជិត ត្រូវបានកំណត់ត្រឹម ១៥ ឆ្នាំ ។ អាយុអប្បបរមារបស់កម្មករនិយោជិតកំណត់ដល់ ១៨ ឆ្នាំ ចំពោះមុខរបរ ឬ ការងារគ្រប់ប្រភេទដែលអាចធ្វើឱ្យខូច ឬ ប៉ះពាល់ដល់សុខភាព ។ ក្មេងដែលមានអាយុពី ១២ ទៅ ១៥ ឆ្នាំ អាចអនុញ្ញាតឱ្យធ្វើការងារស្រាល ៗ ក្នុងល័ក្ខខ័ណ្ឌដែលការងារនោះមិនបណ្តាលឱ្យខូចសុខភាព ឬ ការលូតលាស់ខាងផ្លូវចិត្ត និង ផ្លូវកាយរបស់កុមារ ហើយការងារទាំងនោះ មិនបណ្តាលឱ្យប៉ះពាល់ដល់ការសិក្សាជាទៀងទាត់ ឬ កម្មវិធីបណ្តុះបណ្តាល ។ និយោជក គប្បីបញ្ជាក់អាយុរបស់កម្មករនិយោជិត ដោយផ្ទៀងផ្ទាត់ជាមួយឯកសារដែលអាចយកជាផ្លូវការបានមុនពេលជ្រើសរើសកម្មករនិយោជិត ។

**សំណូមពរដែលលើកឡើងសំរាប់រោងចក្រ :**

| អ្នកគ្រប់គ្រង | ចំនួននិងភាគរយនៃរោងចក្រដែលមានសំណូមពរចំពោះបញ្ហានេះ (មិនអនុវត្ត) | ចំនួននៃរោងចក្រដែលធ្វើឱ្យល័ក្ខខ័ណ្ឌការងារប្រសើរភ្លាមៗមុននឹងរបាយការណ៍ឃ្លាំមើលសំរេចជាស្ថាពរ |
|---|---|---|
| ពុំគប្បីជួលកម្មករនិយោជិតដែលនៅក្រោមអាយុឱ្យធ្វើការ ។ | ១ (២%) | 0 |
| | | |
| គប្បីបញ្ជាក់អាយុរបស់កម្មករនិយោជិត ដោយផ្ទៀងផ្ទាត់ជាមួយឯកសារដែលអាចយកជាផ្លូវការបាន មុនពេលជ្រើសរើសកម្មករនិយោជិត ។ | ៥ (១០%)<br>១ C (២%) | 0 |

បន្ទាប់ពីអ្នកតាមឃ្លាំមើល ធ្វើការផ្ទៀងផ្ទាត់ពីអាយុរបស់កម្មករនិយោជិត ដែលហាក់ដូចជានៅក្រោមអាយុដែលអនុញ្ញាតឱ្យធ្វើការ ជាមួយនឹងឯកសារសំរាប់ផ្ទៀងផ្ទាត់នៅតាមការិយាល័យឃុំ ដែលពាក់ព័ន្ធនីមួយៗមក

រោងចក្រចំនួន ៤ ត្រូវបានរកឃើញថា បានជួលកម្មករនិយោជិតក្រោមអាយុចំនួន ១០ នាក់ ។ កង្វះខាតខាងប្រព័ន្ធចុះឈ្មោះកំណើតជាសកល និង ការក្លែងបន្លំឯកសារដោយកម្មករនិយោជិត គឺជាបញ្ហាដ៏សខាន់នៅប្រទេសកម្ពុជា ។ កម្មករក្រោមអាយុបួននាក់ក្នុងចំណោមពួកគេ ត្រូវបានដាក់ឱ្យចូលរៀនវិជ្ជាជីវៈ ហើយនិយោជកជាអ្នកចេញថ្លៃឈ្នួលសិក្សា ព្រមទាំងឱ្យប្រាក់ឈ្នួលប្រចាំខែចំនួន ៤៥ ដុល្លាអាមេរិក រហូតដល់កម្មករនិយោជិតទាំងនេះ ត្រូវបានជួលឱ្យធ្វើការវិញ នៅពេលពួកគេគ្រប់អាយុ ១៥ ឆ្នាំ ។ បីនាក់ បានលាឈប់ពីការងារ និងមួយនាក់បានគ្រប់អាយុ ១៥ ឆ្នាំ នៅពេលដែលអ្នកឃ្លាំមើល ធ្វើការពិភាក្សាលើបញ្ហានេះ ជាមួយអ្នកគ្រប់គ្រង បន្ទាប់ពីមានការចុះឃ្លាំមើលមក។ ហើយពីរនាក់ផ្សេងទៀតបានគ្រប់អាយុ ១៥ ឆ្នាំ បន្ទាប់ពី ពីរខែក្រោយពេលអ្នកឃ្លាំមើលធ្វើការផ្ទៀងផ្ទាត់ពីអាយុ ។

## ២.២ សុវត្ថិភាព និង អនាម័យ

ច្បាប់ស្តីពីការងារនៃព្រះរាជាណាចក្រកម្ពុជា មានជំពូកទូទៅស្តីពីអនាម័យ និងសុវត្ថិភាពការងារ។ មាត្រា ២២៩ ចែងថាគ្រប់គ្រឹះស្ថានត្រូវឱ្យមានល័ក្ខខ័ណ្ឌការងារចាំបាច់ ស្អាត និង អនាម័យល្អ សំរាប់សុខភាពរបស់កម្មករនិយោជិត ។ រីឯមាត្រា ២៣០ ចែងថាគ្រប់គ្រឹះស្ថានត្រូវរៀបចំយ៉ាងណាឱ្យមានការធានាដល់សុវត្ថិភាពរបស់កម្មករនិយោជិត ហើយមាត្រា ២៥០ ចែងថាសហគ្រាសត្រូវចាត់ ឬ ប្រើឱ្យគេចាត់វិធានការចាំបាច់ទាំងអស់ដើម្បីបង្ការគ្រោះថ្នាក់ការងារផ្សេងៗ ។ ផ្នែកពិសេសស្តីពីសុវត្ថិភាព និង អនាម័យ ដែលបានរៀបរាប់នៅផ្នែកបន្តបន្ទាប់ខាងក្រោមនេះ ត្រូវបានការឯកភាពពីគណៈកម្មការប្រឹក្សាគំរោង ហើយបញ្ចូលទៅក្នុងបញ្ជីផ្ទៀងផ្ទាត់របស់អ្នកឃ្លាំមើល ។ ផ្នែកទាំងនេះ ឆ្លុះបង្ហាញឱ្យឃើញពីល័ក្ខខ័ណ្ឌជាក់លាក់ផ្សេងៗ ដែលសំខាន់សំរាប់សហគ្រាស ក្នុងការធានាសុខភាព និង សុវត្ថិភាព ដល់កម្មករនិយោជិត ។ មាត្រាទាំងនេះ មានចែងនៅក្នុងច្បាប់ស្តីពីការងារ ។

### ២.២.១.១ គោលនយោបាយស្តីពីសុវត្ថិភាព និង អនាម័យ

ច្បាប់:

ពុំមានសេចក្តីតម្រូវខាងផ្លូវច្បាប់ជាក់លាក់ឡើយ ចំពោះការរៀបចំបង្កើត និង ការអនុវត្តន៏នូវគោលនយោបាយ ស្តីពីសុវត្ថិភាព និង អនាម័យ ។

**សំណូមពរដែលលើកឡើងសំរាប់រោងចក្រ :**

| អ្នកគ្រប់គ្រង | ចំនួននិងភាគរយនៃរោងចក្រដែលមានសំណូមពរចំពោះបញ្ហានេះ (មិនអនុវត្ត) | ចំនួននៃរោងចក្រដែលធ្វើឱ្យល័ក្ខខ័ណ្ឌការងារប្រសើរភ្លាមៗ មុននឹងរបាយការណ៍ឃ្លាំមើលសំរេចជាស្ថាពរ |
|---|---|---|
| គប្បីបង្កើតឱ្យមានគោលនយោបាយស្តីពីសុវត្ថិភាព និង អនាម័យការងារ។ | ៤៧ (៩៤%) | ១ |

| អ្នកគ្រប់គ្រង | ចំនួននិងភាគរយនៃរោងចក្រដែលមានសំណូមពរចំពោះបញ្ហានេះ (មិនអនុវត្ត) | ចំនួននៃរោងចក្រដែលធ្វើឱ្យល័ក្ខខ័ណ្ឌការងារប្រសើរភ្លាមៗ មុននឹងរបាយការណ៍ឃ្លាំមើលសំរេចជាស្ថាពរ |
|---|---|---|
| គប្បីបិទផ្សាយគោលនយោបាយស្តីពីសុវត្ថិភាព និង អនាម័យការងារនៅកន្លែងធ្វើការ និង ពន្យល់ដល់កម្មករនិយោជិត ។ | ១ (២%) | 0 |
| | | |
| គប្បីបិទផ្សាយពតិមានស្តីពីសុវត្ថិភាព និង អនាម័យការងារ (ឧ: ប័ណ្ណផ្សាយ និង សញ្ញាសំគាល់នានា) នៅកន្លែងធ្វើការ ។ | ៣ (៦%) | 0 |

២.២.១.២ <u>គ្រោះថ្នាក់ការងារ/ជំងឺវិជ្ជាជីវៈ</u>

ច្បាប់ (ប្រកាស ២៤៣/០២) :

និយោជក ត្រូវជូនដំណឹងជាលាយល័ក្ខណ៍អក្សរអំពីគ្រោះថ្នាក់ការងារទៅនាយកដ្ឋានសន្តិសុខសង្គមនៃក្រសួងការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ ប្រសិនបើសហគ្រាសនោះមានទីតាំងនៅទីក្រុងភ្នំពេញ ឬ ក៏ទៅអធិការដ្ឋានតាមខេត្ត-ក្រុង ។

**សំណូមពរដែលលើកឡើងសំរាប់រោងចក្រ :**

| អ្នកគ្រប់គ្រង | ចំនួននិងភាគរយនៃរោងចក្រដែលមានសំណូមពរចំពោះបញ្ហានេះ (មិនអនុវត្ត) | ចំនួននៃរោងចក្រដែលធ្វើឱ្យល័ក្ខខ័ណ្ឌការងារប្រសើរភ្លាមៗ មុននឹងរបាយការណ៍ឃ្លាំមើលសំរេចជាស្ថាពរ |
|---|---|---|
| គប្បីបង្កើតឱ្យមានប្រព័ន្ធសំរាប់កត់ត្រាគ្រោះថ្នាក់ ការងារ និង ជម្ងឺវិជ្ជាជីវៈ ។ | ១៦ (៣២%) | ២ |
| | | |
| ត្រូវជូនដំណឹងដល់អាជ្ញាធរពាក់ព័ន្ធ អំពីគ្រោះថ្នាក់ការងារ ឬ ជម្ងឺវិជ្ជាជីវៈក្នុងរយៈពេល ៤៨ ម៉ោង ។ | ២៥ (៥០%) | ១ |
| | | |
| ត្រូវផ្តល់ជូនអាជ្ញាធរពាក់ព័ន្ធ នូវរបាយការណ៍សង្ខេប ស្តីពីគ្រោះថ្នាក់ការងារ ឬ ជម្ងឺវិជ្ជាជីវៈ ។ | ៤ (៨%) | 0 |

### ២.២.១.៣ តាវកាលិកសំរាប់គ្រោះថ្នាក់ការងារ ឬ ជំងឺវិជ្ជាជីវៈ

ច្បាប់ ( មាត្រា ២៤៨ ២៤៩ ២៥៣ និង ២៥៤ ប្រកាស ២៤៣/០២) :

គ្រោះថ្នាក់ដែលកើតឡើងធ្លាក់លើកម្មករនិយោជិតដែលធ្វើការ ឬ ក្នុងពេលកំពុងធ្វើការ ត្រូវចាត់ទុកជាគ្រោះថ្នាក់ការងារ ទោះដោយហេតុយ៉ាងណាក៏ដោយ ហើយទោះមានកំហុសមកពីកម្មករនិយោជិត ឬ គ្មានក៏ដោយ។ ម៉្យាងទៀតចំពោះគ្រោះថ្នាក់ណា ដែលធ្លាក់លើកម្មករនិយោជិតក្នុងពេលដែលសាមីខ្លួន ធ្វើដំណើរពីលំនៅស្ថានរបស់ខ្លួនត្រង់ឆ្ពោះទៅទីកន្លែងធ្វើការ និង វិលមកផ្ទះវិញ ក៏ត្រូវចាត់ទុកជាគ្រោះថ្នាក់ការងារដែរ ។ អ្នករងគ្រោះត្រូវមានសិទ្ធិទទួលបានការពិនិត្យព្យាបាលជម្ងឺ (ការព្យាបាលជម្ងឺ និងការផ្តល់ថ្នាំ ព្រមទាំងកន្លែងសំរាកព្យាបាលជាដើម) និង ផ្តល់តាវកាលិកប្រចាំថ្ងៃ ។ ក្នុងករណីដែលមានគ្រោះថ្នាក់ដល់ស្លាប់ ឬ គ្រោះថ្នាក់ដែលបណ្តាលឱ្យបាត់បង់សមត្ថភាពពលកម្មជាអចិន្ត្រៃយ៍ នោះប្រាក់បំណាច់ត្រូវបើកឱ្យអ្នករងគ្រោះ ឬ សិទ្ធិវន្តជាធនលាភ។

**សំណូមពរដែលលើកឡើងសំរាប់រោងចក្រ :**

| អ្នកគ្រប់គ្រង | ចំនួននិងភាគរយនៃរោងចក្រដែលមានសំណូមពរចំពោះបញ្ហានេះ (មិនអនុវត្ត) | ចំនួននៃរោងចក្រដែលធ្វើឱ្យល័ក្ខខ័ណ្ឌការងារប្រសើរភ្លាមៗ មុននឹងរបាយការណ៍ឃ្លាំមើលសំរេចជាស្ថាពរ |
|---|---|---|
| គប្បីធានាឱ្យមានការផ្តល់ដល់កម្មករនិយោជិត នូវតាវកាលិកសំរាប់គ្រោះថ្នាក់ការងារ ឬ ជម្ងឺវិជ្ជាជីវៈ រួមទាំងគ្រោះថ្នាក់តាមផ្លូវមកកាន់ និង ចេញពីធ្វើការ។ | ២២ (៤៤%) | ០ |
| | | |
| គប្បីធានាឱ្យមានការផ្តល់ដល់កម្មករនិយោជិតនូវ តាវកាលិកសំរាប់គ្រោះថ្នាក់ការងារ ឬ ជម្ងឺវិជ្ជាជីវៈ ឱ្យបានត្រឹមត្រូវរួមទាំងការទូទាត់សំរាប់ពិការភាព ប្រសិនបើកម្មករនិយោជិតនោះពិការបណ្តោះអាសន្ន ឬ ពិការជាអចិន្ត្រៃយ៍ ។ | ១ (២%) | ០ |
| | | |
| គប្បីធានាឱ្យមានការផ្តល់ដល់កម្មករនិយោជិត នូវប្រាក់ឈ្នួលសំរាប់គ្រោះថ្នាក់ការងារ ឬ ជម្ងឺវិជ្ជាជីវៈ ដែលបណ្តាលឱ្យខកខានមិនអាចធ្វើការបាន ។ | ១៣ (២៦%) | ១ |

### ២.២.១.៤ ការចាត់ចែងពេលមានអាសន្ន

ច្បាប់:

ពុំមានសេចក្តីតម្រូវតាមផ្លូវច្បាប់ជាក់លាក់ឡើយ ចំពោះការរៀបចំបង្ការភាពអាសន្ន ។

**សំណូមពរដែលលើកឡើងសំរាប់រោងចក្រ :**

| អ្នកគ្រប់គ្រង | ចំនួននិងភាគរយនៃរោងចក្រដែលមានសំណូមពរចំពោះបញ្ហានេះ (មិនអនុវត្ត) | ចំនួននៃរោងចក្រដែលធ្វើឱ្យល័ក្ខខ័ណ្ឌការងារប្រសើរភ្លាម១ មុននឹងរបាយការណ៍ឃ្លាំមើលសំរេចជាស្ថាពរ |
|---|---|---|
| គប្បីរៀបចំធ្វើការហ្វឹកហាត់អំពីភាពអាសន្នឱ្យបានទៀងទាត់ជាប្រចាំ ។ | ៣១ (៦២%) | ៣ |
| | | |
| គប្បីធានាឱ្យប្រាកដថា ទ្វារទាំងអស់សំរាប់គេចចេញពេលមានអាសន្នត្រូវបើកចំហរ ឬ ពុំត្រូវបានចាក់សោរបិទក្នុងម៉ោងធ្វើការរួមទាំងពេលធ្វើការម៉ោងបន្ថែម ។ | ១២ (២៤%) | ១ |
| | | |
| គប្បីបង្កើតទ្វារសំរាប់គេចចេញពេលមានអាសន្ន ឱ្យបានគ្រប់គ្រាន់សំរាប់កម្មករនិយោជិតរត់ចេញបានលឿន បើសិនមានភាពអាសន្ន ។ | ១ (២%) | 0 |
| | | |
| គប្បីគូសគំនូសសំគាល់ទ្វារសំរាប់គេចចេញ ពេលមានអាសន្នឱ្យបានច្បាស់ ។ | ៦ (១២%) | 0 |
| | | |
| គប្បីធានាឱ្យប្រាកដថា ទ្វារសំរាប់គេចចេញពេលមានអាសន្នអាចឆ្លងកាត់បាន ។ | ២ (៤%) | 0 |
| | | |
| គប្បីធានាឱ្យប្រាកដថា មានការតម្លើងបំពង់ពន្លត់អគ្គិភ័យឱ្យបានគ្រប់គ្រាន់ ។ | ២ (៤%) | ១ |
| | | |
| គប្បីធានាឱ្យប្រាកដថា បំពង់ពន្លត់អគ្គិភ័យទាំងអស់ងាយស្រួលក្នុងការយកមកប្រើប្រាស់ ។ | ៤ (៨%) | 0 |

| អ្នកគ្រប់គ្រង | ចំនួននិងភាគរយនៃរោងចក្រដែលមានសំណូមពរចំពោះបញ្ហានេះ (មិនអនុវត្ត) | ចំនួននៃរោងចក្រដែលធ្វើឱ្យល័ក្ខខ័ណ្ឌការងារប្រសើរភ្លាមៗមុននឹងរបាយការណ៍ឃ្លាំមើលសំរេចជាស្ថាពរ |
|---|---|---|
| គប្បីធានាឱ្យប្រាកដថា បំពង់ពន្លត់អគ្គីភ័យទាំងអស់ត្រូវបានពិនិត្យថែទាំទៀងទាត់ជាប្រចាំ ។ | ៦ (១២%) | ២ |
| | | |
| គប្បីបង្រៀនកម្មករនិយោជិត តាមចំនួនសមស្រប ទាំងប្រុស និង ស្រី ឱ្យចេះប្រើប្រាស់បំពង់ពន្លត់អគ្គីភ័យ ។ | ៤ (៨%) | 0 |
| | | |
| គប្បីបិទសញ្ញា/សេចក្ដីជូនដំណឹងពីសុវត្ថិភាពនៅតាមកន្លែងធ្វើការ ។ | ៩ (១៨%) | 0 |

២.២.១.៥ <u>ការសង្គ្រោះបឋម</u>

ច្បាប់:

ពុំមានសេចក្ដីតម្រូវខាងផ្លូវច្បាប់ជាក់លាក់ឡើយ ចំពោះការរៀបចំឱ្យមានប្រអប់សង្គ្រោះបឋមនៅតាមកន្លែង លើកលែងតែប្រកាសរួមលេខ ៣៣០/០០ ដែលតម្រូវឱ្យសហគ្រាសដែលមានកម្មករនិយោជិតតិចជាង ២០នាក់ ត្រូវមានប្រអប់សង្គ្រោះបឋមមួយ និងអ្នកសង្គ្រោះបឋមម្នាក់ (ជាជំនួសឱ្យការបង្កើតគិលានដ្ឋានមួយ នៅក្នុងសហគ្រាសតូចៗ) នោះ ។

**សំណូមពរដែលលើកឡើងសំរាប់រោងចក្រ :**

| អ្នកគ្រប់គ្រង | ចំនួននិងភាគរយនៃរោងចក្រដែលមានសំណូមពរចំពោះបញ្ហានេះ (មិនអនុវត្ត) | ចំនួននៃរោងចក្រដែលធ្វើឱ្យល័ក្ខខ័ណ្ឌការងារប្រសើរភ្លាមៗមុននឹងរបាយការណ៍ឃ្លាំមើលសំរេចជាស្ថាពរ |
|---|---|---|
| គប្បីធានាឱ្យប្រាកដថា ប្រអប់សង្គ្រោះមានចំនួនគ្រប់គ្រាន់ត្រូវបានស្ដុកទុកយ៉ាងល្អត្រឹមត្រូវនៅកន្លែងធ្វើការ ។ | ១៨ (៣៦%) | ១ |
| | | |
| គប្បីធានាឱ្យប្រាកដថា ប្រអប់សង្គ្រោះត្រូវបានស្ដុកទុក យ៉ាងល្អត្រឹមត្រូវ ។ | ១៩ (៣៨%) | ១ |

| អ្នកគ្រប់គ្រង | ចំនួននិងភាគរយនៃរោងចក្រដែលមានសំណូមពរចំពោះបញ្ហានេះ (មិនអនុវត្ត) | ចំនួននៃរោងចក្រដែលធ្វើឱ្យល័ក្ខខ័ណ្ឌការងារប្រសើរភ្លាមៗ មុននឹងរបាយការណ៍ឃ្លាំមើលសំរេចជាស្ថាពរ |
|---|---|---|
| គប្បីធានាឱ្យប្រាកដថា ប្រអប់សង្គ្រោះអាចប្រើប្រាស់បានស្រួល ។ | ៧ (១៤%) | 0 |
| | | |
| គប្បីបង្រៀនកម្មករនិយោជិត អំពីការសង្គ្រោះបឋម ។ | ១៣ (២៦%) | 0 |

**២.២.១.៦ គិលានដ្ឋាន**

ច្បាប់ (មាត្រា ២៤២ និង ២៤៤ ប្រកាសរួម ៣៣០/០០) :

សហគ្រាសទាំងអស់ដែលមានប្រើកម្មករនិយោជិតយ៉ាងតិច ៥០ នាក់ ត្រូវតែមានគិលានដ្ឋានអចិន្ត្រៃយ៍មួយក្នុងបរិវេណនៃគ្រឹះស្ថាន ។ គិលានដ្ឋាននេះ ត្រូវមានគ្រូពេទ្យកាន់កាប់ផ្ទាល់ដោយមានគិលានុបដ្ឋាក ឬ គិលានុបដ្ឋាយិកាម្នាក់ ឬ ច្រើននាក់ជួយធ្វើការផង គិតទៅតាមចំនួនកម្មករនិយោជិត ។ ក្នុងម៉ោងធ្វើការទាំងថ្ងៃទាំងយប់ និងម៉ោងបន្ថែម ត្រូវមានគិលានុបដ្ឋាក ឬ គិលានុបដ្ឋាយិកាយ៉ាងតិចម្នាក់ នៅយាមប្រចាំការជាអចិន្ត្រៃយ៍ ។ គិលានដ្ឋានត្រូវមានសំភារៈ វត្ថុរុំរបួស និង ឱសថគ្រប់គ្រាន់ ដើម្បីព្យាបាលជាបន្ទាន់ ក្នុងករណីមានគ្រោះថ្នាក់ ឬ មានជម្ងឺបណ្តាលមកពីការងារ ឬ មានជម្ងឺក្នុងពេលធ្វើការងារ ។ កាលណាចំនួនកម្មករនិយោជិតមានច្រើនជាង ២០០ នាក់ គិលានដ្ឋានត្រូវមានគ្រែសំរាប់ឱ្យអ្នករបួស និង អ្នកជម្ងឺសំរាកព្យាបាល ។ ទីកន្លែងទាំងនោះត្រូវមានលទ្ធភាពដាក់អ្នកជម្ងឺសំរាកឱ្យបានពីរភាគរយ នៃបុគ្គលិកដែលបំរើការក្នុងការដ្ឋាន ហើយចំនួនគ្រែវិញមានត្រឹម ២០ ជាអតិបរមា ។

**សំណូមពរដែលលើកឡើងសំរាប់រោងចក្រ :**

| អ្នកគ្រប់គ្រង | ចំនួននិងភាគរយនៃរោងចក្រដែលមានសំណូមពរចំពោះបញ្ហានេះ (មិនអនុវត្ត) | ចំនួននៃរោងចក្រដែលធ្វើឱ្យល័ក្ខខ័ណ្ឌការងារប្រសើរភ្លាមៗ មុននឹងរបាយការណ៍ឃ្លាំមើលសំរេចជាស្ថាពរ |
|---|---|---|
| គប្បីបង្កើតឱ្យមានគិលានដ្ឋានសំរាប់កម្មករនិយោជិត ។ | ៩ (១៨%) | 0 |
| | | |
| គប្បីពង្រីកលទ្ធភាពនៃគិលានដ្ឋានសំរាប់ការសំរាកព្យាបាលជម្ងឺ ។ | ៣៥ (៧០%) | ១ |
| | | |
| គប្បីជួលវេជ្ជបណ្ឌិតម្នាក់មកបំរើការ ។ | ១៦ (៣២%) | ១ |

| អ្នកគ្រប់គ្រង | ចំនួននិងភាគរយនៃរោងចក្រដែលមានសំណូមពរចំពោះបញ្ហានេះ (មិនអនុវត្ត) | ចំនួននៃរោងចក្រដែលធ្វើឱ្យល័ក្ខខ័ណ្ឌការងារប្រសើរភ្លាមៗមុននឹងរបាយការណ៍ឃ្លាំមើលសំរេចជាស្ថាពរ |
|---|---|---|
| គប្បីជួលគិលានុបដ្ឋាក ឬ គិលានុបដ្ឋាយិកាម្នាក់មកបំរើការ (បន្ថែម) ។ | ១៧ (៣៤%) | 0 |
| | | |
| គប្បីធានាឱ្យប្រាកដថា គិលានុបដ្ឋាក ឬ គិលានុបដ្ឋាយិកាម្នាក់ ឬ វេជ្ជបណ្ឌិតម្នាក់ត្រូវយាមប្រចាំការក្នុងពេលម៉ោង ដែលតម្រូវឱ្យធ្វើការ (រួមទាំងពេលធ្វើការបន្ថែមម៉ោងផង) ។ | ៣០ (៦០%) | 0 |
| | | |
| គប្បីធានាឱ្យប្រាកដថា គិលានដ្ឋានផ្តល់ភាពងាយស្រួលដល់កម្មករនិយោជិត ។ | ១ (២%) | 0 |
| | | |
| គប្បីធានាឱ្យប្រាកដថាគិលានដ្ឋានមានថ្នាំពេទ្យ និង ឧបករណ៍ពេទ្យគ្រប់គ្រាន់ ។ | ២២ (៤៤%) | 0 |
| | | |
| គប្បីធានាឱ្យប្រាកដថា គិលានដ្ឋានមានភាពស្អាត អនាម័យល្អ ។ | ៤ (៨%) | 0 |
| | | |
| ពុំគប្បីកំណត់ជ្រុលហួសហេតុលើកម្មករនិយោជិត ក្នុងការប្រើប្រាស់គិលានដ្ឋាន ។ | ៤ (៨%) | 0 |
| | | |
| គប្បីពិចារណាធ្វើបង្គន់អនាម័យមួយនៅជិតគិលានដ្ឋាន ។ | ២ (៤%) | 0 |

**២.២.២ ការប្រើប្រាស់ សារធាតុគ្រោះថ្នាក់**

**២.២.២.១ ការស្តុកទុក**

ច្បាប់:

ពុំមានសេចក្តីតម្រូវខាងផ្លូវច្បាប់ជាក់លាក់ឡើយ ចំពោះការស្តុកទុក និង ការប្រើប្រាស់សារធាតុគ្រោះថ្នាក់ជាសក្តានុពល ។

**សំគាល់ :** ដោយសារវាហួសពីសមត្ថភាពរបស់គំរោង ក្នុងការពិនិត្យផ្ទៀងផ្ទាត់សារធាតុគីមី និងគ្រោះថ្នាក់ជាសក្តានុពលពីការប៉ះពាល់សារធាតុគីមី គំរោងគ្រាន់តែធ្វើការពិនិត្យមើលទីកន្លែងទុកដាក់សារធាតុទាំងនោះនៅតាមរោងចក្រទាំងឡាយណាដែលមានប្រើសារធាតុគីមីក្នុងចំនួនច្រើន ។ តាមការអនុវត្តន៍ជាក់ស្តែង គឺមានន័យថាជារោងចក្រទាំងឡាយណាដែលបានអធិប្បាយក្នុងរបាយការណ៍នេះ មានផ្នែកបោកគក់ ឬ ផ្នែកជ្រលក់ពណ៌តែប៉ុណ្ណោះ ។

**សំណូមពរដែលលើកឡើងសំរាប់រោងចក្រ :**

| អ្នកគ្រប់គ្រង | ចំនួននិងភាគរយនៃរោងចក្រដែលមានសំណូមពរចំពោះបញ្ហានេះ (មិនអនុវត្ត) | ចំនួននៃរោងចក្រដែលធ្វើឱ្យល័ក្ខខ័ណ្ឌការងារប្រសើរភ្លាមៗ មុននឹងរបាយការណ៍ឃ្លាំមើលសំរេចជាស្ថាពរ |
|---|---|---|
| គប្បីធានាឱ្យប្រាកដថា សារធាតុគីមីត្រូវបានរៀបចំស្តុកទុកដោយឡែកពីកន្លែងធ្វើការ ។ | ៤ (៨%) | ១ |
| | | |
| គប្បីធានាឱ្យប្រាកដថា ធុងដាក់សារធាតុគីមីត្រូវតែបិទផ្លាកសំគាល់ជាភាសាខ្មែរ ។ | ៧ (១៤%) | ១ |
| | | |
| គប្បីរៀបចំផ្នែកដែលមានការប្រើប្រាស់សារធាតុគីមី ឱ្យនៅកន្លែងដោយឡែកពីកន្លែងធ្វើការ ។ | ១ (២%) | 0 |
| | | |
| គប្បីផ្តល់ឧបករណ៍សមស្របដល់កម្មករនិយោជិត ដែលធ្វើការជាមួយសារធាតុគីមី ។ | ៥ (១០%) | 0 |
| | | |
| គប្បីបំពាក់ប្រព័ន្ធស្រូបខ្យល់ចេញចូល នៅកន្លែងដែលមានការប្រើប្រាស់សារធាតុគីមី ។ | ៨ (១៦%) | 0 |
| | | |
| គប្បីបង្រៀន កម្មករនិយោជិតឱ្យប្រើប្រាស់សារធាតុគីមីប្រកបដោយសុវត្ថិភាព ។ | ៤ (៨%) | 0 |

## ២.២.២.២ វិធានការការពារ

ច្បាប់:

ពុំមានសេចក្តីតម្រូវខាងផ្លូវច្បាប់ជាក់លាក់ឡើយ ចំពោះការផ្តល់នូវប្រដាប់ការពារ ។

**សំណូមពរដែលលើកឡើងសំរាប់រោងចក្រ :**

| អ្នកគ្រប់គ្រង | ចំនួននិងភាគរយនៃរោងចក្រដែលមានសំណូមពរចំពោះបញ្ហានេះ (មិនអនុវត្ត) | ចំនួននៃរោងចក្រដែលធ្វើឱ្យល័ក្ខខ័ណ្ឌការងារប្រសើរភ្លាមៗមុននឹងរបាយការណ៍ឃ្លាំមើលសំរេចជាស្ថាពរ |
|---|---|---|
| គប្បីផ្តល់ម៉ាស់ និង ស្រោមដៃ ដល់កម្មករនិយោជិតដោយមិនគិតកំរៃ ។ | ២៩ (៥៨%) | 0 |
| | | |
| គប្បីផ្តល់ស្បែកជើងពាក់ឱ្យបានសមរម្យ ជូនកម្មករនិយោជិតដោយមិនគិតកំរៃ ឬ អនុញ្ញាតឱ្យកម្មករនិយោជិតពាក់ស្បែកជើងរបស់គេផ្ទាល់នៅកន្លែងធ្វើការ ។ | ២៣ (៤៦%) | ២ |
| | | |
| គប្បីបង្រៀន/ចាត់វិធានការជំរុញកម្មករនិយោជិត ឱ្យចេះប្រើប្រាស់ប្រដាប់ និង សំលៀកបំពាក់ការពារ ។ | ៣៤ (៦៨%) | 0 |

## ២.២.៣ ភ្លើងបំភ្លឺ

ច្បាប់ (ប្រកាស ៤៨៤/០៣):

សហគ្រាសត្រូវរៀបចំឱ្យមានភ្លើងបំភ្លឺល្អគ្រប់គ្រាន់ ។ ភ្លើងបំភ្លឺត្រូវអោយភ្លឺល្អ និង មិនមានចំណាំងពន្លឺ ។

**សំណូមពរដែលលើកឡើងសំរាប់រោងចក្រ :**

| អ្នកគ្រប់គ្រង | ចំនួននិងភាគរយនៃរោងចក្រដែលមានសំណូមពរចំពោះបញ្ហានេះ (មិនអនុវត្ត) | ចំនួននៃរោងចក្រដែលធ្វើឱ្យល័ក្ខខ័ណ្ឌការងារប្រសើរភ្លាមៗមុននឹងរបាយការណ៍ឃ្លាំមើលសំរេចជាស្ថាពរ |
|---|---|---|
| គប្បីធានាឱ្យប្រាកដថា កន្លែងធ្វើការមានពន្លឺគ្រប់គ្រាន់ ។ | ៣ (៦%) | 0 |

## ២.២.៤ សូរសំលេង

ច្បាប់ ( អនុក្រិត្យ ៤២/00 ប្រកាស ១៣៨/0៣) :

បទដ្ឋាននៃការត្រួតពិនិត្យសូរសម្លេងសំរាប់រយៈពេលជាម៉ោងនៃការប្រឈមមុខនឹងសំលេង ត្រូវកំណត់តាមខ្នាតដូចខាងក្រោម :

| | |
|---|---|
| ៧៥ dB(A)( ដេស៊ីបែល) សំរាប់រយៈពេល ៣២ ម៉ោង | ១00 dB(A) ក្នុងរយៈពេល ១ ម៉ោង |
| ៨0 dB(A) សំរាប់រយៈពេល ១៦ ម៉ោង | ១0៥ dB(A) ក្នុងរយៈពេល 0,៥ ម៉ោង |
| ៨៥ dB(A) រយៈពេល ៨ ម៉ោង | ១១0 dB(A) ក្នុងរយៈពេល 0,២៥ ម៉ោង |
| ៩0 dB(A) ក្នុងរយៈពេល ៤ ម៉ោង | ១១៥ dB(A) ក្នុងរយៈពេល 0,១២៥ ម៉ោង |
| ៩៥ dB(A) ក្នុងរយៈពេល ២ ម៉ោង | |

និយោជក គប្បីផ្តល់ប្រដាប់ពាក់ការពារជូនដល់កម្មករនិយោជិត កាលណាពួកគេត្រូវប្រឈមនឹងកំរិតសម្លេងលើសពី ៨0 dB(A) ។

**សំណូមពរដែលលើកឡើងសំរាប់រោងចក្រ :**

| អ្នកគ្រប់គ្រង | ចំនួននិងភាគរយនៃរោងចក្រដែលមានសំណូមពរចំពោះបញ្ហានេះ ( មិនអនុវត្ត) | ចំនួននៃរោងចក្រដែលធ្វើឱ្យល័ក្ខខ័ណ្ឌការងារប្រសើរភ្លាម១ មុននឹងរបាយការណ៍ឃ្លាំមើលសំរេចជាស្ថាពរ |
|---|---|---|
| គប្បីធានាឱ្យប្រាកដថា កំរិតសូរសំលេងត្រូវបានកាត់បន្ថយនៅកន្លែងធ្វើការ ឬ ត្រូវផ្តល់ប្រដាប់ការពារត្រចៀកដល់កម្មករនិយោជិត ។ | ៩ ( ១៨%) | 0 |

## ២.២.៥ សុវត្ថិភាពនៃគ្រឿងម៉ាស៊ីន

ច្បាប់:

ពុំមានសេចក្តីតម្រូវខាងផ្លូវច្បាប់ជាក់លាក់ឡើយ ចំពោះសុវត្ថិភាពនៃគ្រឿងម៉ាស៊ីន ។

**សំណូមពរដែលលើកឡើងសំរាប់រោងចក្រ ៖**

| អ្នកគ្រប់គ្រង | ចំនួននិងភាគរយនៃរោងចក្រដែលមានសំណូមពរចំពោះបញ្ហានេះ (មិនអនុវត្ត) | ចំនួននៃរោងចក្រដែលធ្វើឱ្យល័ក្ខខ័ណ្ឌការងារប្រសើរភ្លាមៗមុននឹងរបាយការណ៍ឃ្លាំមើលសំរេចជាស្ថាពរ |
|---|---|---|
| គប្បីធានាឱ្យប្រាកដថា ម៉ាស៊ីនត្រូវបានថែទាំយ៉ាងល្អជាប្រចាំ ។ | ៥ (១០%) | 0 |
| | | |
| គប្បីធានាឱ្យប្រាកដថា ប្រព័ន្ធខ្សែភ្លើងត្រូវបានថែទាំយ៉ាងល្អត្រឹមត្រូវ ។ | ២ (៤%) | 0 |
| | | |
| គប្បីធានាឱ្យប្រាកដថា គ្រប់ម៉ាស៊ីនទាំងអស់ មានរបាំងការពារ/សុវត្ថិភាព ។ | ៣៤ (៦៨%) | ២ |
| | | |
| គប្បីបិទផ្លាកសញ្ញាសុវត្ថិភាពនៅតាមកន្លែងគ្រប់ប្រអប់អគ្គិសនី ។ | ២ (៤%) | 0 |

**២.២.៦. <u>ខ្យល់ចេញចូល និង កំដៅ</u>**

ច្បាប់ (ប្រកាស ១២៥/០១ និង ១៤៧/០២) ៖

និយោជក ត្រូវមានកាតព្វកិច្ចក្នុងការធានាឱ្យប្រាកដថា ការងារត្រូវបានធ្វើនៅក្នុងបរិយាកាសកំដៅដែលមិនធ្វើឱ្យប៉ះពាល់ដល់សុខភាពរបស់កម្មករនិយោជិត ឬ ក៏ប៉ះពាល់ដល់លទ្ធភាពបំពេញកិច្ចការរបស់កម្មករនិយោជិត ។ ដើម្បីសំរេចទិសដៅនេះ និយោជកត្រូវចាត់ឱ្យមានវិធានការសមស្របដើម្បីកាត់បន្ថយកំដៅ ។

**សំណូមពរដែលលើកឡើងសំរាប់រោងចក្រ ៖**

| អ្នកគ្រប់គ្រង | ចំនួននិងភាគរយនៃរោងចក្រដែលមានសំណូមពរចំពោះបញ្ហានេះ (មិនអនុវត្ត) | ចំនួននៃរោងចក្រដែលធ្វើឱ្យល័ក្ខខ័ណ្ឌការងារប្រសើរភ្លាមៗមុននឹងរបាយការណ៍ឃ្លាំមើលសំរេចជាស្ថាពរ |
|---|---|---|
| គប្បីធានាឱ្យប្រាកដថា កំរិតសីតុណ្ហភាពនៅកន្លែងធ្វើការត្រូវបានកាត់បន្ថយ ។ | ២១ (៤២%) | 0 |
| | | |
| គប្បីធ្វើឱ្យខ្យល់ចេញចូលនៅកន្លែងធ្វើការប្រសើរឡើង ។ | ២១ (៤២%) | 0 |

| អ្នកគ្រប់គ្រង | ចំនួននិងភាគរយនៃរោងចក្រដែលមានសំណូមពរចំពោះបញ្ហានេះ (មិនអនុវត្ត) | ចំនួននៃរោងចក្រដែលធ្វើឱ្យល័ក្ខខ័ណ្ឌការងារប្រសើរភ្លាមៗ មុននឹងរបាយការណ៍ឃ្លាំមើលសំរេចជាស្ថាពរ |
|---|---|---|
| គប្បីចាត់ឱ្យមានវិធានការកាត់បន្ថយធូលី ។ | ២ (៤%) | 0 |
| | | |
| គប្បីរៀបចំជួសជុលកង្ហារ និង ប្រព័ន្ធបញ្ចេញបញ្ចូលខ្យល់ឱ្យដំណើរការបានល្អប្រសើរ ។ | ៦ (១២%) | 0 |

## ២.២.៧ គេហកិច្ច

ច្បាប់:

ពុំមានសេចក្តីតម្រូវខាងផ្លូវច្បាប់ជាក់លាក់ឡើយ ចំពោះគេហកិច្ច ។

**សំណូមពរដែលលើកឡើងសំរាប់រោងចក្រ :**

| អ្នកគ្រប់គ្រង | ចំនួននិងភាគរយនៃរោងចក្រដែលមានសំណូមពរចំពោះបញ្ហានេះ (មិនអនុវត្ត) | ចំនួននៃរោងចក្រដែលធ្វើឱ្យល័ក្ខខ័ណ្ឌការងារប្រសើរភ្លាមៗ មុននឹងរបាយការណ៍ឃ្លាំមើលសំរេចជាស្ថាពរ |
|---|---|---|
| គប្បីធានាឱ្យប្រាកដថា ទីកន្លែងធ្វើការត្រូវបានបោសសំអាតឱ្យបានស្អាតល្អ។ | ១ (២%) | 0 |
| | | |
| គប្បីធានាឱ្យប្រាកដថា ទីកន្លែងធ្វើការត្រូវបានរៀបចំឱ្យមានសណ្តាប់ធ្នាប់។ | ១ (២%) | 0 |
| | | |
| គប្បីធានាឱ្យប្រាកដថា បង្អួច ជញ្ជាំង និង/ឬ ពិដាន ត្រូវបានសំអាត។ | ១៦ (៣២%) | 0 |
| | | |
| គប្បីធានាឱ្យប្រាកដថា វត្ថុធាតុដើម ឬ ផលិតផលសំរេចត្រូវបានរៀបចំទុកដាក់ ឱ្យមានសណ្តាប់ធ្នាប់ល្អ។ | ៥ (១០%) | 0 |
| | | |
| គប្បីរក្សាផ្លូវដើរឱ្យបានស្អាត និង ពុំមានអ្វីបាំង ។ | ៦ (១២%) | 0 |

| អ្នកគ្រប់គ្រង | ចំនួននិងភាគរយនៃរោងចក្រដែលមានសំណូមពរចំពោះបញ្ហានេះ (មិនអនុវត្ត) | ចំនួននៃរោងចក្រដែលធ្វើឱ្យល័ក្ខខ័ណ្ឌការងារប្រសើរភ្លាមៗ មុននឹងរបាយការណ៍ឃ្លាំមើលសំរេចជាស្ថាពរ |
|---|---|---|
| គប្បីធានាឱ្យប្រាកដថា ផ្លូវដើរអាចធ្វើចរាចរទៅមកបាន ។ | ១០ (២០%) | 0 |
| | | |
| គប្បីធានាឱ្យប្រាកដថា ឧបករណ៍ សំភារៈ និង កុងតាក់ស្ថិតនៅជិតដៃរបស់កម្មករនិយោជិត ។ | ២ (៤%) | 0 |
| | | |
| គប្បីធានាឱ្យប្រាកដថា មានឧបករណ៍សំរាប់ដឹកជញ្ជូន សំភារៈធ្ងន់ៗ និងសំពីងសំពោង ។ | ៩ (១៨%) | ១ |
| | | |
| គប្បីធានាឱ្យប្រាកដថា អំពូលភ្លើងត្រូវបានសំអាតល្អ ។ | ២ (៤%) | 0 |

**២.២.៨ <u>សុខុមាលភាព</u>**

**២.២.៨.១ <u>ភេសជ្ជៈអនាម័យ</u>**

ច្បាប់ (ប្រកាស ០៥៤/០០):

និយោជកត្រូវផ្តល់ភេសជ្ជៈអនាម័យឱ្យបានគ្រប់គ្រាន់ ដល់កម្មករនិយោជិតរបស់ខ្លួន ។ ដើម្បីរក្សាបានភាពស្អាត និង អនាម័យ ភេសជ្ជៈត្រូវដាក់ក្នុងធុងដែលមានគម្របបិទជិត និងមានជំពួយសំរាប់បង្ហូរពីខាងក្រោម ។ ទីតាំងដាក់ធុងភេសជ្ជៈ ត្រូវស្ថិតនៅជិតកន្លែងធ្វើការ ។ និយោជកត្រូវរៀបចំឱ្យមានកែវទឹក ឬ មធ្យោបាយណាផ្សេងទៀតប្រកបដោយលក្ខណៈអនាម័យសំរាប់កម្មករនិយោជិតប្រើប្រាស់ ។ និយោជក មិនត្រូវដាក់កំរិតជ្រុលហួសហេតុលើការពិសារទឹកទេ ។

**សំណូមពរដែលលើកឡើងសំរាប់រោងចក្រ :**

| អ្នកគ្រប់គ្រង | ចំនួននិងភាគរយនៃរោងចក្រដែលមានសំណូមពរចំពោះបញ្ហានេះ (មិនអនុវត្ត) | ចំនួននៃរោងចក្រដែលធ្វើឱ្យល័ក្ខខ័ណ្ឌការងារប្រសើរភ្លាមៗ មុននឹងរបាយការណ៍ឃ្លាំមើលសំរេចជាស្ថាពរ |
|---|---|---|
| គប្បីផ្តល់ទឹកស្អាតសំរាប់បរិភោគ ។ | ៣ (៦%) | 0 |
| | | |
| គប្បីផ្តល់ទឹកស្អាតសំរាប់បរិភោគឱ្យបានគ្រប់គ្រាន់ ។ | ២ (៤%) | 0 |

| អ្នកគ្រប់គ្រង | ចំនួននិងភាគរយនៃរោងចក្រដែលមានសំណូមពរចំពោះបញ្ហានេះ (មិនអនុវត្ត) | ចំនួននៃរោងចក្រដែលធ្វើឱ្យល័ក្ខខ័ណ្ឌការងារប្រសើរភ្លាមៗមុននឹងរបាយការណ៍ឃ្លាំមើលសំរេចជាស្ថាពរ |
|---|---|---|
| គប្បីផ្តល់នូវកែវទឹកមានចំនួនគ្រប់គ្រាន់ ឬ មានមធ្យោបាយអនាម័យផ្សេងទៀតសំរាប់ពិសារភេសជ្ជៈ ។ | ៣៨ (៧៦%) | 0 |
| | | |
| គប្បីរៀបចំកន្លែងសំរាប់បរិភោគទឹកបន្ថែមទៀត ។ | ៥ (១០%) | ១ |
| | | |
| គប្បីធានាឱ្យប្រាកដថា កន្លែងពិសារភេសជ្ជៈ និង ធុងដាក់ទឹកពិសារ មានលក្ខណៈស្អាត និង អនាម័យគ្រប់គ្រាន់ ។ | ១៦ (៣២%) | 0 |
| | | |
| ពុំគប្បីដាក់កំរិតជ្រុលហួសហេតុលើការពិសារទឹក ។ | ៣ (៦%) | 0 |

## **២.២.៨.២ ការរៀបចំបង្គន់អនាម័យ**

ច្បាប់ (ប្រកាស ០៥២/០០) :

សហគ្រាសត្រូវរៀបចំនូវបង្គន់សំរាប់ឱ្យកម្មករនិយោជិតបានប្រើប្រាស់ដោយសមរម្យ និង មានអនាម័យល្អ ។ ចំនួនបង្គន់ត្រូវរៀបចំ អាស្រ័យទៅតាមចំនួនកម្មករនិយោជិតនៅក្នុងសហគ្រាស ។ បង្គន់ត្រូវសាងសង់ឱ្យស្របទៅតាមកំរិតទំហំជាក់លាក់ ហើយឱ្យបានដូចតទៅ : កំរាលក្រោម និង ជញ្ជាំងមិនជ្រាបទឹក ទ្វារជិត និង មានគន្លឹះសំរាប់ខ្ទាស់ពីក្នុង មានពន្លឺសមរម្យ និង ត្រូវរៀបចំយ៉ាងណាឱ្យទឹកដែលបង្ហូរចេញពីបង្គន់ ស្របតាមក្បួនអនាម័យ ។ គប្បីសរសេរ/ដាក់សញ្ញាសំគាល់ឱ្យបានច្បាស់នៅបង្គន់សំរាប់បុរស-នារី ហើយបង្គន់ទាំងអស់ ត្រូវទទួលការថែទាំសំអាតយ៉ាងហោចណាស់បានម្តងក្នុងមួយថ្ងៃ ។ និយោជក គប្បីផ្តល់កន្លែងសំរាប់លាងដៃនៅក្បែរបង្គន់ ។ និយោជក គប្បីធានាឱ្យប្រាកដថាគ្មានការដាក់កម្រិតជ្រុលហួសហេតុ ទៅលើការប្រើប្រាស់បង្គន់ ។

សំណូមពរដែលលើកឡើងសំរាប់រោងចក្រ ៖

| អ្នកគ្រប់គ្រង | ចំនួននិងភាគរយនៃរោងចក្រដែលមានសំណូមពរចំពោះបញ្ហានេះ (មិនអនុវត្ត) | ចំនួននៃរោងចក្រដែលធ្វើឱ្យល័ក្ខខ័ណ្ឌការងារប្រសើរភ្លាមៗមុននឹងរបាយការណ៍ឃ្លាំមើលសំរេចជាស្ថាពរ |
|---|---|---|
| គប្បីសង់បង្គន់ ឱ្យគ្រប់ចំនួនដែលតំរូវដោយប្រកាសលេខ ០៥២/០០ ។ | ១៦ (៣២%) | ២ |
| | | |
| គប្បីជួសជុលបង្គន់ដែលខូច ។ | ១២ (២៤%) | ០ |
| | | |
| គប្បីជួសជុលទ្វារបង្គន់ដែលខូច ។ | ៩ (១៨%) | ៣ |
| | | |
| គប្បីសរសេរ/ដាក់សញ្ញាសំគាល់បង្គន់សំរាប់ បុរស-នារី ឱ្យបានច្បាស់ ។ | ៥ (១០%) | ០ |
| | | |
| គប្បីផ្តល់កន្លែងសំរាប់លាងដៃនៅក្បែរបង្គន់។ | ៣ (៦%) | ០ |
| | | |
| គប្បីធានាឱ្យប្រាកដថា បង្គន់ស្អាតល្អជានិច្ច ។ | ២០ (៤០%) | ១ |
| | | |
| គប្បីធានាឱ្យប្រាកដថា បង្គន់មានសាប៊ូ និង ទឹកប្រើប្រាស់គ្រប់គ្រាន់ ។ | ៤០ (៨០%) | ០ |
| | | |
| គប្បីធានាឱ្យប្រាកដថា គ្មានការដាក់កម្រិតជ្រុលហួសហេតុទៅលើការប្រើប្រាស់បង្គន់។ | ៦ (១២%) | ១ |
| | | |
| គប្បីកែលំអឱ្យបានប្រសើរនូវភ្លើងបំភ្លឺក្នុងបង្គន់។ | ២ (៤%) | ១ |
| | | |
| គប្បីផ្តល់ស្បែកជើងឱ្យបានសមរម្យដល់កម្មករនិយោជិតសំរាប់ប្រើពេលចូលបង្គន់ ឬ អនុញ្ញាតឱ្យគេប្រើស្បែកជើងរបស់គេ។ | ៣ (៦%) | ០ |

## ២.២.៨.៣ កន្លែងផ្ទុកឥវ៉ាន់ផ្ទាល់ខ្លួន

ច្បាប់:

ពុំមានសេចក្តីតម្រូវខាងផ្លូវច្បាប់ជាក់លាក់ឡើយ ចំពោះការរៀបចំបង្កើតកន្លែង ប្រកបដោយសុវត្ថិភាព សំរាប់ឱ្យកម្មករនិយោជិត ទុកដាក់របស់របរផ្ទាល់ខ្លួន ។

**សំណូមពរដែលលើកឡើងសំរាប់រោងចក្រ :**

| អ្នកគ្រប់គ្រង | ចំនួននិងភាគរយនៃរោងចក្រដែលមានសំណូមពរចំពោះបញ្ហានេះ (មិនអនុវត្ត) | ចំនួននៃរោងចក្រដែលធ្វើឱ្យល័ក្ខខ័ណ្ឌការងារប្រសើរភ្លាម១ មុននឹងរបាយការណ៍ឃ្លាំមើលសំរេចជាស្ថាពរ |
|---|---|---|
| គប្បីរៀបចំកន្លែងដែលមានសុវត្ថិភាពឱ្យកម្មករនិយោជិតទុកដាក់របស់របរផ្ទាល់ខ្លួន ។ | ៨ (១៦%) | 0 |

## ២.២.៩ ការរៀបចំអាសនៈ

ច្បាប់ (ប្រកាស ០៥៣/០០) :

និយោជកគប្បីផ្តល់កៅអីសមរម្យ ដល់កម្មករនិយោជិតដែលធ្វើការក្នុងឥរិយាបថអង្គុយ ។ កៅអីដែលអាចសេរ៉េ និង ផ្អែកខ្នងបាន គឺត្រូវបានចាត់ទុកថាសមរម្យសំរាប់កម្មករនិយោជិត ដែលធ្វើការរោងចក្រកាត់ដេរសំលៀកបំពាក់ ។ កម្មករនិយោជិតដែលធ្វើការងាររបស់ខ្លួនក្នុងឥរិយាបថឈរ ត្រូវបានផ្តល់ឱ្យនូវកៅអីនៅជិតកន្លែងធ្វើការដើម្បីមានលទ្ធភាពបានអង្គុយចុះម្តងម្កាលបាន ។

**សំណូមពរដែលលើកឡើងសំរាប់រោងចក្រ :**

| អ្នកគ្រប់គ្រង | ចំនួននិងភាគរយនៃរោងចក្រដែលមានសំណូមពរចំពោះបញ្ហានេះ (មិនអនុវត្ត) | ចំនួននៃរោងចក្រដែលធ្វើឱ្យល័ក្ខខ័ណ្ឌការងារប្រសើរភ្លាម១ មុននឹងរបាយការណ៍ឃ្លាំមើលសំរេចជាស្ថាពរ |
|---|---|---|
| គប្បីផ្តល់កៅអីដែលអាចសេរ៉េ និង ផ្អែកខ្នងបាន ដល់កម្មករនិយោជិត ដែលធ្វើការក្នុងឥរិយាបថអង្គុយ ។ | ៤៨ (៩៦%) | 0 |
| | | |
| គប្បីធានាឱ្យប្រាកដថា កម្មករនិយោជិត ដែលធ្វើការងាររបស់ | ៤៥ (៩០%) | 0 |

| អ្នកគ្រប់គ្រង | ចំនួននិងភាគរយនៃរោងចក្រដែលមានសំណូមពរចំពោះបញ្ហានេះ (មិនអនុវត្ត) | ចំនួននៃរោងចក្រដែលធ្វើឱ្យល័ក្ខខ័ណ្ឌការងារប្រសើរភ្លាមៗមុននឹងរបាយការណ៍ឃ្លាំមើលសំរេចជាស្ថាពរ |
|---|---|---|
| ខ្លួនក្នុងឥរិយាបថឈរ ត្រូវបានផ្តល់ឱ្យ នូវកៅអីដើម្បីមានលទ្ធភាពបានអង្គុយចុះ។ | | |
| | | |
| ពុំគប្បីដាក់កំហិតជ្រុលហួសហេតុ លើកម្មករនិយោជិត ដែលធ្វើការងាររបស់ខ្លួន ក្នុងឥរិយាបថឈរ មិនឱ្យសំរាកលើកៅអី ។ | ២ (៤%) | 0 |
| | | |
| គប្បីធានាឱ្យប្រាកដថា កម្មករនិយោជិតមិនធ្វើការងារដោយអង្គុយផ្ទាល់លើកំរាល/ដី ។ | ៣ (៦%) | 0 |

## ២.៣ ទំនាក់ទំនងក្នុងវិស័យការងារ

### ២.៣.១ សេរីភាពនៃកម្មករនិយោជិតក្នុងការបង្កើតអង្គការវិជ្ជាជីវៈ

ច្បាប់ (មាត្រា ២៦៦ ២៦៧ ២៧១ ២៧៣ និង ២៨0 អនុសញ្ញា ៨៧/៩៥ មាត្រា ២ និង ៣):

កម្មករនិយោជិត និង និយោជក មានសិទ្ធិបង្កើតអង្គការវិជ្ជាជីវៈរបស់ខ្លួនបាន ។ សហជីពរបស់និយោជិត និង សមាគមរបស់និយោជក មានសិទ្ធិតាក់តែងលក្ខន្តិកៈ ជ្រើសរើសតំណាងរបស់ខ្លួន និង បង្កើតកម្មវិធីរបស់ខ្លួនបាន ។ អ្នកគ្រប់គ្រងមិនត្រូវរំជ្រៀតជ្រែក សិទ្ធិរបស់កម្មករនិយោជិតក្នុងការបង្កើត និង ចូលរួមក្នុងសកម្មភាពរបស់សហជីព ឡើយ ។ អ្នកគ្រប់គ្រងគប្បីមិនមានការចាត់វិធានការណាមួយ ដែលអាចចាត់ទុកថាជាគោលបំណងដាក់សហជីព ឱ្យនៅក្រោមការគ្រប់គ្រងរបស់ខ្លួន មានដូចជា គាំទ្រដល់ការបង្កើតសហជីពដែលគ្រប់គ្រងដោយអ្នកគ្រប់គ្រង ឬ គាំទ្រផ្នែកហិរញ្ញវត្ថុដល់សហជីព ឬ ដោយមធ្យោបាយផ្សេងទៀត ។

**សំណូមពរដែលលើកឡើងសំរាប់រោងចក្រ :**

| អ្នកគ្រប់គ្រង | ចំនួននិងភាគរយនៃរោងចក្រដែលមានសំណូមពរចំពោះបញ្ហានេះ (មិនអនុវត្ត) | ចំនួននៃរោងចក្រដែលធ្វើឱ្យល័ក្ខខ័ណ្ឌការងារប្រសើរភ្លាមៗមុននឹងរបាយការណ៍ឃ្លាំមើលសំរេចជាស្ថាពរ |
|---|---|---|
| ពុំគប្បីជ្រៀតជ្រែក សិទ្ធិរបស់កម្មករនិយោជិតក្នុងការបង្កើត និង ចូលរួមក្នុងសកម្មភាពរបស់សហជីព។ | ៤ (៨%) | 0 |

| អ្នកគ្រប់គ្រង | ចំនួននិងភាគរយនៃរោងចក្រដែលមានសំណួមពរចំពោះបញ្ហានេះ (មិនអនុវត្ត) | ចំនួននៃរោងចក្រដែលធ្វើឱ្យល័ក្ខខ័ណ្ឌការងារប្រសើរភ្លាមៗមុននឹងរបាយការណ៍ឃ្លាំមើលសំរេចជាស្ថាពរ |
|---|---|---|
| គប្បីធានាឱ្យប្រាកដថា កម្មករនិយោជិតមានសេរីភាពក្នុងការមិនចូលជាសមាជិករបស់សហជីព ។ | ១ (២%) | 0 |
| | | |
| គប្បីធានាឱ្យប្រាកដថា មិនមានការចាត់វិធានការណាមួយដែលអាចចាត់ទុកថាជាគោលបំណងដាក់សហជីព ឱ្យនៅក្រោមការគ្រប់គ្រងរបស់ខ្លួន។ | ២ (៤%) | 0 |
| | | |
| ពុំគប្បីកាត់ប្រាក់សំរាប់សហជីពពីប្រាក់ឈ្នួលរបស់កម្មករនិយោជិតទេ បើកម្មករនិយោជិតនោះពុំបានផ្តល់ការអនុញ្ញាតឱ្យកាត់ប្រាក់ឈ្នួល ។ | ១ (២%) | 0 |

ល័ក្ខខ័ណ្ឌដែលធ្វើឱ្យមានការកើនឡើងនូវសំណួមពរទាំងនេះមានដូចតទៅ ។ នៅក្នុងរោងចក្រចំនួន ២ ពុំមានសហជីព ឬ កម្មករនិយោជិតណានិយាយថា ពួកគេត្រូវបានហាមឃាត់មិនឱ្យបង្កើត ឬ ខ្លាចមិនហ៊ានបង្កើតសហជីពនោះទេ ។ នៅក្នុងរោងចក្រមួយ មានសហជីពមួយ ប៉ុន្តែកម្មករនិយោជិតខ្លាចមិនហ៊ានចូល ឬ ចូលរួមក្នុងសកម្មភាពនានារបស់សហជីព ។ នៅក្នុងរោងចក្រនេះ អ្នកគ្រប់គ្រងបានបណ្តេញមេដឹកនាំសហជីពឱ្យឈប់ធ្វើការ ហើយមិនបានឱ្យមេដឹកនាំសហជីពរូបនោះ ចូលធ្វើការងារឡើងវិញទេ ទោះបីជាមានការបង្គាប់បញ្ជាពីអធិការការងារឱ្យធ្វើដូច្នោះក៏ដោយ ។ (សំរាប់ពតិមានបន្ថែម សូមមើលការរើសអើសប្រឆាំងនឹងសហជីពនៅផ្នែកបន្ទាប់ ) ។ អ្នកគ្រប់គ្រងបានធ្វើបណ្តឹងសារទុក្ខទៅក្រសួងការងារ អំពីការបង្គាប់បញ្ជានេះ ។ កម្មករនិយោជិតនៅក្នុងរោងចក្រចំនួន ២ និយាយថា អ្នកគ្រប់គ្រងបានគ្រប់គ្រងសហជីព ។ នៅក្នុងរោងចក្រមួយ ក្នុងចំណោមរោងចក្រទាំងនេះ កម្មករនិយោជិតនិយាយថា ខ្លួនមានការលំបាកក្នុងការបដិសេធមិនចូលរួមសហជីព ហើយអ្នកគ្រប់គ្រងបានធ្វើការកាត់ប្រាក់វិភាគទានសំរាប់សហជីព ដោយពុំមានការឯកភាពពីពួកគេ ។ នៅក្នុងរោងចក្រដទៃទៀត កម្មករនិយោជិតនិយាយថា អ្នកគ្រប់គ្រងមិនអនុញ្ញាតឱ្យកម្មករនិយោជិតបង្កើតសហជីព (ឯករាជ្យ) មួយផ្សេងទៀតទេ ។

### ២.៣.២ ការរើសអើងប្រឆាំងសហជីព

ច្បាប់ ( មាត្រា ១២ ២៧៩ និង ២៩៣ ប្រកាស ៣០៥/០១) :

ត្រូវបានហាមឃាត់ចំពោះនិយោជកគ្រប់រូបមិនឱ្យយកការចូលជាសមាជិករបស់សហជីព ឬ ការចូលរួមក្នុងសកម្មភាពរបស់សហជីពនៃកម្មករនិយោជិត ដើម្បីធ្វើការសំរេចចិត្តក្នុងការជ្រើសរើសឱ្យចូលធ្វើការគ្រប់គ្រង និងការបែងចែកការងារ ការតំលើងឋានៈ ការផ្តល់ប្រាក់ឈ្នួល និងការផ្តល់ប្រយោជន៍ផ្សេងៗ ការដាក់វិធានខាងវិន័យ និងការបណ្តេញចេញ ។ សមាសភាពរបស់ថ្នាក់ដឹកនាំជាន់ខ្ពស់ចំនួន ៣ រូប នៃសហជីពដែលបានចុះបញ្ជីរួចក្នុងនោះរួមមានប្រធាន អនុប្រធាន និងលេខាធិការ អាចត្រូវបានគេបញ្ឈប់ពីការងារបាន លុះត្រាណាតែមានការយល់ព្រមពីអធិការដ្ឋានការងារ ។

**សំណូមពរដែលលើកឡើងសំរាប់រោងចក្រ :**

| អ្នកគ្រប់គ្រង | ចំនួននិងភាគរយនៃរោងចក្រដែលមានសំណូមពរចំពោះបញ្ហានេះ (មិនអនុវត្ត) | ចំនួននៃរោងចក្រដែលធ្វើឱ្យល័ក្ខខ័ណ្ឌការងារប្រសើរភ្លាមៗ មុននឹងរបាយការណ៍ឃ្លាំមើលសំរេចជាស្ថាពរ |
|---|---|---|
| ពុំគប្បីរើសអើងចំពោះកម្មករនិយោជិតណាម្នាក់ ដោយសារតែចូលជាសមាជិកសហជីព ឬ ចូលរួមក្នុងសកម្មភាពសហជីព។ | ៣ (៦%) | 0 |
| | | |
| គប្បីធ្វើទៅតាមច្បាប់ពេលដែលបញ្ចប់មេដឹកនាំសហជីព ឬ បេក្ខជនសំរាប់មេដឹកនាំសហជីពពីការងារ ។ | ១ (២%) | 0 |

ល័ក្ខខ័ណ្ឌដែលធ្វើឱ្យមានការកើនឡើងនូវសំណូមពរទាំងនេះមានដូចតទៅ : នៅក្នុងរោងចក្រ ១ អ្នកគ្រប់គ្រងបានបណ្តេញមេដឹកនាំសហជីពចេញពីការងារ ហើយអធិការការងារបង្គាប់បញ្ជាឱ្យអ្នកគ្រប់គ្រងទទួលមេដឹកនាំសហជីពរូបនោះឱ្យចូលធ្វើការវិញបន្ទាប់ពីរកឃើញថាមេដឹកនាំនោះពុំបានប្រព្រឹត្តកំហុសធ្ងន់ ប៉ុន្តែអ្នកគ្រប់គ្រងពុំបានធ្វើតាមទេ។ អ្នកគ្រប់គ្រងបានធ្វើបណ្តឹងសារទុក្ខទៅក្រសួងការងារ អំពីការបង្គាប់បញ្ជានេះ ។ នៅក្នុងរោងចក្រមួយផ្សេងទៀតកម្មករនិយោជិតនិយាយថា មេក្រុមបានប្រាប់ពួកគេថា ពួកគេនឹងត្រូវបញ្ឈប់ពីការងារ បើពួកគេហ៊ានចូលរួមក្នុងសកម្មភាពរបស់សហជីព ទោះបីជាពុំទាន់មានកម្មករនិយោជិតណាមួយ ត្រូវបានបញ្ឈប់ពីការងារនៅពេលចុះធ្វើការឃ្លាំមើលក៏ដោយ ។ នៅក្នុងរោងចក្រទី ៣ កម្មករនិយោជិតនិយាយថា អ្នកគ្រប់គ្រងបង្ខំឱ្យមេដឹកនាំសហជីពលាឈប់ពីការងារដោយហេតុផលថា គាត់បានទាមទារឱ្យអ្នកគ្រប់គ្រងផ្តល់ប្រាក់ឧបត្ថម្ភសំរាប់អាហារមួយពេលសំរាប់កម្មករនិយោជិតដែលធ្វើការបន្ថែមម៉ោង ។

### ២.៣.៣ ប្រតិភូបុគ្គលិក

ច្បាប់ ( មាត្រា ២៨៣-២៨៥ ២៨៧ ២៨៨ ២៩១-២៩៣ និង ២៩៦ ប្រកាស ២៨៦/០១) :

នៅគ្រប់សហគ្រាស ដែលជាធម្មតាមានប្រើកម្មករនិយោជិតយ៉ាងតិចប្រាំបីនាក់ និយោជករៀបចំបោះឆ្នោតជ្រើសរើសប្រតិភូបុគ្គលិក បន្ទាប់ពីសហគ្រាសដំណើរការបានរយៈពេល ៦ ខែ ។ ចំនួនប្រតិភូបុគ្គលិក និង ជំនួយប្រតិភូបុគ្គលិកត្រូវកំណត់តាមសមាមាត្រនៃចំនួនកម្មករនិយោជិតក្នុងគ្រឹះស្ថាន ។

| ចំនួនកម្មករនិយោជិត | ចំនួនប្រតិភូបុគ្គលិក ( រួមទាំងជំនួយប្រតិភូបុគ្គលិក) |
|---|---|
| ១-៧ នាក់ | 0 |
| ៨-៥0 នាក់ | ១ (១) |
| ៥១-១00 នាក់ | ២ (២) |
| ១00+ នាក់ | ប្រតិភូពេញសិទ្ធិបន្ថែមម្នាក់ និងប្រតិភូជំនួយបន្ថែមម្នាក់ សំរាប់រាល់ក្រុមនៃកម្មករនិយោជិតដែលមានចំនួន ១00 នាក់ ។ |

ក្នុងការរៀបចំបោះឆ្នោតប្រតិភូបុគ្គលិក អ្នកគ្រប់គ្រងត្រូវ :

- ពិគ្រោះយោបល់ជាមួយសហជីពមួយ (ច្រើន) មុននឹងធ្វើការបោះឆ្នោត ។
- អនុញ្ញាតឱ្យសហជីពដែលមានភាពជាតំណាងឱ្យតែងតាំងបេក្ខជន ។
- បិទផ្សាយនីតិវិធីបោះឆ្នោត និង បញ្ជីឈ្មោះបេក្ខជនឈរឈ្មោះ យ៉ាងតិច ៣ ថ្ងៃមុនបោះឆ្នោត ។
- ធ្វើការបែងចែក ប៉ុន្តែស្រដៀងគ្នានឹងការបោះឆ្នោតសំរាប់ប្រតិភូបុគ្គលិក និង ជំនួយប្រតិភូ
- ធានាឱ្យប្រាកដថា បង្កើតក្រុមបោះឆ្នោតប្រតិភូបុគ្គលិក ដោយឡែកពីគ្នាសំរាប់ (១)កម្មករគ្មានជំនាញ និង (២)កម្មករមានជំនាញ អ្នកដឹកនាំ អ្នកបច្ចេកទេស និង អ្នករដ្ឋបាល នៅក្នុងសហគ្រាសដែលមានបុគ្គលិកយ៉ាងតិច ៥១ នាក់ ។
- រៀបចំ និង ផ្តល់ប្រាក់ឈ្នួលពេលធ្វើការបោះឆ្នោត ។
- រៀបចំបោះឆ្នោតយ៉ាងហោចណាស់ ១៥ ថ្ងៃ មុនថ្ងៃចប់អាណត្តិរបស់ប្រតិភូបុគ្គលិក ។
- រៀបចំបោះឆ្នោតក្នុងម៉ោងធ្វើការធម្មតា ។
- ផ្តល់ពេលវេលាសំរាកចំនួន ២ ម៉ោង ដល់កម្មករនិយោជិតមុនការបោះឆ្នោត ។
- ធានាឱ្យប្រាកដថា ការបោះឆ្នោតត្រូវបានកំណត់ធ្វើឡើងតាមរយៈការបោះឆ្នោតដោយសំងាត់ និង
- ជូនដំណឹងដល់អធិការការងារអំពីលទ្ធផលបោះឆ្នោតក្នុងកំឡុងពេល ៨ ថ្ងៃ ។

អ្នកគ្រប់គ្រងត្រូវផ្តល់ដល់ប្រតិភូបុគ្គលិកនូវរយៈពេល ២ ម៉ោង (ដោយមានប្រាក់ឈ្នួល) ក្នុងមួយសប្តាហ៍ ការិយាល័យ បន្ទប់ប្រជុំ ព្រមទាំងសំភារៈសំរាប់ធ្វើការដើម្បីអនុវត្តភារកិច្ចរបស់ខ្លួន ។ អ្នកគ្រប់គ្រងអាចបណ្តេញប្រតិភូបុគ្គលិកឱ្យឈប់ធ្វើការបាន បន្ទាប់ពីទទួលបានការអនុញ្ញាតពីអធិការការងារ ។

**សំណូមពរដែលលើកឡើងសំរាប់រោងចក្រ :**

| អ្នកគ្រប់គ្រង | ចំនួននិងភាគរយនៃរោងចក្រដែលមានសំណូមពរចំពោះបញ្ហានេះ (មិនអនុវត្ត) | ចំនួននៃរោងចក្រដែលធ្វើឱ្យល័ក្ខខ័ណ្ឌការងារប្រសើរភ្លាមៗ មុននឹងរបាយការណ៍ឃ្លាំមើលសំរេចជាស្ថាពរ |
|---|---|---|
| គប្បីពិគ្រោះយោបល់ជាមួយនឹងតំណាងកម្មករនិយោជិត មុននឹងរៀបចំការបោះឆ្នោតជ្រើសរើសប្រតិភូបុគ្គលិក ។ | ៥ (១០%) | 0 |
| | | |
| គប្បីរៀបចំការបោះឆ្នោតជ្រើសរើសប្រតិភូបុគ្គលិកសារជាថ្មី ។ | ១២ (២៤%) | ១ |
| | | |
| គប្បីធានាឱ្យប្រាកដថា ការបោះឆ្នោតជ្រើសរើសប្រតិភូបុគ្គលិក អនុលោមទៅតាមនីតិវិធី និង បទបញ្ជាជាធរមាន ។ | ៣៤ (៦៨%) | 0 |
| | | |
| គប្បីធានាឱ្យប្រាកដថា ចំនួនប្រតិភូបុគ្គលិកដែលត្រូវជ្រើសរើស ត្រូវអនុលោមទៅតាមច្បាប់ ។ | ៤ (៨%) | 0 |
| | | |
| គប្បីបិទផ្សាយ លទ្ធផលបោះឆ្នោតប្រតិភូបុគ្គលិកនៅកន្លែងធ្វើការ ។ | ៨ (១៦%) | 0 |
| | | |
| គប្បីធានាឱ្យប្រាកដថា ប្រតិភូបុគ្គលិកត្រូវបានផ្តល់ឱ្យនូវរយៈពេល ២ ម៉ោងក្នុងមួយសប្តាហ៍ និង ការិយាល័យ ព្រមទាំងសំភារៈសំរាប់ធ្វើការដើម្បីអនុវត្តភារកិច្ចរបស់ខ្លួន ។ | ៣៧ (៧៤%) | 0 |
| | | |
| គប្បីបណ្តេញប្រតិភូបុគ្គលិកចេញពីការងារដោយអនុលោមទៅតាមនីតិវិធីនៃច្បាប់តែប៉ុណ្ណោះ ។ | ១ (២%) | 0 |
| | | |
| គប្បីផ្តល់នូវច្បាប់ស្តីពីការងារដល់ប្រតិភូបុគ្គលិក នៅពេលដែលពួកគេស្នើសុំ ។ | ១ (២%) | 0 |

| អ្នកគ្រប់គ្រង | ចំនួននិងភាគរយនៃរោងចក្រដែលមានសំណូមពរចំពោះបញ្ហានេះ (មិនអនុវត្ត) | ចំនួននៃរោងចក្រដែលធ្វើឱ្យល័ក្ខខ័ណ្ឌការងារប្រសើរភ្លាមៗ មុននឹងរបាយការណ៍ឃ្លាំមើលសំរេចជាស្ថាពរ |
|---|---|---|
| គប្បីបង្កើតក្រុមបោះឆ្នោតប្រតិភូបុគ្គលិកដោយឡែកពីគ្នាសំរាប់កម្មករមានជំនាញ និងកម្មករគ្មានជំនាញ ។ | ១ (២%) | 0 |
| | | |
| គប្បីជំនួសប្រតិភូបុគ្គលិកដែលលាឈប់ពីការងារ ដោយជំនួយការប្រតិភូបុគ្គលិក ។ | ២ (៤%) | 0 |

## ២.៣.៤ មន្ត្រីទំនាក់ទំនង

ច្បាប់ (សារាចរ ០២១/៩៩) :

សហគ្រាសនីមួយៗ ត្រូវរៀបចំឱ្យមានបុគ្គលិកទំនាក់ទំនងឯករាជ្យយ៉ាងតិចមួយរូបសំរាប់ទទួលខុសត្រូវ ដោះស្រាយបណ្តឹងសារទុក្ខផ្សេងៗ ដែលកម្មករនិយោជិតបានលើកឡើង ។ មុននឹងតែងតាំងមន្ត្រីទំនាក់ទំនង សហគ្រាសត្រូវពិគ្រោះយោបល់នឹងតំណាងកម្មករ ដើម្បីស្វែងរកការយល់ព្រមក្នុងការជ្រើសរើសមនុស្សម្នាក់ ដែលឯករាជ្យ និងអព្យាក្រិត ។ ការតែងតាំងនេះត្រូវទទួលស្គាល់ដោយក្រសួងការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ ។ បើសិនមន្ត្រីទំនាក់ទំនងនេះ មិនអាចដោះស្រាយជម្លោះអោយកម្មករនិយោជិតបានទេ មន្ត្រីនេះត្រូវជូនដំណឹងដល់អ្នកគ្រប់គ្រង ហើយបន្ទាប់មកនិយោជកត្រូវជួបជាមួយកម្មករនិយោជិត ដោយប្រហែលជាអាចមានការចូលរួមពីប្រតិភូបុគ្គលិក ឬ តំណាងសហជីពមួយរូប ។

**សំណូមពរដែលលើកឡើងសំរាប់រោងចក្រ :**

| អ្នកគ្រប់គ្រង | ចំនួននិងភាគរយនៃរោងចក្រដែលមានសំណូមពរចំពោះបញ្ហានេះ (មិនអនុវត្ត) | ចំនួននៃរោងចក្រដែលធ្វើឱ្យល័ក្ខខ័ណ្ឌការងារប្រសើរភ្លាមៗ មុននឹងរបាយការណ៍ឃ្លាំមើលសំរេចជាស្ថាពរ |
|---|---|---|
| គប្បីតែងតាំងបុគ្គលិកទំនាក់ទំនង ឯករាជ្យមួយរូប ។ | ៣២ (៦៤%) | ២ |
| | | |
| គប្បីពិភាក្សាជាមួយកម្មករនិយោជិតជាមុនសិន មុនពេលជ្រើសតាំងបុគ្គលិកទំនាក់ទំនងឯករាជ្យ ។ | ១ (២%) | 0 |
| | | |
| ជូនដំណឹងដល់កម្មករនិយោជិត អំពីការតែងតាំងបុគ្គលិកទំនាក់ទំនង ។ | ៧ (១៤%) | 0 |

## ២.៣.៥ វិវាទការងាររួម (ក្នុងកំឡុងពេល ១២ខែ មុនការឃ្លាំមើល)

ច្បាប់ (មាត្រា ៣០២-៣០៨ ៣១៥ ប្រកាស ១៤៤/៩៧) :

វិវាទការងាររួម គឺជាវិវាទដែលកើតឡើងពេលដែលកម្មករនិយោជិតមួយក្រុម ឬ សហជីពមួយ តវ៉ាប្រឆាំងនឹងល័ក្ខខ័ណ្ឌការងារ ខទាំងឡាយនៃការជួលឱ្យធ្វើការងារ ឬ ការហាមឃាត់លើសិទ្ធិរបស់ពួកគេ មានដូចជាសិទ្ធិក្នុងការចូលរួមបង្កើតអង្គការវិជ្ជាជីវៈ ។ បើពុំមានបទបញ្ញត្តិចែងអំពីការដោះស្រាយជម្លោះ នៅក្នុងកិច្ចព្រមព្រៀងរួមទេ ភាគីជម្លោះត្រូវជូនដំណឹងអំពីវិវាទការងាររួម ទៅអធិការការងារក្នុងខេត្ត-ក្រុង ដើម្បីធ្វើការសម្រុះសម្រួល ។

ក្រសួងការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ ត្រូវតែងតាំងអ្នកផ្សះផ្សាម្នាក់ ដែលត្រូវដោះស្រាយជម្លោះនេះ ក្នុងរយៈពេល ១៥ ថ្ងៃ ។ ប្រសិនបើកម្មករនិយោជិត និងអ្នកគ្រប់គ្រងមិនអាចព្រមព្រៀងគ្នា អ្នកផ្សះផ្សាត្រូវធ្វើរបាយការណ៍មួយអំពីលទ្ធផល និង ត្រូវបញ្ជូនទៅក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ដែលបន្ទាប់មកបញ្ជូនជម្លោះនោះទៅកាន់ក្រុមប្រឹក្សាអាជ្ញាកណ្តាល ។ កិច្ចព្រមព្រៀងផ្សះផ្សា មានប្រសិទ្ធិភាពដូចគ្នានឹងកិច្ចព្រមព្រៀងរួមដែរ ។

**សំណូមពរដែលលើកឡើងសំរាប់រោងចក្រ :**

| អ្នកគ្រប់គ្រង | ចំនួននិងភាគរយនៃរោងចក្រដែលមានសំណូមពរចំពោះបញ្ហានេះ (មិនអនុវត្ត) | ចំនួននៃរោងចក្រដែលធ្វើឱ្យល័ក្ខខ័ណ្ឌការងារប្រសើរភ្លាមៗមុននឹងរបាយការណ៍ឃ្លាំមើលសំរេចជាស្ថាពរ |
|---|---|---|
| គប្បីអនុវត្តកិច្ចព្រមព្រៀងស្តីអំពីការផ្សះផ្សាវិវាទ ឱ្យបានពេញលេញ ។ | ៩ (១៨%) | ១ |
| | | |
| បិទផ្សាយកិច្ចព្រមព្រៀងស្តីពីការផ្សះផ្សាវិវាទនៅកន្លែងធ្វើការ ។ | ២ (៤%) | 0 |

មានវិវាទការងាររួមមួយ រវាងអ្នកគ្រប់គ្រង និង កម្មករនិយោជិត នៅក្នុងរោងចក្រចំនួន ១១ ។ រោងចក្រចំនួន ៨ ក្នុងចំណោមរោងចក្រទាំងនេះ មានវិវាទការងាររួមដែលក្លាយទៅជាកូដកម្ម ។ មានវិវាទការងាររួម ៣ ដងនៅក្នុងរោងចក្រចំនួន ២ ដែលបានក្លាយទៅជាកូដកម្ម ២ លើក នៅក្នុងរោងចក្រទាំង ២ នេះ។ វិវាទការងាររួមចំនួន ៥ ត្រូវបានផ្សះផ្សា ហេតុដូច្នេះហើយបានធ្វើកុំឱ្យកូដកម្មកើតមានឡើង ។

២.៣.៦ កូដកម្ម / ឡុកអៅ ( រយៈពេល ១២ខែកន្លងមក ដោយគិតនៅមុនពេលចុះធ្វើការតាមឃ្លាំមើល)

ច្បាប់ ( មាត្រា ៣១៨-៣២០ ៣២៣-៣២៥ ៣៣០-៣៣៧) :

កូដកម្មកើតឡើងនៅពេលដែលកម្មករនិយោជិតមួយក្រុមឈប់ធ្វើការ ដើម្បីទាមទារឱ្យអ្នកគ្រប់គ្រងយល់ព្រមធ្វើតាមការទាមទារនានាដែលពាក់ព័ន្ធនឹងការងារក្នុងល័ក្ខខ័ណ្ឌដើម្បីចូលធ្វើការវិញ ។ កម្មករនិយោជិត អាចប្រើប្រាស់សិទ្ធិធ្វើកូដកម្មនេះបាន នៅពេលដែលមានការព្យាយាមដោះស្រាយវិវាទតាមរយៈ ការចរចា ការផ្សះផ្សា និង អាជ្ញាកណ្តាលហើយ ។

មុននឹងធ្វើកូដកម្ម កម្មករនិយោជិតត្រូវតែគោរពតាមនីតិវិធីដែលមានចែងនៅក្នុងលក្ខន្តិកៈរបស់សហជីព គឺតំរូវឱ្យសមាជិកសហជីពធ្វើសេចក្តីសំរេចចិត្តតាមការបោះឆ្នោតជាសំងាត់ ។ សហជីពក៏ត្រូវផ្តល់ការជូនដំណឹង អំពីកូដកម្មដល់រោងចក្រ និង កកបវ ជាមុនចំនួន ៧ ថ្ងៃផងដែរ ។ កូដកម្មត្រូវប្រព្រឹត្តទៅដោយសន្តិវិធី ។ អំពើហឹង្សាត្រូវចាត់ទុកជាកំហុសធ្ងន់ ។ ត្រូវហាមឃាត់មិនឱ្យនិយោជក ដាក់ទណ្ឌកម្មអ្វីមួយទៅលើកម្មករនិយោជិត ដោយសារតែការចូលរួមធ្វើកូដកម្មនោះឡើយ លុះត្រាតែនិយោជកអាចបង្ហាញឱ្យឃើញថា កម្មករនិយោជិតនោះបានប្រព្រឹត្តកំហុសធ្ងន់ពេលធ្វើកូដកម្ម ។

ឡុកអៅ គឺជាការបិទសហគ្រាសទាំងមូល ឬ មួយផ្នែក ដោយនិយោជក ក្នុងឱកាសដែលមានវិវាទការងារ ។ សិទ្ធិធ្វើឡុកអៅរបស់និយោជក ត្រូវអនុវត្តតាមបទបញ្ញត្តិទាំងឡាយដូចគ្នានឹងសិទ្ធិធ្វើកូដកម្មដែរ ។

**សំណូមពរដែលលើកឡើងសំរាប់រោងចក្រ :** ពុំមាន (ប៉ុន្តែសូមមើលនៅផ្នែកវិវាទការងាររួមសំរាប់សំណូមពរ ដែលពាក់ព័ន្ធនឹងកិច្ចព្រមព្រៀងស្តីពីការផ្សះផ្សាវិវាទ)

មានកូដកម្មមួយដង នៅរោងចក្រចំនួន ១២ និងមានកូដកម្មពីរដងនៅរោងចក្រចំនួន ៣ នៅក្នុងអំឡុងពេល ១២ ខែ មុននឹងមានការចុះពិនិត្យមើលលើកដំបូង ។ កូដកម្មអសន្តិវិធីមួយបានកើតឡើង នៅក្នុងរោងចក្រមួយ ។ គ្មានកូដកម្មណាមួយត្រូវបានរៀបចំធ្វើដោយអនុលោមតាមនីតិវិធី និងតាមបទបញ្ជាជាធរមានឡើយ ។

ក្នុងចំណោមរោងចក្រចំនួន ៧ កម្មករកូដកម្មទាមទារឱ្យអ្នកគ្រប់គ្រង :

- ទូទាត់ប្រាក់ឈ្នួលស្របតាមផ្លូវច្បាប់ ។
- ធានាឱ្យប្រាដកថា ការងារបន្ថែមម៉ោង គឺផ្អែកលើគោលការណ៍ស្ម័គ្រចិត្ត ។

ក្នុងចំណោមរោងចក្រចំនួន ៤ កម្មករកូដកម្មទាមទារឱ្យអ្នកគ្រប់គ្រង :

- ទូទាត់ប្រាក់ឈ្នួលឱ្យបានទៀងពេល ។
- លុបបំបាត់ចោលឥរិយាបថមិនសមរម្យ ។

ក្នុងចំណោមរោងចក្រចំនួន ៣ កម្មករកូដកម្មទាមទារឱ្យអ្នកគ្រប់គ្រង :

- ដោះស្រាយវិវាទបុគ្គល ។

ក្នុងចំណោមរោងចក្រចំនួន ២ កម្មករកូដកម្មទាមទារឱ្យអ្នកគ្រប់គ្រង :

- តម្លើងតំលៃដេរស៊ីបុង ។
- ទូទាត់ប្រាក់ឈ្នួលឱ្យកម្មករសាកល្បងបានត្រឹមត្រូវ ។
- ទូទាត់ប្រាក់រង្វាន់ធ្វើការទៀតទាត់ ពេលណាកម្មករនិយោជិតអវត្តមានដោយមានការអនុញ្ញាតត្រឹមត្រូវ ។
- ផ្តល់ប្រាក់ឧបត្ថមបាយចំនួន ១000 រៀល ។
- បង្កើតប័ណ្ណបើកប្រាក់ ។
- ផ្តល់ការឈប់សំរាកដោយជំងឺដែលមានប្រាក់ឈ្នួល ។
- ផ្តល់ការឈប់សំរាកពិសេសដោយមានប្រាក់ឈ្នួល ។
- ធានាឱ្យប្រាកដថា កម្មករនិយោជិតមានសិទ្ធិសេរីភាព ក្នុងការបង្កើតអង្គការវិជ្ជាជីវៈ ។
- បញ្ឈប់ និង ដាក់វិន័យដល់កម្មករនិយោជិត ត្រូវធ្វើឡើងដោយអនុលោមតាមនីតិវិធីក្នុងបទបញ្ជាផ្ទៃក្នុង ។
- បណ្តេញកម្មករនិយោជិតចេញពីការងារត្រូវធ្វើឡើងដោយអនុលោមតាមផ្លូវច្បាប់ ។
- ជួលកម្មករនិយោជិតដែលបានបណ្តេញចេញពីការងារឡើងវិញ ។
- បង្កើត ឬ ធ្វើឱ្យគិលានដ្ឋានបានប្រសើរឡើង ។

ក្នុងរោងចក្រ ១ កម្មករកូដកម្មទាមទារឱ្យអ្នកគ្រប់គ្រង :

- ជូនពត៌មានដល់កម្មករនិយោជិតអំពីតំលៃដេរស៊ីបុងជាមុន ។
- ផ្តល់ប្រាក់ឈ្នួលដល់កម្មករនិយោជិតដែលទទួលប្រាក់ឈ្នួលតាមបរិមាណផលិតផល ។
- ផ្តល់ប្រាក់ឈ្នួលក្នុងកំឡុងពេលម៉ោងធ្វើការធម្មតា ។
- ផ្តល់ប្រាក់ឈ្នួល ៥0% ដល់កម្មករនិយោជិត ពេលមានការព្យួរការងារ ។
- ផ្តល់ដល់កម្មករនិយោជិតនូវប្រាក់ឈ្នួល ព្រមទាំងតាវកាលិកសំរាប់គ្រោះថ្នាក់ការងារ ឬ ជម្ងឺវិជ្ជាជីវៈ ។
- ប្តូរម៉ោងធ្វើការ ។
- ផ្តល់ការសំរាកលំហែមាតុភាពដោយអនុលោមតាមច្បាប់ ។
- ជួលតំណាងសហជីពដែលបានបណ្តេញចេញពីការងារឱ្យចូលធ្វើការវិញ ។
- រៀបចំបោះឆ្នោតប្រតិភូបុគ្គលិក ។
- ផ្តល់ដល់ប្រតិភូបុគ្គលិកនូវ រយៈពេល ២ ម៉ោងក្នុងមួយសប្តាហ៍ ដើម្បីអនុវត្តភារកិច្ចរបស់ខ្លួន។
- ផ្តល់កែវ ។

- ធ្វើឱ្យបង្គន់ប្រសើរឡើង ។
- ផ្តល់ទឹកស្អាត សំរាប់បរិភោគអោយបានគ្រប់គ្រាន់ ។
- អនុញ្ញាត្តិឱ្យកម្មករនិយោជិតប្រើស្បែកជើងរបស់គេនៅកន្លែងធ្វើការ ។

កូដកម្មទាំងអស់លើកលែងតែមួយចេញ ត្រូវបានដោះស្រាយបានតាមរយៈកិច្ចព្រមព្រៀងផ្សះផ្សា ។ អ្នកគ្រប់គ្រង និង កម្មករនិយោជិត បានដោះស្រាយកូដកម្មរបស់ពួកគេដូចខាងក្រោម :

| | |
|---|---|
| កូដកម្មត្រូវបានដោះស្រាយដោយមានជំនួយពីអធិការការងារ ។ | ៩ |
| កូដកម្មត្រូវបានដោះស្រាយដោយពុំមានជំនួយពីខាងណាសោះ ។ | ៣ |
| កូដកម្មត្រូវបានដោះស្រាយដោយមានជំនួយទាំងពីរ អាជ្ញាធរមូលដ្ឋាន និងអធិការការងារ ។ | ១ |
| កូដកម្មត្រូវបានដោះស្រាយដោយមានជំនួយពី GMAC និង អធិការការងារ ។ | ១ |
| ពុំមានលក្ខណៈច្បាស់លាស់ថាតើកូដកម្មនោះត្រូវបានដោះស្រាយតាមរបៀបណា ។ | ១ |

### ២.៣.៧ វិវាទបុគ្គល (រយៈពល ១២ខែកន្លងមក ដោយគិតនៅមុនពេលចុះធ្វើការតាមឃ្លាំមើល)

**ច្បាប់ (មាត្រា ៣00 និង ៣០១) :**

វិវាទបុគ្គល គឺជាវិវាទដែលកើតមានឡើងរវាងនិយោជក និងកម្មករនិយោជិតម្នាក់ ឬ ច្រើននាក់ជាលក្ខណៈបុគ្គល ហើយដែលទាក់ទងនឹងការបកស្រាយ ឬ ការអនុវត្តន៍ប្រការទាំងឡាយនៃកិច្ចសន្យាការងារ ប្រការទាំងឡាយនៃកិច្ចព្រមព្រៀងរួម ឬ បទបញ្ជាព្រមទាំងច្បាប់ជាធរមានផងដែរ ។ មុននឹងប្តឹងទៅតុលាការ គ្រប់រឿងវិវាទបុគ្គលអាចឱ្យភាគីណាមួយផ្តើមគំនិតនាំយកទៅប្តឹងអធិការការងារនៃខេត្ត-ក្រុងរបស់ខ្លួន ដើម្បីធ្វើការផ្សះផ្សាជាមុនសិន ។

**សំណូមពរដែលលើកឡើងសំរាប់រោងចក្រ : ពុំមាន**

រោងចក្រចំនួន ៥ មានវិវាទបុគ្គល ។ វិវាទបុគ្គលចំនួន ៣ ក្នុងចំណោមវិវាទទាំងនេះបាននាំឱ្យកើតមានកូដកម្ម ។ មូលហេតុដែលបណ្តាលឱ្យមានវិវាទបុគ្គលទាំងនេះ រួមមានការបណ្តេញមេដឹកនាំសហជីព និង កម្មករឱ្យឈប់ពីការងារ ការយល់ច្រឡំលើការទូទាត់ប្រាក់ឈ្នួល និង ការមិនយល់ស្របគ្នាលើអវត្តមាន ដែលពុំមានការអនុញ្ញាតត្រឹមត្រូវ ។

## សេចក្តីសន្និដ្ឋានបញ្ចប់

ការបោះពុម្ពផ្សាយរបាយការណ៍លើកទី ១១ នេះ រោងចក្រកាត់ដេរសំលៀកបំពាក់ទាំងអស់នៅក្នុងប្រទេសកម្ពុជា ត្រូវបានបញ្ចូលទៅក្នុងរបាយការណ៍យ៉ាងហោចណាស់បានម្តង លើកលែងតែរោងចក្រមួយចំនួន ដែលទើបបង្កើតឡើងក្នុងពេលថ្មីៗនេះ ។ ជាថ្មីម្តងទៀតរបាយការណ៍នេះ បានបង្ហាញពីបញ្ហាខ្លះក្នុងការទូទាត់ប្រាក់ខែឱ្យបានត្រឹមត្រូវ និងការធ្វើការបន្ថែមម៉ោងនៅជាបញ្ហាធំនៅឡើយ ។ រោងចក្រខ្លះទៀតមានបញ្ហា ពាក់ព័ន្ធនឹងសេរីភាពខាងវិជ្ជាជីវៈ និងការរើសអើស ។ រោងចក្រចំនួន ៤ ដែលគ្របដណ្តប់ក្នុងរបាយការណ៍នេះ ជួលក្មេងក្រោមអាយុឱ្យធ្វើការ ។ ការងារដោយបង្ខំពុំត្រូវបានរកឃើញថាមានកើតឡើងនៅក្នុងរោងចក្រណាមួយនោះទេ ។ ក្រុមរោងចក្រនេះ មានការគោរពច្បាប់ក្នុងកំរិតទាបមួយគួរឱ្យគត់សំគាល់ ពោលគឺភាគច្រើនដោយសារតែរបាយការណ៍នេះប្រមូលពតិមានក្នុងអំឡុងពេលការចុះពិនិត្យមើលលើកដំបូង ។ ជាធម្មតារោងចក្រ ធ្វើការកែប្រែល័ក្ខខ័ណ្ឌការងារឱ្យប្រសើរឡើង បន្ទាប់ពីទទួលបានរបាយការណ៍ចុះពិនិត្យមើលលើកដំបូង និង រោងចក្រទាំងនោះបន្តការកែប្រែតទៅទៀតក្នុងពេលបញ្ជាក់បង្ហាញដោយការចុះពិនិត្យតាមដានជាបន្តបន្ទាប់មកទៀត ។

អង្គការពលកម្មអន្តរជាតិនឹងបន្តធ្វើការជាមួយគ្រប់ភាគីពាក់ព័ន្ធទាំងអស់ ដើម្បីនាំមកនូវការលើកស្ទួយល័ក្ខខ័ណ្ឌការងារឱ្យប្រសើរឡើង ។ បច្ចុប្បន្ននេះ គំរោងរោងចក្រកាន់តែប្រសើរនៅកម្ពុជា កំពុងអនុវត្តប្រព័ន្ធគ្រប់គ្រងពតិមាន(IMS)តាមវេបសាយ ដើម្បីរៀបចំចាត់ចែងពតិមានដែលប្រមូលបានដោយអ្នកឃ្លាំមើល និង ដើម្បីធ្វើជារបាយការណ៍ផ្សេងៗសំរាប់អ្នកគ្រប់គ្រង និង ដៃគូសង្គមនានា ។ ពេលណាដែលប្រព័ន្ធនេះត្រូវបានដំណើរការ រោងចក្រនឹងអាចងាយស្រួលធ្វើការវាយតំលៃបានដោយខ្លួនឯងលើការអនុវត្តន៍ផ្សេងៗ ពាក់ព័ន្ធនឹងវិស័យកាត់ដេរសំលៀកបំពាក់ និង វាយនភ័ណ្ឌទាំងមូល ។ បន្ថែមពីលើនេះ រោងចក្រនឹងអាចទទួលរបាយការណ៍ចុះពិនិត្យមើលលើកដំបូង និង ចុះពិនិត្យតាមដានជាភាសាខ្មែរ អង់គ្លេស និង ចិនបាន ។ ការនេះនឹងរឹតតែធ្វើឱ្យមានភាពងាយស្រួលសំរាប់ភាគីពាក់ព័ន្ធទាំងអស់ ក្នុងការយល់ដឹងពីសិទ្ធិ និង ភារកិច្ចរបស់ខ្លួនឱ្យកាន់តែច្បាស់ ថែមទៀតដែលមានចែងនៅក្នុងច្បាប់ការងារ ។

* * *

# សេចក្តីថ្លែងការណ៍របស់គណៈកម្មការប្រឹក្សាគំរោង (PAC)
# ស្តីពី
# ការចេញផ្សាយរបាយការណ៍សំយោគលើកទី ១១
# របស់អង្គការពលកម្មអន្តរជាតិ (ILO) ស្តីពីស្ថានភាពនៃល័ក្ខខ័ណ្ឌការងារ
# ក្នុងវិស័យវាយនភ័ណ្ឌ និងសំលៀកបំពាក់នៅកម្ពុជា

១. នៅថ្ងៃទី ១២ ខែឧសភា ឆ្នាំ២០០៥ គណៈកម្មការប្រឹក្សាគំរោង របស់គំរោងរោងចក្រកាន់តែប្រសើរនៅកម្ពុជា[២] នៃអង្គការពលកម្មអន្តរជាតិ បានជួបប្រជុំនៅទីក្រុងភ្នំពេញដើម្បីពិនិត្យមើល និង ផ្តល់ការយល់ព្រមទៅលើរបាយការណ៍សំយោគលើកទី ១១ របស់អង្គការពលកម្មអន្តរជាតិស្តីពីស្ថានភាពនៃល័ក្ខខ័ណ្ឌការងារនៅក្នុងវិស័យកាត់ដេរនៅកម្ពុជា គណៈកម្មការប្រឹក្សាគំរោងមានអ្នកតំណាងបីរូប មកពីរាជរដ្ឋាភិបាលកម្ពុជា សមាគមរោងចក្រកាត់ដេរនៅកម្ពុជា និងចលនាសហជីពកម្ពុជា ។

២. សមាជិកគណៈកម្មការប្រឹក្សាគំរោងស្វាគមន៍នូវការចេញផ្សាយរបាយការណ៍នេះ ហើយជាថ្មីម្តងទៀតបានសំដែងនូវការកោតសរសើរដល់បុគ្គលិករបស់គំរោងអង្គការពលកម្មអន្តរជាតិ ដែលបានបន្តប្រើប្រាស់នូវវិធីសាស្ត្រដ៏ត្រឹមត្រូវ និងហ្មត់ចត់នៅក្នុងការធ្វើការវាយតំលៃរបស់ខ្លួន ។

៣. យើងជឿជាក់ថា ការសំរេចចិត្តរបស់គណៈកម្មការប្រឹក្សាគំរោង ក្នុងការគាំទ្រដល់ កម្មវិធីអង្គការពលកម្មអន្តរជាតិ បាននាំមកនូវផលប្រយោជន៍ជាវិជ្ជមានដល់គ្រប់ភាគីទាំងអស់នៅកម្ពុជា និង បាននាំមកនូវល័ក្ខខ័ណ្ឌការងារកាន់តែល្អប្រសើរ និង ការគោរពសិទ្ធិរបស់កម្មករនិយោជិតកាន់តែប្រសើរ ។ យើងសង្ឃឹមថាកិច្ចការនេះនឹងនាំអោយមានផលិតភាពខ្ពស់ជាងមុនក្នុងពេលអនាគត ។

៤. យើងកត់សំគាល់ថារបាយការណ៍នេះគ្របដណ្តប់រោងចក្រថ្មីៗចំនួន ៥០ ដែលត្រូវបានធ្វើទស្សនៈកិច្ចជាលើកដំបូង ។ ការរំលោភបំពានច្បាប់ស្តីពីការងារនៅក្នុងចំណោមរោងចក្រទាំងនេះ គឺមានកំរិតខ្ពស់ជាងនៅក្នុងចំណោមរោងចក្រដែលបានធ្វើការជាមួយគំរោងអស់រយៈពេលជាយូរមកហើយនោះ ។ យើងអំពាវនាវដល់រោងចក្រទាំងនេះ អោយចាត់វិធានការណ៍ជាបន្ទាន់ក្នុងការអនុវត្តន៍តាមការផ្តល់យោបល់ និង កែលំអល័ក្ខខ័ណ្ឌការងារអោយស្របទៅតាមច្បាប់ស្តីពីការងារ ។

[២] កាលពីមុនមានឈ្មោះថា គំរោងកែលំអល័ក្ខខ័ណ្ឌការងារក្នុងវិស័យកាត់ដេរ នៃអង្គការពលកម្មអន្តរជាតិ ។

៥. យើងក៏មានសេចក្តីរីករាយផងដែរដែលបានកត់សំគាល់ថា ពុំមានសេចក្តីរាយការណ៏អំពីភស្តុតាងនៃពលកម្មដោយបង្ខំនៅក្នុងចំណោមរោងចក្រដែលត្រូវបានអង្កេតនោះទេ ។

៦. មានរោងចក្រមួយចំនួន ដែលថ្នាក់គ្រប់គ្រងបានជ្រៀតជ្រែកដល់សេរីភាពនៃការរៀបចំសហជីព របស់កម្មករនិយោជិត ។ សេរីភាពនៃការរៀបចំ គឺជាសិទ្ធិការងារដ៏សំខាន់ហើយដែលត្រូវតែគោរព ។

៧. យើងមានការសោកស្តាយដោយបានកត់សំគាល់ថា មានឧប្បត្តិហេតុមួយចំនួនទាក់ទងនឹងការរើសអើងប្រឆាំងស្ត្រីមានផ្ទៃពោះ និងឧប្បត្តិហេតុមួយទៀត គឺការរើសអើងប្រឆាំងនឹងបុរសក្នុងពេលជ្រើសរើសបុគ្គលិក ។

៨. យើងក៏មានការសោកស្តាយផងដែរដោយបានកត់សំគាល់ឃើញថា មានកម្មករនិយោជិតមិនទាន់គ្រប់វ័យចំនួនដប់នាក់ ត្រូវបានរកឃើញធ្វើការនៅក្នុងរោងចក្រចំនួនបួន ។ កង្វះខាតខាងប្រព័ន្ធចុះឈ្មោះកំណើតជាសកល និង ការក្លែងបន្លំឯកសារដោយកម្មករនិយោជិត គឺជាបញ្ហាដ៏សខាន់នៅប្រទេសកម្ពុជា ។ ជាធម្មតាការជួលកម្មករនិយោជិតក្រោមអាយុឱ្យធ្វើការ គឺបណ្តាលមកពីការបន្លំឯកសារដោយកម្មករនិយោជិត ហើយវាពុំមែនជាចេតនារបស់និយោជកទេ ។ មានកិច្ចការជាចាំបាច់ដើម្បីធ្វើការបញ្ជាក់ពីកាតព្វកិច្ចផ្លូវច្បាប់ និង ការទទួលខុសត្រូវដល់ក៏រិតណារបស់និយោជក ក្នុងការពិនិត្យបញ្ជាក់ពីឯកសារដែលត្រូវបានបង្ហាញជូនដោយកម្មករនិយោជិត ដើម្បីកំណត់ពីអាយុរបស់ពួកគេ។

៩. នៅមានចំនុចខ្វះខាតមួយចំនួនសំរាប់អោយមានការកែលំអផ្នែកទំនាក់ទំនងវិជ្ជាជីវៈ ។ ការធ្វើកូដកម្មនៅតែមិនទាន់ត្រូវបានរៀបចំដោយអនុលោមទៅតាមច្បាប់ ហើយក្នុងករណីដែលមានការព្រមព្រៀងគ្នាកិច្ចព្រមព្រៀងនោះមិនត្រូវបានអនុវត្តអោយបានពេញលេញឡើយ។

១០. យើងកត់សំគាល់ដោយសេចក្តីសោកស្តាយថា ជាថ្មីម្តងទៀតរបាយការណ៏ចង្អុលបង្ហាញថា ការបង់ប្រាក់ឈ្នួល ព្រមទាំងចរិតលក្ខណៈ និង ភាពញឹកញាប់នៃការងារបន្ថែមម៉ោង នៅតែជាបញ្ហានៅតាមបណ្តារោចក្រមួយចំនួនធំនៅកម្ពុជា ។ យើងអំពាវនាវដល់និយោជកដែលត្រូវបានរកឃើញថាមានបញ្ហានេះអោយបំពេញនូវកាតព្វកិច្ចស្របច្បាប់របស់ខ្លួននៅក្នុងផ្នែកនេះ ។

១១. យើងក៏កត់សំគាល់ដោយសេចក្តីសោកស្តាយផងដែរថា រោងចក្រជាច្រើនដែលត្រូវបានគ្របដណ្តប់ក្នុងរបាយការណ៏នេះ មិនបានអនុវត្តអោយបានត្រឹមត្រូវតាមបទដ្ឋានសុខភាព និង សុវត្ថិភាពឡើយ ដែលក្នុងនោះរួមទាំងការផ្តល់ និង ការប្រើប្រាស់នូវឧបករណ៏សំរាប់ការពារ ការតំលើងឧបករណ៏ការពារនៅលើម៉ាស៊ីន ការបណ្តុះបណ្តាលត្រឹមត្រូវផ្នែកសុវត្ថិភាព និង ខ្យល់អាកាសចេញចូលគ្រប់គ្រាន់។

១២. ដោយសារកម្ពុជាបានចូលជាសមាជិកអង្គការពាណិជ្ជកម្មពិភពលោក ការលុបចោលនូវកូតានាំចូល និង ការផុតកំណត់នៃកិច្ចព្រមព្រៀងពាណិជ្ជកម្មរវាងកម្ពុជា និងសហរដ្ឋអាមេរិកនោះ យើងជឿជាក់ថាការ មានល័ក្ខខ័ណ្ឌការងារ និង ទំនាក់ទំនងការងារក្នុងកំរិតបទដ្ឋានខ្ពស់នៅក្នុងវិស័យនេះទាំងមូល គឺជាប្រការ សំខាន់បំផុត ។

១៣. ជាថ្មីម្តងទៀត គណៈកម្មការប្រឹក្សាគំរោង សូមអំពាវនាវដល់អ្នកទិញ សូមអោយបង្ហាញនូវការគាំទ្រ របស់ខ្លួន ចំពោះកិច្ចខិតខំប្រឹងប្រែងដែលកំពុងកើតមាននៅកម្ពុជា តាមរយៈការបង្កើននូវការតាំងចិត្ត ទិញផលិតផលពីឧស្សាហកម្មកាត់ដេររបស់យើង និង តាមរយៈការរួមចំណែកបន្ថែមទៀតដល់ល័ក្ខខ័ណ្ឌ ការងារ ដែលកាន់តែមានលក្ខណៈល្អប្រសើរនៅក្នុងវិស័យកាត់ដេរសំលៀកបំពាក់នៅកម្ពុជា ។

ភ្នំពេញ, ថ្ងៃទី ១២ ខែ ឧសភា ឆ្នាំ ២០០៥